ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៩

លេខៈ ១៤

ឆ្នាំ២០២១

## អារម្ភកថា

សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០១៩ នៅតែបន្តសម្រេចបានកំណើនដ៏រឹងមាំក្នុងរង្វង់**៧,១%**។ ផ.ស.ស សម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី**១ ៥៦៣** ដុល្លារអាមេរិកក្នុងឆ្នាំ២០១៨ ដល់**១ ៧០០** ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។ ទន្ទឹមនឹងនេះ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំក្នុងរង្វង់**១,៨%**ក្នុងឆ្នាំ២០១៩ និងអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំរក្សាបានក្នុងកម្រិត**៤ ០៥៥**រៀល ក្នុងមួយដុល្លារអាមេរិក។ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០១៩ ត្រូវបានទ្រទ្រង់ដោយវិស័យសំខាន់ៗ រួមមាន៖ (១)-វិស័យកសិកម្ម ត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមានក្នុងរង្វង់(-០,៥%) (២)-វិស័យឧស្សាហកម្មនៅរក្សាបានកំណើនខ្ពស់ក្នុងរង្វង់ **១១,៣%** ក្នុងឆ្នាំ២០១៩ និង(៣)-វិស័យសេវាកម្មសម្រេចបានក្នុងអត្រា**៦,២%** ក្នុងឆ្នាំ២០១៩។ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវគោលនយោបាយអាទិភាពរបស់ខ្លួនប្រកបដោយជោគជ័យដែលឆ្លុះបញ្ចាំងតាមរយៈ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពភូមិ ឃុំ សម្រាប់ការរស់នៅដោយក្សេមក្សាន្តរបស់ប្រជាជន ព្រមទាំងការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីមិនឱ្យកម្លាំងណាមករំលោភបំពាន និងបំផ្លាញបានឡើយ ២-ធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កាកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន ៣-បន្តធានាសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន ចីរភាព និងធន់នឹងវិបត្តិ ព្រមទាំងធានាបានស្ថិរភាពហិរញ្ញវត្ថុជាទូទៅ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបអាចគ្រប់គ្រងបាន និងអត្រាប្តូរប្រាក់មានស្ថិរភាព ៤-បន្តគាំទ្រដល់ការអនុវត្តការកែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ដើម្បីអភិបាលកិច្ចល្អ ជាពិសេស ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ៥-បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា២០១៨-២០២៥ ៦-បន្តគិតគូរ និងដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងកម្រិតសមស្របជូនដល់មន្ត្រីរាជការទូទៅ ព្រមទាំងបង្កើនប្រាក់សោធនជូននិវត្តជន និងអតីតយុទ្ធជន និងផ្តល់អាទិភាពលើការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីក្នុងកម្រិតគ្រប់គ្រង និងមន្ត្រីដែលមានជំនាញខ្ពស់ ក្នុងក្របខណ្ឌនៃការផ្សារភ្ជាប់ការកែទម្រង់រដ្ឋបាលសាធារណៈទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៧-បន្តអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ជាពិសេសការដាក់ឱ្យអនុវត្តនូវកម្មវិធីគាំពារសង្គមជាអាទិភាពមួយចំនួន រួមមាន៖ (ក)-កម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំនៃគ្រួសារក្រីក្រ (ខ)-របបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ និង(គ)-របបសោធនសម្រាប់កម្មករនិយោជិត ៨-ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី តាមរយៈការជំរុញវិនិយោគសាធារណៈឱ្យគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសាធារណៈចាំបាច់សម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម ៩-បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលកម្មជំនាញប្រកបដោយផលិតភាពឱ្យ

បានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរកិច្ច ១០-បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការបង្កើនការវិនិយោគបន្ថែម ទាំងលើអគារមន្ទីរពេទ្យ សម្ភារបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល ១១-បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្តោតសំខាន់លើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន វិស័យថាមពល និងវិស័យឌីជីថល ដោយក្នុងនោះតម្លៃអគ្គិសនី នឹងត្រូវបានបញ្ចុះទៅតាមកម្មវិធី និងតារាងតម្លៃជាក់លាក់សម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០ ដើម្បីជំរុញការលូតលាស់ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យសេវាកម្ម ១២-បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្មដោយផ្តោតលើការបង្កើនផលិតភាព ពិពិធកម្ម ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម ១៣-ពង្រឹងលំហថវិកា និងយន្តការគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើងជាយថាហេតុ ១៤-បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ១៥-បន្តគ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព សំដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ១៦-គាំទ្រដល់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌអាណត្តិទី៣ ១៧-បន្តកែទម្រង់អភិបាលកិច្ច និងពង្រឹងសមត្ថភាពស្ថាប័ន និងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ជាពិសេសការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព និងតម្លាភាពនៃសេវាសាធារណៈ ដើម្បីទទួលបាននូវការជឿទុកចិត្តកាន់តែខ្លាំងឡើងថែមទៀតពីសំណាក់ប្រជាជន។ ជាក់ស្តែង ចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៩ កើនឡើង **២៦,១%** និងចំណូលសារពើពន្ធបានកើនឡើង **២៧,៥%** ធៀបនឹងការអនុវត្តឆ្នាំ២០១៨ ចំពោះចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០១៩ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៤១,៥% ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១៩ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១,៥% និងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៣,៦%។ រីឯចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៩ មានការកើនឡើង ២១,១% ធៀបនឹងការអនុវត្តឆ្នាំ២០១៨ ចំពោះចំណាយថវិការាជធានី ខេត្តអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ២៩,៣% ចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ១,១% និងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ក៏អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ១៧,៦% ដែរ។ ការអនុវត្តចំណូល និងចំណាយថវិកាថ្នាក់ជាតិបានធ្វើឱ្យមានការសន្សំអតិរេកថវិកាថ្នាក់ជាតិចំនួន៣ ៧៣៥ ២៦៧,៥លានរៀល។ ការគ្រប់គ្រងថវិកាឆ្នាំ២០១៩ អនុវត្តស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ហើយតម្រង់តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន និងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត គិតទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យ។

សមិទ្ធផលទាំងនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តលើកស្ទួយកិត្យានុភាពកម្ពុជា ការការពារបាននូវអធិបតេយ្យជាតិ បូរណភាពទឹកដី ការបន្តពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងធានាបាននូវស័ក្តិសិទ្ធ

ភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា។ ទន្ទឹមគ្នានេះដែរ ថវិកាឆ្នាំ២០១៩ គឺពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការរក្សា ការពារ និងពង្រឹងថែមទៀតនូវសមិទ្ធផលដ៏ធំធេងដែលកម្ពុជាសម្រេចបានកន្លងមក ក៏ដូចជាក្នុងការបន្តបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត។

សរុបមក ថវិកាឆ្នាំ២០១៩ ពិតជាសម្រេចបានតាមការប្រសិទ្ធនាមថាជា " **ថវិកាយុទ្ធសាស្ត្រនៃការរក្សាសមិទ្ធិផលដែលសម្រេចបានដោយលំបាកក្នុងពេលកន្លងមក និងការបន្តបុកគ្រឹះថ្មីៗសម្រាប់គាំទ្រដល់ការសម្រេចបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដើម្បីបន្តរក្សាសន្តិភាព ស្ថិរភាព ក៏ដូចជាទ្រទ្រង់នូវដំណើរការវិវឌ្ឍឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព តទៅមុខឥតឈប់ឈរ**"។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ មានភារកិច្ចចំពោះការអនុវត្តន៍មុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅចូលរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះ ជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០១៩ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ មានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋាន ទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់ស្តីពីសវន

កម្មនៃព្រះរាជាណាចក្រកម្ពុជា ស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មទូទៅ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណៈជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់ស្ថាប័នសវនកម្មកំពូលប្រទេសស៊ុយអែត ដៃគូអភិវឌ្ឍន៍ ព្រមទាំងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរសវនកម្មជាតិនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រលាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ ចន្ទ ៤ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២១

**អគ្គសវនករ**

**សោម គីមសួគ៌**

# មាតិកា

ទំព័រ


**សេចក្ដីសង្ខេប** ........ ១
**១. សេចក្ដីផ្ដើម** ........ ៦
១.១.លក្ខណៈទូទៅ ........ ៦
១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម ........ ៦
១.៣. គោលបំណងនៃការផ្សព្វផ្សាយ ........ ៦
**២. ការគ្រប់គ្រងថវិកា** ........ ៧
២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា ........ ៧
២.២.កិច្ចប្រតិបត្តិការថវិកា ........ ៧
**៣. លទ្ធផលសវនកម្ម** ........ ១២
**៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ** ........ ១២
៣.១.១. ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ........ ១២
៣.១.២. ក្រុមហ៊ុនសហគ្រាសមួយចំនួនមិនបានមកធ្វើបច្ចុប្បន្នភាព ........ ១២
៣.១.៣. ការគ្រប់គ្រងទំនិញនាំចូលបណ្ដោះអាសន្នតាមរបបប្រវេសន៍កាលិកនៅមានកម្រិត ........ ១៣
៣.១.៤. ភាពយឺតយ៉ាវក្នុងការបង់ និងបង្វែចំណូលថវិកាជាតិ និង ទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ........ ១៤
៣.១.៥. ការគ្រប់គ្រងសាច់ប្រាក់ដែលទទួលបានពីការពិន័យ ........ ១៦
៣.១.៦.ភាពយឺតយ៉ាវក្នុងការបង់ភាគលាភសហគ្រាស ........ ១៧
៣.១.៧.ការពុំទាន់បានរៀបចំបញ្ជីបេឡាសាច់ប្រាក់ចំណូល ........ ១៨
៣.១.៨.ការអនុវត្តការងាររបស់ភ្នាក់ងារប្រមូលចំណូលពុំមានលិខិតប្រកាសតែងតាំងជាផ្លូវការ ........ ១៩
៣.១.៩.ចំណូលការិយបរិច្ឆេទ២០១៩ កត់ត្រាជាចំណូលការិយបរិច្ឆេទ២០២០ ........ ១៩
៣.១.១០.ភាពយឺតយ៉ាវក្នុងការបង់ចំណូលថ្លៃឈ្នួល ........ ២០
៣.១.១១.ភាពយឺតយ៉ាវក្នុងការទូទាត់ប្រតិបត្តិការចំណាយ ........ ២១
៣.១.១២.ការអនុវត្តចំណាយលើសឥណទានថវិកាប្រចាំឆ្នាំ ........ ២២
៣.១.១៣.ការចំណាយ និងការទូទាត់ចំណាយពុំមានភ្ជាប់សក្ខីបត្រគ្រប់គ្រាន់ ........ ២២
៣.១.១៤.ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃមិនទាន់មានលក្ខណសម្បត្តិស្របទៅនឹងកម្មវត្ថុនៃការដេញថ្លៃ ........ ២៣
៣.១.១៥.សក្ខីបត្រទូទាត់ចំណាយពុំស្របទៅនឹងប្រតិបត្តិការជាក់ស្ដែង ........ ២៤

៣.១.១៦.ភាពយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយថវិកាឆ្នាំ២០១៩សម្រាប់ទិញទំនិញចាំបាច់ ........ ២៤
៣.១.១៧.ការចំណាយ និងកត់ត្រាចំណាយពុំទាន់ស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ ........ ២៥
៣.១.១៨.ការបំបែកគម្រោងលទ្ធកម្មសាធារណៈ ........ ២៧
៣.១.១៩.ការចុះកិច្ចសន្យាពុំបានតម្រូវឱ្យអ្នកផ្គត់ផ្គង់បំពេញបែបបទចុះបញ្ជីធ្វើអាជីវកម្មយានយន្ត ........ ២៨
៣.១.២០.ការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្ម ........ ២៩
៣.១.២១.ការចុះកិច្ចសន្យាសាងសង់ជាមួយក្រុមហ៊ុនដែលពុំទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ ២៩
៣.១.២២.កង្វះខាតក្នុងការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់ ........ ៣០
៣.១.២៣.ការបំបែកបណ្ណចំណាយដើម្បីគេចវេះកិច្ចលទ្ធកម្ម ........ ៣១
៣.១.២៤.ការចេញបណ្ណចំណាយពុំត្រឹមត្រូវតាមគណនេយ្យភាព ........ ៣២
៣.១.២៥.ការចេញបណ្ណចំណាយដោយពុំមានភ្ជាប់គោលការណ៍ចំណាយ ........ ៣៣
៣.១.២៦.ការទូទាត់ចំណាយថវិកាកម្មវិធីពុំស្របតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ........ ៣៣
៣.១.២៧.ការគ្រោងថវិកាប្រាក់បេសកកម្មពុំសមស្របតាមគោលការណ៍ ........ ៣៤
៣.១.២៨.ការអនុវត្តប្រព័ន្ធFMIS ........ ៣៥
៣.១.២៩.កង្វះខាតក្នុងការកត់ត្រាបញ្ចូលសម្ភារបរិក្ខារបច្ចេកទេសមួយចំនួនចូលទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះឆ្នាំ២០១៩ ........ ៣៦
៣.១.៣០.ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍សមិទ្ធកម្មចំណាយថវិកាកម្មវិធី ........ ៣៧
៣.១.៣១.ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញ ចូលតែមួយ ........ ៣៨
៣.១.៣២.ភាពយឺតយ៉ាវក្នុងការបូកសរុបចំណាយថវិកាកម្មវិធីទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ........ ៣៨
៣.១.៣៣.ការអនុវត្តថវិកាកម្មវិធីពុំទាន់បានពេញលេញ ........ ៣៩
៣.១.៣៤.ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃពុំទាន់ស្របនឹងកម្មវត្ថុនៃការដេញថ្លៃ.. ៤០
៣.១.៣៥.ភាពយឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពសេវាសាធារណៈ ........ ៤១
៣.១.៣៦.ការចេញអាជ្ញាបណ្ណមិនស្របតាមកម្រិតសិក្សារបស់គ្រឹះស្ថានដែលអនុវត្តជាក់ស្តែង ........ ៤២
៣.១.៣៧.ការអនុវត្តកិច្ចលទ្ធកម្មដោយអង្គភាពថវិកាដែលមិនមែនជាអង្គភាពលទ្ធកម្ម .. ៤៣
៣.១.៣៨.ការពុំបានកាត់ប្រាក់១០%ពីគម្រោងដែលបានអនុវត្តដោយអង្គភាពរដ្ឋ ........ ៤៤
៣.១.៣៩.ការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង ........ ៤៥

៣.១.៤០.ការប្រមូលបំណុលពន្ធដែលអ្នកជាប់ពន្ធសន្យាទូទាត់ ............................... ៤៦
៣.១.៤១.បំណុលត្រូវទារពីថ្លៃឈ្នួលឡូត៍នៃសាទ វិនិយោគកៅស៊ូ និងដីសម្បទានសេដ្ឋកិច្ច ............................................................................................... **៤៧**
**៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ............................................ ៤៩**
៣.២.១. ការកត់ត្រាពន្ធឈ្នួលចលន និងអចលនទ្រព្យពុំទាន់សមស្រប ........................ ៤៩
៣.២.២. ភាពយឺតយ៉ាវក្នុងការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួន ........................................................................ ៥០
៣.២.៣. កង្វះខាតក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ ................................. ៥១
៣.២.៤. ការប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់ ...................................................... ៥១
៣.២.៥. ការប្រមូលចំណូលពីការចេញអាជ្ញាបណ្ណទេសចរណ៍ពុំអស់លទ្ធភាព ............. ៥២
៣.២.៦. ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីតាមដានការងារសាងសង់និងជួសជុល ................................................................................................ ៥៤
៣.២.៧. ការសម្រេចជ្រើសអ្នកទទួលការផ្គត់ផ្គង់តាមកិច្ចលទ្ធកម្មសាធារណៈប្រើប៉ាតង់ពុំចំមុខសញ្ញា ............................................................................ ៥៤
៣.២.៨. កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម ..................... ៥៦
៣.២.៩. ការខ្ចីប្រេងឥន្ធនៈប្រើប្រាស់មុនធ្វើកិច្ចលទ្ធកម្ម ........................................... ៥៦
៣.២.១០.ការពុំទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ............................................ ៥៧
៣.២.១១.ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈនៅមានកម្រិត ........................................ ៥៧
**៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម ............................. ៥៩**
៤.១. ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម ..................... ៥៩
៤.២. ការប្រមូលពន្ធប៉ាតង់ពុំទាន់បានពេញលេញ ................................................. ៥៩
៤.៣. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន.......... ៦០
៤.៤. ការគ្រប់គ្រងអ្នកជាប់ពន្ធ ........................................................................ ៦០
៤.៥. ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ ...................................... ៦១
៤.៦. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ .................................................. ៦២
៤.៧. ការប្រើប្រាស់វិក្កយបត្រ ......................................................................... ៦២
៤.៨. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ......................................................... ៦៣
៤.៩.ការប្រមូលពន្ធអចលនទ្រព្យ ..................................................................... ៦៣
៤.១០.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ ............................ ៦៤
៤.១១.ការយឺតយ៉ាវក្នុងការធ្វើសលាកប័ត្របង្វែរថវិកាចូលរតនាគារ ............................ ៦៥
៤.១២.ការយឺតយ៉ាវក្នុងការធ្វើប្រកាសបង្វែរឥណទានតួលេខចំណូលចូលថវិកា ............ ៦៦
៤.១៣.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ........................................ ៦៦

៤.១៤.ការទូទាត់ និងការកត់ត្រាចំណាយ.............................................................. ៦៧
៤.១៥.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ............................................ ៦៨
៤.១៦.ក្រសួង ស្ថាប័នមួយចំនួនមិនបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៩... ៦៩
៤.១៧.ការមិនបានបែងចែក និងវិភាជន៍ឥណទានថវិកាទៅឱ្យអង្គភាពថវិកា ................. ៧០
៤.១៨.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ................ ៧១
៤.១៩.ការធ្វើបណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ............................................. ៧២
**៥.សេចក្តីសន្និដ្ឋាន**........................................................................................ ៧៣

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១៩

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **៣១ ០៥២ ១២២**,៤លានរៀល ស្មើនឹង **២៨,២៣%** នៃផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **២២,៩%** ហើយកើនឡើង **២៤,៣%** ធៀបនឹងការអនុវត្តឆ្នាំ២០១៨។ ចំណូលថវិកាខ្ពស់នេះ គឺជាលទ្ធផលនៃកិច្ចប្រឹងប្រែងយូរឆ្នាំរបស់រាជរដ្ឋាភិបាលលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរួមចំណែកពីសកម្មភាពសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ការអនុវត្តចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អប្រសើរ តាមរយៈយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ យុទ្ធសាស្ត្រកំណែទម្រង់ និងទំនើបកម្មគយ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដូចជា៖ ការពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេស និងការអនុវត្តនីតិវិធីគយ ការពង្រឹងអនុលោមភាព និងប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ ការពង្រឹងយន្តការគ្រប់គ្រងហានិភ័យនិងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ការពង្រឹងវប្បធម៌អនុលោមភាពរបស់វិស័យឯកជន ការពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ និងការពង្រឹងអភិបាលកិច្ចអង្គភាពគយ និងការអភិវឌ្ឍស្ថាប័ន។

ការប្រមូលចំណូលពន្ធអាករបានលទ្ធផលដ៏ល្អប្រសើរនេះ អាចសម្រេចទៅបានដោយសារ៖ (១)-ភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចដែលជំរុញឱ្យមានសកម្មភាពអាជីវកម្មសំខាន់ៗជាច្រើនរីកចម្រើនយ៉ាងឆាប់រហ័ស (២)-តាមរយៈការដាក់ចេញនូវវិធានការគន្លឹះនានាប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការបន្តលើកកម្ពស់អនុលោមភាពអ្នកជាប់ពន្ធដោយការធ្វើទំនើបកម្ម និងសាមញ្ញកម្មសេវាអ្នកជាប់ពន្ធ (៣)-ការបន្តកែសម្រួលគោលនយោបាយសារពើពន្ធ និងវិធានការរដ្ឋបាលសំដៅធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសង្គមសេដ្ឋកិច្ច ធុរកិច្ច និងការទាក់ទាញវិនិយោគទុនពីបរទេស។

ដោយឡែក ចំណូលមិនមែនសារពើពន្ធមានកំណើនខ្ពស់ បានមកពីចំណូលមួយចំនួនដូចជា៖ ការបង់ភាគលាភពីសហគ្រាសសាធារណៈ និងការបង់ចំណូលពាក់ព័ន្ធនឹងវិស័យកាស៊ីណូ ដែលរួមមានទាំងការបង់កាតព្វកិច្ចកាស៊ីណូ ការសងបំណុល និងការទិញសិទ្ធិផ្តាច់មុខ ដែលបានប៉ះប៉ូវដល់ការធ្លាក់ចុះនៃប្រភពចំណូលសំខាន់ៗ រួមមានចំណូលពីផលទុននៃសកម្មភាពទេសចរណ៍ជាដើម។ លើសពីនេះ ក្នុងន័យចូលរួមជំរុញដល់កំណើនចំណូលមិនមែនសារពើពន្ធ រដ្ឋបាលចំណូលមិនមែនសារពើពន្ធបានពង្រឹងប្រសិទ្ធភាពអភិបាលកិច្ចតាមរយៈការអនុវត្តវិធានការគន្លឹះដូចជា៖ (១)-ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) (២)-ការជំរុញការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងអនុវត្តការបង់ប្រាក់តាមប្រព័ន្ធធនាគារ និង (៣)-ការជំរុញការអនុវត្តប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជារួម។

តាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតមានជាអាទិ៍៖ ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ក្រុមហ៊ុនសហគ្រាសមួយចំនួនមិនបានមកធ្វើបច្ចុប្បន្នភាព ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម ការប្រមូលពន្ធប៉ាតង់ពុំទាន់បានពេញលេញ ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន ការគ្រប់គ្រងអ្នកជាប់ពន្ធការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ការប្រើប្រាស់វិក្កយបត្រ ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ការប្រមូលពន្ធអចលនទ្រព្យ ការគ្រប់គ្រងទំនិញនាំចូលបណ្ដោះអាសន្នតាមរបបប្រវេសន៍កាលិកនៅមានកម្រិត ភាពយឺតយ៉ាវក្នុងការបង់និងបង្វែរចំណូលថវិកាជាតិ និងទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ការគ្រប់គ្រងសាច់ប្រាក់ដែលទទួលបានពីការពិន័យ ភាពយឺតយ៉ាវក្នុងការបង់ភាគលាភសហគ្រាស ការពុំទាន់បានរៀបចំបញ្ជីបេឡាសាច់ប្រាក់ចំណូល ការអនុវត្តការងាររបស់ភ្នាក់ងារប្រមូលចំណូលពុំមានលិខិតប្រកាសតែងតាំងជាផ្លូវការ ចំណូលការិយបរិច្ឆេទ២០១៩កត់ត្រាជាចំណូលការិយបរិច្ឆេទ២០២០ ភាពយឺតយ៉ាវក្នុងការបង់ចំណូលថ្លៃឈ្នួល ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ ការយឺតយ៉ាវក្នុងការធ្វើសលាកប័ត្របង្វែរថវិកាចូលរតនាគារ ការយឺតយ៉ាវក្នុងការធ្វើប្រកាសបង្វែរឥណទានតួលេខចំណូលចូលថវិកា និងការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន**២៧ ៣១៦ ៨៥៤,៩** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៣,0%** ហើយស្មើនឹង**២៤,៨៣%** នៃផ.ស.ស គឺមានការកើនឡើង**២១,១%** ធៀបនឹងការអនុវត្តឆ្នាំ២០១៨ ។ ចំណាយថវិកានេះ បានបន្តធានាដល់ការអនុវត្តគោលនយោបាយគាំពារសង្គម បន្តការអនុវត្តកម្មវិធីកែទម្រង់នានា ពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ និងវិនិយោគលើធនធានមនុស្ស ព្រមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក្នុងន័យជំរុញពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែង។ ក្នុងឆ្នាំ២០១៩ មានការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម សំដៅបម្រើដល់កិច្ចការជាអាទិភាព រួមមាន ការផ្តល់ឥណទានដល់ធនាគារអភិវឌ្ឍន៍ជនបទដើម្បីទូទាត់ចំណាយបំពេញតម្រូវការឥណទានរបស់រោងម៉ាស៊ីនកិនស្រូវ ក្នុងការប្រមូលទិញស្រូវពីប្រជា

កសិករ និងដើម្បីបំពេញលក្ខខណ្ឌតម្រូវក្នុងការស្នើសុំអាជ្ញាបណ្ណជាធនាគារពាណិជ្ជ ប្រតិបត្តិការបន្ថែមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការទូទាត់ចំណាយវិនិយោគលើការសាងសង់រោងចក្រផលិតអគ្គិសនី។

ចំពោះចំណាយចរន្តផ្តោតលើការដំឡើងបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ សំដៅលើកកម្ពស់ជីវភាពមន្ត្រីសាធារណៈ និងការអនុវត្តកម្មវិធីនានាក្នុងគោលនយោបាយគាំពារសង្គម ដែលរួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ កម្មវិធីមូលនិធិសមធម៌ផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃ និងការឧបត្ថម្ភមាតុភាពដល់កម្មករនិយោជិត។ ដោយឡែកចំណាយមូលធនផ្តោតលើការវិនិយោគ បានចូលរួមចំណែកក្នុងការអភិវឌ្ឍគម្រោងវិនិយោគ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានគុណភាពខ្ពស់ និងទំហំធំនៅក្នុងវិស័យអាទិភាព ជាពិសេសផ្តោតលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូនថាមពល និងឌីជីថល។

ជារួម ការអនុវត្តចំណាយក្នុងឆ្នាំ២០១៩ ត្រូវបានវាយតម្លៃថាកាន់តែមានប្រសិទ្ធភាពខ្ពស់តាមរយៈការបន្តបោះជំហានយ៉ាងមុតមាំក្នុងកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបន្តពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងបែងចែកធនធានហិរញ្ញវត្ថុសាធារណៈ និងតម្រង់ខ្លួនឆ្ពោះទៅសម្រេចបាននូវប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។ ការអនុវត្តគោលនយោបាយចំណាយថវិកាឆ្នាំ២០១៩ សម្រេចបានលទ្ធផលល្អ ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ដោយបានបំពេញតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមការគ្រោងទុក និងដោះស្រាយបាននូវអាទិភាពគោលនយោបាយថ្មីៗ ឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ និងគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដូចជា៖ ការសម្រេចបានការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ការបង្កើននូវប្រសិទ្ធភាពចំណាយតាមរយៈវិធានការបង្កើនប្រសិទ្ធភាពក្នុងការវិភាជ និងក្នុងការពិនិត្យផ្តល់ធានាចំណាយ ដោយធានាបាននូវចំណាយចំមុខសញ្ញាមានភាពចាំបាច់ តម្លៃសមរម្យ បរិមាណត្រឹមត្រូវ គុណភាពសមរម្យ និងទាន់ពេលវេលា ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលសន្សំសំចៃថវិកាបានមួយចំនួន យន្តការផ្ទេរមុខងារពីក្រសួង ស្ថាប័ន ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងដំណើរការអនុវត្តឱនភាពទូទៅនៃថវិកា ត្រូវបានកាត់បន្ថយឱ្យមកស្ថិតនៅក្នុងកម្រិតដែលបានរួមចំណែកយ៉ាងចម្បងក្នុងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងរយៈពេលវែងដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ជាពិសេសតាមគោលការណ៍គន្លឹះទាំង៥ គោលនយោបាយក្នុងការពង្រីក និងការលើកកម្ពស់ការអភិវឌ្ឍនៅរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ តាមរយៈការចែករំលែកចំណូលថវិកាដែលមានប្រភពពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ជូនរដ្ឋបាលក្រុង ស្រុកចំនួន៣% និងរដ្ឋបាលឃុំ សង្កាត់ចំនួន១% សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា៖ ភាពយឺតយ៉ាវក្នុងការទូទាត់ប្រតិបត្តិការចំណាយ ការអនុវត្តចំណាយលើសឥណទានថវិកាប្រចាំឆ្នាំ សក្ខីបត្រទូទាត់ចំណាយពុំស្របទៅនឹងប្រតិបត្តិការជាក់ស្តែង ការពុំបានរៀបចំ

គម្រោង និងស្នើសុំធានាចំណាយថវិកាឆ្នាំ២០១៩ សម្រាប់ទិញទំនិញចាំបាច់ ការចំណាយ និងកត់ត្រាចំណាយពុំទាន់ស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ ការទូទាត់ និងការកត់ត្រាចំណាយ ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ការបំបែកគម្រោងលទ្ធកម្មសាធារណៈ ការចុះកិច្ចសន្យាពុំបានតម្រូវឱ្យអ្នកផ្គត់ផ្គង់បំពេញបែបបទចុះបញ្ជីធ្វើអាជីវកម្មយានយន្ត ការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្ម ការចុះកិច្ចសន្យាសាងសង់ជាមួយក្រុមហ៊ុនដែលពុំទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់ កង្វះខាតក្នុងការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់ ការបំបែកបណ្ណចំណាយដើម្បីគេចវេសកិច្ចលទ្ធកម្ម ការចេញបណ្ណចំណាយពុំត្រឹមត្រូវតាមគណនេយ្យភាព ការចេញបណ្ណចំណាយពុំមានភ្ជាប់គោលការណ៍ចំណាយ ការទូទាត់ចំណាយថវិកាកម្មវិធីពុំស្របតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ការគ្រោងថវិកាប្រាក់បេសកកម្មពុំសមស្របតាមគោលការណ៍ ការអនុវត្តប្រព័ន្ធFMIS កង្វះខាតក្នុងការកត់ត្រាបញ្ចូលសម្ភារបរិក្ខារបច្ចេកទេសមួយចំនួនចូលទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះឆ្នាំ២០១៩ ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍សមិទ្ធកម្មចំណាយថវិកាកម្មវិធី ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ ភាពយឺតយ៉ាវក្នុងការបូកសរុបចំណាយថវិកាកម្មវិធីទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ការអនុវត្តថវិកាកម្មវិធីពុំទាន់បានពេញលេញ ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃពុំទាន់ស្របនឹងកម្មវត្ថុនៃការដេញថ្លៃ ភាពយឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពសេវាសាធារណៈ ការចេញអាជ្ញាបណ្ណមិនស្របតាមកម្រិតសិក្សារបស់គ្រឹះស្ថានដែលអនុវត្តជាក់ស្តែង ការអនុវត្តកិច្ចលទ្ធកម្មដោយអង្គភាពថវិកាដែលមិនមែនជាអង្គភាពលទ្ធកម្ម ការពុំបានកាត់ប្រាក់១០%ពីគម្រោងដែលបានអនុវត្តដោយអង្គភាពរដ្ឋ ក្រសួងស្ថាប័នមួយចំនួនមិនបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៩ ការមិនបានបែងចែក និងវិភាជន៍តណទានថវិកាទៅឱ្យអង្គភាពថវិកា ការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង ការប្រមូលបំណុលពន្ធដែលអ្នកជាប់ពន្ធសន្យាទូទាត់ បំណុលត្រូវទារពីថ្លៃឈ្នួលឡូត៍នៃសាទ វិនិយោគកៅស៊ូ និងដីសម្បទានសេដ្ឋកិច្ច។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន**៥ ០២៧ ០៨៩,២** លានរៀល ស្មើនឹង**៩៤,៤%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន**៥ ៣២៣ ៧៦៨,០**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន**២៩៦ ៦៧៨,៨** លានរៀល។

### ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**២ ៥៨៩ ៥៨១,០** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**៤១,៥%** និងចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្ត អនុវត្តបានចំនួន**២ ៣៥៤ ០៥២,៦**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**២៩,៣%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តចំនួន**២៤០ ០៩១,៥** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**១,៥%** និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន**២៣៣ ៨៦៦,២** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **១,១%**។ រីឯចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានចំនួន**៦៨៤ ៧៧១,៩** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ

**៣,៦%** និងចំណាយចរិការបស់រដ្ឋបាលឃុំសង្កាត់ អនុវត្តបានចំនួន**៥៤៤ ៧០២,៧**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**១៧,៦%**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់មួយចំនួនដូចជា៖ ការកត់ត្រាពន្ធឈ្នួលចលន និងអចលនទ្រព្យពុំទាន់សមស្រប ភាពយឺតយ៉ាវក្នុងការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួន កង្វះខាតក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ ការប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់ ការប្រមូលចំណូលពីការចេញអាជ្ញាបណ្ណទេសចរណ៍ពុំអស់លទ្ធភាព ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីតាមដានការងារសាងសង់ និងជួសជុល ការសម្រេចជ្រើសអ្នកទទួលការផ្គត់ផ្គង់តាមកិច្ចលទ្ធកម្មសាធារណៈប្រើប៉ាតង់ពុំចំមុខសញ្ញា កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម ការខ្ចីប្រេងឥន្ធនៈប្រើប្រាស់មុនធ្វើកិច្ចលទ្ធកម្ម ការពុំទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការគ្រប់គ្រងស្តានីយប្រេងឥន្ធនៈនៅមានកម្រិត។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជិកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុរដ្ឋចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

### ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ ២០២០ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះ ត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មទូទៅដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាម

រយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

# ២. ការគ្រប់គ្រងថវិកា

## ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១៩ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៩ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ២០១៩ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| I. សរុបចំណូល | **២៥ ៣៦០ ០២៨,០** | **៣១ ០៥២ ១២២,៤** | **១២២,៤%** |
| -ចំណូលចរន្ត | ១៩ ៥៩៣ ១១១,០ | ២៥ ៣៩៥ ០២១,៩ | ១២៩,៦% |
| -ចំណូលមូលធនក្នុងប្រទេស | ១៩៣ ១៥៩,០ | ១៨១ ៤២៦,៧ | ៩៣,៩% |
| -ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២៥០ ០០០,០ | ៤៤៨ ៥៨៤,៦ | ១៧៩,៤% |

| បរិយាយ | ២០១៩ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| -ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៥ ៣២៣ ៧៦៨,០ | ៥ ០២៧ ០៨៩,២ | ៩៤,៤% |
| **II. សរុបចំណាយ** | **២៨ ១៦១ ២៣០,០**[*] | **២៧ ៣១៦ ៨៥៤,៩** | **៩៧,0%** |
| -ចំណាយចរន្ត | ១៧ ៩៩៣ ៤៨២,០[*] | ១៧ ៨៨៩ ៤៩២,៩ | ៩៩,៤% |
| -ចំណាយមូលធន | ៤ ៨៤៣ ៩៨០,០ | ៤ ៤០០ ២៧២,៨ | ៩០,៨% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៥ ៣២៣ ៧៦៨,០ | ៥ ០២៧ ០៨៩,២ | ៩៤,១% |

[*] តួលេខនេះបូកបញ្ចូលនូវ៖ (១)-ឥណទានថវិកាចំនួន១ ៤៣៤ ២០០,០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និង(២)-ឥណទានថវិកាចំនួន ៩៦២ ០០២,០ លានរៀល ត្រូវបានបែងចែកឡើងវិញដោយយោងប្រកាសបន្ថែមឥណទានថវិកាអនុលោមតាមមាត្រា៤២(ថ្មី) នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ២០១៩ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **១ ៨៣០ ៣១៤,០*** | **២ ៥៨៩ ៥៨១,០** | **១៤១,៥%** |
| -ចំណូលចរន្ត | ១ ៣៩៣ ១៣៨,០ | ២ ១៦២ ៥៤៥,០ | ១៥៥,២% |
| •ចំណូលសារពើពន្ធ | ១ ៣៥១ ៦១៦,៧ | ២ ១១៣ ៧៤៣,០ | ១៥៦,៤% |
| •ចំណូលពុំមែនសារពើពន្ធ | ៤១ ៥២១,៣ | ៤៨ ៨០១,៩ | ១១៧,៥% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៤៣៧ ១៧៦,០* | ៤២៧ ០៣៦,០ | ៩៧,៧% |
| **II. សរុបចំណាយថវិកា** | **១ ៨២០ ១៧២,៥**** | **២ ៣៥៤ ០៥២,៥** | **១២៩,៣%** |
| -ចំណាយចរន្ត | ១ ៣៧០ ៦០៩,៥** | ១ ៨៧៤ ៨២៥,២ | ១៣៦,៨% |
| -ចំណាយមូលធន | ៤៤៩ ៥៦៣,០ | ៤៧៩ ២២៧,៣ | ១០៦,៦% |

* តួលេខនេះបូកបញ្ចូលនូវ៖ (១)-ឥណទានចំនួន៣៤២ ៤៥០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ (២)-ឥណទានចំនួន៥ ៩៩០លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកា ជូនសាលាខេត្តសៀមរាប និង(៣)-ឥណទានចំនួន៤ ៩២៨ លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ជូនរដ្ឋបាលរាជធានី ខេត្តចំនួន១៨ ដើម្បីអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋបាលរាជធានី ខេត្ត

**តួលេខនេះបូកបញ្ចូលនូវឥណទានសរុបចំនួន៣៤៣ ២២៨ លានរៀល រួមមានចំណាយចរន្តចំនួន២៥៤ ៩៦៤ លានរៀល និងចំណាយមូលធនចំនួន៨៨ ២៦៤ លានរៀល ដែលក្នុងនោះ ៖ (១)-ឥណទានចំនួន៣៣២ ៣១០លានរៀល ដោយយោងប្រកាសបន្ថែមឥណទាន ដើម្បីបែងចែកទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត (២)-ឥណទានចំនួន៥ ៩៩០លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកាជូនសាលាខេត្តសៀមរាប និង៣)-ឥណទានចំនួន៤ ៩២៨លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកា ជូនរដ្ឋបាលរាជធានី ខេត្តចំនួន១៨ ដើម្បីអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋបាលរាជធានី ខេត្ត។

## ខ២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ២០១៩ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **២៣៦ ៥១៨,៣** | **២៤០ ០៩១,៥** | **១០១,៥%** |
| -ចំណូលចរន្ត (មិនមែនសារពើពន្ធ) | ២៤ ០១០,២* | ២៧ ៩០០,៩ | ១១៦,២% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ២០១ ១៦៣,០** | ២០០ ៨៤៥,៥ | ៩៩,៨% |
| -អតិរេកឆ្នាំ២០១៨ | ១១ ៣៤៥,១*** | ១១ ៣៤៥,១ | ១០០,០% |
| **II. សរុបចំណាយថវិកា** | **២៣៦ ៥១៨,៣** | **២៣៣ ៨៦៦,២** | **៩៨,៩%** |
| -ចំណាយចរន្ត | ២៣៥ ៨៧៦,៨**** | ២៣៣ ២៣០,៧ | ៩៨,៩% |
| -ចំណាយមូលធន | ៦៤១,៥***** | ៦៣៥,៥ | ៩៩,១% |

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន៩ ១៨០,២ លានរៀល ពីប្រភពការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត៣% និងតួលេខថវិកាចំនួន៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន។

(**) តួលេខនេះបូកបញ្ចូលនូវតួលេខនេះបូកបន្ថែមថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣១ស្រុក ចំនួន៩ ១០៣,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍។

(***)តួលេខនេះបូកបញ្ចូលឥណទានថវិកាចំនួន១១ ៣៤៥,១លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

(****)តួលេខនេះបាន៖ (១)-បូកបញ្ចូលនូវ៖ (ក)-ឥណទានចំនួន១១ ២៣៤,៦លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ (ខ)-ឥណទានចំនួន៩ ១៨០,២លានរៀល ដោយយោងប្រកាសបន្ថែមឥណទានថវិកាពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត៣% សម្រាប់ចំណាយអភិវឌ្ឍន៍ (គ)-ប្រកាសបន្ថែមឥណទានថវិកាចំនួន៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន និង(ឃ)-ប្រកាសបន្ថែមឥណទានថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣១ស្រុក ចំនួន៨ ៦៧០,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍ និង(២)-ផ្ទេរឥណទានចំនួន៩៨,០លានរៀល ចេញពីអនុគណនី៦១០៥៤ ទៅចំណាយមូលធនក្នុងអនុគណនី២០១៤៦ ជូនរដ្ឋបាលស្រុកគិរីវង្ស។

(*****)តួលេខនេះបូកបញ្ចូលនូវ៖ (១)-ឥណទានចំនួន៥៤៣,៥លានរៀល ដោយបន្ថែមឥណទានជូនរដ្ឋបាលស្រុកសំរោងទងនៃខេត្តកំពង់ស្ពឺ ក្នុងនោះមាន មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (SNIF) ចំនួន៤៣៣,០លានរៀល និងការផ្ទេរមុខងារក្រសួងអភិវឌ្ឍន៍ជនបទចំនួន១១០,៥លានរៀល សម្រាប់ធ្វើផ្លូវលំជនបទដោយការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និង(២)-ឥណទានចំនួន៩៨,០លានរៀលដោយការធ្វើនិយ័តភាពឥណទានផ្ទៃក្នុងពីចំណាយចរន្តជូនរដ្ឋបាលស្រុកគិរីវង្សនៃខេត្តតាកែវ សម្រាប់ការងារសាងសង់បង្គោលភ្លើងបំភ្លឺសាធារណៈ។

## ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ២០១៩ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៦៦១ ០០៣,១** | **៦៨៤ ៧៧១,៩** | **១០៣,៦%** |
| -ចំណូលមិនមែនសារពើពន្ធ | ០ | ២៣ ៧៦៨,៨ | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិ | ៥២៣ ៨០០,០ | ៥២៣ ៨០០,០ | ១០០,០% |
| -អតិរេកឆ្នាំ២០១៨ | ១៣៧ ២០៣,១* | ១៣៧ ២០៣,១ | ១០០,០% |
| **II. សរុបចំណាយថវិកា** | **៦៦១ ០០៣,១** | **៥៤៤ ៧០២,៧** | **៨២,៤%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ៤៧ ៧០៨,៧ | ៤២ ២៤៦,៣ | ៨៨,៦% |
| - ចំណាយសង្កាត់ចំណុះក្រុង | ៥៤ ០៣៥,៧ | ៤១ ៧៣៦,៦ | ៧៧,២% |
| -ចំណាយឃុំ | ៥៥៩ ២៥៨,៧ | ៤៦០ ៧១៩,៨ | ៨២,៤% |

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន១៣៧ ២០៣,១លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

# ៣. លទ្ធផលសវនកម្ម

## ៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១.ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម

ដើម្បីទប់ស្កាត់ការគេចវេះពន្ធ ឬការប្រកាសពន្ធមិនត្រឹមត្រូវ ជាពិសេសចំពោះអាជីវកម្មនាំចេញ និងនាំចូលទំនិញ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិព្យួរទុក ឬដកហូតមកវិញនូវវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមគំរូថ្មី ប្រសិនបើសហគ្រាសក្រុមហ៊ុនណាមួយមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករក្នុងរយៈពេល៣ខែជាប់គ្នា។ តាមការពិនិត្យស្ថិតិក្រុមហ៊ុនសហគ្រាសអ្នកជាប់ពន្ធមធ្យមក្នុងឆ្នាំ២០១៩ នៅសាខាពន្ធដារខណ្ឌចំនួន០៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនសហគ្រាសចំនួន៦ ០២១ បានដាក់លិខិតប្រកាសពន្ធប្រចាំខែសូន្យ (គ្មានសកម្មភាព) ក្នុងនោះ សាខាពន្ធដារខេត្ត ខណ្ឌទាំងនោះបានព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុន សហគ្រាសចំនួន ៩៦១ ប៉ុន្តែនៅសល់ក្រុមហ៊ុន សហគ្រាសមួយចំនួន ដែលសាខាពន្ធដារខេត្ត ខណ្ឌនៅមិនទាន់បានព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមនៅឡើយ។

ដោយសារការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមមិនទាន់បានគត់មត់ អគ្គនាយកដ្ឋានពន្ធដារអាចនឹងជួបការលំបាកក្នុងការទប់ស្កាត់ការគេចវេះពន្ធ ឬការប្រកាសពន្ធមិនត្រឹមត្រូវ និងទាន់ពេលវេលា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារអនុវត្តសិទ្ធិព្យួរទុក ឬដកហូតមកវិញនូវវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមគំរូថ្មីចំពោះសហគ្រាសក្រុមហ៊ុនណាមួយមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករក្នុងរយៈពេល៣ខែជាប់គ្នាឱ្យបានគត់មត់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំប្រកាស និងសេចក្តីណែនាំបន្ថែម អំពីនីតិវិធីនៃការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ដើម្បីឱ្យគ្រប់អង្គភាពនៅក្រោមអគ្គនាយកដ្ឋានពន្ធដារអនុវត្តស្តង់ដារតែមួយ និងមានការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀតផងដែរ។

អាជ្ញាធរសវនកម្មជាតិទទួលយកការឆ្លើយបំភ្លឺនេះ។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២.ក្រុមហ៊ុនសហគ្រាសមួយចំនួនមិនបានមកធ្វើបច្ចុប្បន្នភាព

ដើម្បីគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ផ្តល់សេវាជូនអ្នកជាប់ពន្ធ និងប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានតម្រូវឱ្យអ្នកជាប់ពន្ធ ដែលមានការផ្លាស់ប្តូរព័ត៌មានដូចជា អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ឬសកម្មភាពអាជីវកម្ម ការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់ភាគហ៊ុន សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬសាខា ការបញ្ឈប់អាជីវកម្ម អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ព័ត៌មានគណនីធនាគារ ព័ត៌មានទំនាក់ទំនង លេខទូរស័ព្ទ សារអេឡិចត្រូនិក និងអ្នកជាប់ពន្ធដែលចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ មានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ថ្ងៃ

នៃថ្ងៃធ្វើការ។ តាមការពិនិត្យស្ថិតិសហគ្រាសមិនទាន់ធ្វើបច្ចុប្បន្នភាពគិតត្រឹមខែធ្នូ ឆ្នាំ២០១៩ នៅសាខាពន្ធដារខណ្ឌចំនួន០៩ និងខេត្តចំនួន១៤ ដោយមិនរាប់បញ្ចូលអង្គការ និងស្ថាប័នរដ្ឋ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅមានក្រុមហ៊ុន សហគ្រាសចំនួន៨៦៩ មិនទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយ។

ការខកខានរបស់អ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចផ្តល់នូវព័ត៌មានបច្ចុប្បន្នជូនមករដ្ឋបាលសារពើពន្ធ នាំឱ្យរដ្ឋបាលសារពើពន្ធមិនអាចផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យបានល្អប្រសើរ និងប្រមូលពន្ធ ឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារមានវិធានការបន្ថែមចំពោះអ្នកជាប់ពន្ធដែលមិនមកធ្វើបច្ចុប្បន្នភាពព័ត៌មាន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានខិតខំជំរុញប្រព័ន្ធនៃការចុះបញ្ជីឱ្យបានល្អប្រសើរ និងការធ្វើបច្ចុប្បន្នភាពដែលមានរួមទាំងវិធានការ ពេលសវនករចុះធ្វើសវនកម្មផងដែរ។ ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារក៏បានរៀបចំប្រកាសលេខ៧០១ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ គឺក្នុងគោលបំណងពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ និងការគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធ ដើម្បីគាំទ្រដល់ការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលពន្ធឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តខិតខំជំរុញការធ្វើបច្ចុប្បន្នភាពនេះឱ្យកាន់តែល្អប្រសើរ។

អាជ្ញាធរសវនកម្មជាតិទទួលយកការឆ្លើយបំភ្លឺនេះ។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពនៃការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ។

**៣.១.៣.ការគ្រប់គ្រងទំនិញនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិកនៅមានកម្រិត**

នាយកដ្ឋានរបបគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងាររបបគយដោយមានតួនាទី និងភារកិច្ចដូចជា៖ ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាតគយនាំចេញ នាំចូលទំនិញតាមរបបគយអនុគ្រោះនានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងមានភារកិច្ចតាមដានត្រួតពិនិត្យការប្រើប្រាស់សម្ភារបរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការគ្រប់គ្រងទំនិញនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិកនៅមានកម្រិតនៅឡើយ ដូចជាការលក់ ការផ្ទេរ និងការបង្វែរទិសដៅនៃការប្រើប្រាស់រថយន្ត ទោចក្រយានយន្ត គ្រឿងម៉ាស៊ីន និងគ្រឿងចក្រផ្សេងៗដទៃទៀតដែលបាននាំចូលបណ្តោះអាសន្ន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា កន្លងមក អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (អគរ) បានពិនិត្យ និងអនុញ្ញាតឱ្យលក់ ផ្ទេរ និងបង្វែរនូវរថយន្ត សម្ភារបរិក្ខារ ឬគ្រឿងចក្រ ដែលត្រូវបាននាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិកដោយពន្ធអាករជាបន្ទុករដ្ឋ តាមបទប្បញ្ញត្តិជាធរមាន តាមការស្នើសុំរបស់ក្រសួង ស្ថាប័នរដ្ឋ ស្ថានទូត អង្គការអន្តរជាតិ និងបុគ្គលពាក់ព័ន្ធ ដោយមានចងក្រងជារបាយការណ៍តាមដានការលក់ ការផ្ទេរ និងការបង្វែរទិសដៅប្រើប្រាស់ ប៉ុន្តែអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានកត់សម្គាល់ឃើញថា ការគ្រប់គ្រងទំនិញនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិកនៅមានកម្រិតនៅឡើយ។

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងទំនិញនាំចូលតាមរបបប្រវេសន៍កាលិកនោះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បាននិងកំពុងបន្តកំណត់មុខសញ្ញាចុះត្រួតពិនិត្យអនុលោមភាព និងពិនិត្យលទ្ធភាពកែសម្រួលបទប្បញ្ញត្តិ ឬចេញសេចក្តីណែនាំអនុវត្តឱ្យកាន់តែសមស្របតាមស្ថានភាពជាក់ស្តែងថែមទៀត។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

**៣.១.៤.ភាពយឺតយ៉ាវក្នុងការបង់ និងបង្វែចំណូលថវិកាជាតិ និងទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត**

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ផ្នែកទី២ មាត្រា៣៩ បានចែងថា "នៅរៀងរាល់ចុងខែនីមួយៗ យោងតាមចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលប្រមូលបានតាមរយៈគណនីទោលរបស់រតនាគារ ឬគណនីរបស់ធានាដៃគូ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវធ្វើសលាកបត្រចំណូលថវិកាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិដែលជាសក្ខីបត្រមូលដ្ឋានសម្រាប់គណនេយ្យករសាធារណៈនៅរតនាគារ ដើម្បីបំពេញនីតិវិធីកត់ត្រាជាចំណូលថវិកាជាតិ" និងសារាចរណែនាំលេខ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់សេវាសាធារណៈ ត្រង់ផ្នែកទី៣ ចំណុចទី៩.១ ចំណែកទី១ បានកំណត់ថា: ប្រាក់ចំណូលដែលត្រូវបង់ចូលថវិកាជាតិជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ។ ចំណែកប្រាក់ចំណូលនេះជាចំណូលពិត និងធ្វើសលាកបត្រចំណូលថវិកាជាតិដែលជាសក្ខីបត្រយោងសម្រាប់កត់ត្រាចំណូលថវិកាជាតិ និងចំណែកទី២ បានកំណត់ថា:...ជារៀងរាល់ខែ រដ្ឋទេយ្យករចំណូលត្រូវបូកសរុបប្រាក់ចំណូលចំណែកទី២នេះ និងធ្វើសលាកបត្រចំណូលថវិកាជាតិ ដើម្បីជាមូលដ្ឋានសម្រាប់កត់ត្រាជាចំណូលថវិកាជាតិ និងសម្រាប់ការអនុវត្តនីតិវិធីទូទាត់លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត" តាមរយៈការប្រើប្រាស់តារាងស្តីពីការគណនាប្រាក់រង្វាន់ ដែលចំនួនទឹកប្រាក់សរុបនេះត្រូវប្រើជាមូលដ្ឋានសម្រាប់ចុះនៅក្នុងសលាកបត្រចំណូលថវិកាជាតិផង និងចុះនៅក្នុងអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម)ផង និងចំណុចទី៨ ករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តណាមួយមិន

យកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីទូទាត់ប្រាក់បុរេប្រទានលើប្រាក់រង្វាន់លើកទឹកចិត្តឱ្យបាន ទាន់ពេលវេលា ឬមិនបានរៀបចំសំណុំឯកសារ ដើម្បីធ្វើការទូទាត់ទេនោះនឹងត្រូវប្រឈមទៅ នឹងការពិន័យរដ្ឋបាលពីប្រមុខរាជរដ្ឋាភិបាលជាយថាហេតុ"។ សារាចរណែនាំលេខ០០៧ សហវ.អថ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការ ធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៩ ត្រង់ផ្នែកទី១ ចំណុច"ក" បានកំណត់ថា "ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុក ប្រើប្រាស់ជាប្រយោជន៍ណាមួយបានឡើយ។ ដូចនេះ ប្រាក់ចំណូលទាំងអស់ ត្រូវតែប្រមូល បង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ជាកំហិត"។

អាជ្ញាធរសវនកម្មជាតិ សង្កេតឃើញថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសាធារណការ និងដឹកជញ្ជូន នៅមានភាពយឺតយ៉ាវក្នុងការបង់បង្វែចំណូលថវិកា ជាតិ(រង្វាន់) និងទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ស្រប តាមខ្លឹមសារនៃអនុក្រឹត្យ និងប្រកាសខាងលើនៅឡើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅមានភាពយឺតយ៉ាវក្នុងការធ្វើសលាកបត្រចំណូលថវិកាជាតិដែលប្រមូលបានក្នុង ឆ្នាំ២០១៩ មានចំនួន ៤ ៧៨៦ ៧១៨ ៥៦៣រៀល ដើម្បីជាមូលដ្ឋានសម្រាប់កត់ត្រាឆ្លុះបញ្ចាំង ជាចំណូលថវិកាជាតិសម្រាប់ឆ្នាំ២០១៩ ឱ្យបានពេញលេញ និងត្រឹមត្រូវទៅតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុនៅឡើយ។ បន្ថែមពីនោះ អាជ្ញាធរសវនកម្មជាតិ ក៏បានកត់សម្គាល់ឃើញថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តក្នុងឆ្នាំ២០១៩ សរុបមានចំនួន១៣ ០០៥ ៤៦៩ ២៦៥រៀល ក្នុងនោះ ប្រាក់រង្វាន់ក្នុងឆ្នាំ២០១៩ បានទូទាត់ មានចំនួនសរុបចំនួន៦ ៩៣០ ០៦៤ ៤៣០រៀល និងប្រាក់រង្វាន់សល់ពីឆ្នាំ២០១៨ យកមក ទូទាត់ឥណទានឆ្នាំ២០១៩ សរុបមានចំនួន៦ ០៧៥ ៤០៤ ៨៣៥រៀល។ ចំណែកឯតាមរយៈ ការពិនិត្យ និងប្រៀបធៀបរបាយការណ៍ចំណូលដែលពាក់ព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ក្រសួងសាធារណការ និងដឹក ជញ្ជូន បានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូលនូវចំណូលសរុបចំនួន ៤៩ ៨៥៨ ២៧៨ ៤០០ រៀល ប៉ុន្តែក្នុងតារាងសរុបចំណូលថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ បានកត់ត្រាចំណូលសរុបចំនួន ៤៩ ០៣១ ១២៥ ៨២៨ រៀល ដោយមានគម្លាត នៃការបង់ និងបង្វែរចំណូលសរុបចំនួន ៨២៧ ១៥២ ៥៧២ រៀល។ កត្តាទាំងនេះ អាចឱ្យ ការទទួលស្គាល់ និងការកត់ត្រាប្រាក់ចំណូលថវិកាថ្នាក់ជាតិនៅក្នុងឆ្នាំ មិនបានត្រឹមត្រូវ និង ទាន់ពេលវេលា។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសាធារណ ការ និងដឹកជញ្ជូន គួររៀបចំបង់ និងបង្វែរចំណូលថវិកា និងទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត

នៅក្នុងឆ្នាំនីមួយៗ ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា នៃការិយបរិច្ឆេទនៃឆ្នាំថវិកា ដើម្បីឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យ និងសារាចរណែនាំខាងលើ ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការបញ្ជាក់ថា ក្រសួងតែងតែបានយកចិត្តទុកដាក់ខ្ពស់អនុវត្តតាមនីតិវិធីហិរញ្ញវត្ថុ និងការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយក្រសួងបានរៀបចំអាណត្តិទូទាត់ប្រាក់បុរេប្រទាន ប្រាក់រង្វាន់លើកទឹកចិត្តពីការផ្តល់សេវាសាធារណៈ ទៅតាមឥណទានថវិកា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ឱ្យ ហើយក្នុងនោះ ជារៀងរាល់ឆ្នាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការស្នើសុំឥណទានបន្ថែមសម្រាប់ទូទាត់ប្រាក់បុរេប្រទាន ប្រាក់រង្វាន់លើកទឹកចិត្តពីការផ្តល់សេវាសាធារណៈ ប៉ុន្តែការផ្តល់ឥណទានសម្រាប់ទូទាត់មិនគ្រប់គ្រាន់ ទើបធ្វើឱ្យការទូទាត់ប្រាក់រង្វាន់នេះត្រូវឆ្លងឆ្នាំ។ តួលេខប្រាក់រង្វាន់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានរាយការណ៍ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ) និងសុំកិច្ចអន្តរាគមន៍ ដើម្បីដោះស្រាយពីបញ្ហាកង្វះឥណទានសម្រាប់ទូទាត់ប្រាក់រង្វាន់នេះផងដែរ។ ចំណែកឯ ក្រសួងសាធារណការ និងដឹកជញ្ជូន បានបញ្ជាក់ចំពោះករណីលើកឡើងខាងលើថា របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល មានចំនួនច្រើនជាងចំណូលថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ (ផ្ទុផ្ទងឆ្នាំ ២០១៩) ការលម្អៀងតួលេខនេះ បណ្តាលមកពីការទូទាត់ឆ្លងឆ្នាំជាក់ស្តែងប្រាក់រង្វាន់រៀងរាល់ចុងឆ្នាំ ក្រសួងតែងតែខ្វះឥណទានសម្រាប់ធ្វើការទូទាត់នាំឱ្យនាយកដ្ឋានចំណូល នៃអគ្គនាយកដ្ឋានរតនាគារជាតិ កត់ត្រាតួលេខសលាកបត្រចំណូលថវិកាជាតិចូលទៅឆ្នាំបន្ទាប់ ប៉ុន្តែក្រសួងមិនដែលបង្វែរលុយចូលថវិកាជាតិឆ្លងឆ្នាំនោះទេ។

ផ្អែកតាមបញ្ជាក់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងធ្វើបង់បង្វែចំណូលថវិកាជាតិ និងទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាស្របតាមគោលការណ៍នៃអនុក្រឹត្យ និងសារាចរណែនាំខាងលើឱ្យបានខ្ជាប់ខ្ជួន។

**៣.១.៥.ការគ្រប់គ្រងសាច់ប្រាក់ដែលទទួលបានពីការពិន័យ**

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់មាត្រា៦១ ចែងថា "រដ្ឋទេយ្យករចំណូល ឬភ្នាក់ងារប្រមូលចំណូលអនុវត្តមិនបានហ្មត់ចត់ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រាក់កាសសាធារណៈ ត្រូវទទួលខុសត្រូវតាមកម្រិតនៃបទល្មើស"។

តាមរយៈការចុះសង្កេតនៅស្ថានីយត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងការសាកសួរមន្ត្រីពាក់ព័ន្ធ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ទាំងស្ថានីយថ្នល់កែង និងស្ថានីយប្រាសាទ បានរក្សាសាច់ប្រាក់ដែលទទួលបានពីការពិន័យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅនឹងមន្ត្រីផ្ទាល់ ដោយពុំមានកន្លែង ឬទូរ

សុវត្ថិភាពសម្រាប់រក្សាទុកសាច់ប្រាក់នោះឱ្យបានត្រឹមត្រូវនោះទេ។ កត្តានេះអាចនាំឱ្យមានហានិភ័យខ្ពស់ដែលសាច់ប្រាក់អាចនឹងមានការបាត់បង់ដាយថាហេតុ។

ដូចនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន គួរណែនាំដល់ស្ថានីយត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ខាងលើ ឱ្យរៀបចំរក្សាសាច់ប្រាក់ដែលបានទទួលពីការពិន័យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព។

ក្រសួងសាធារណការ និងជញ្ជូន បានបញ្ជាក់ថា ដោយមានការផ្លាស់ប្តូរសមាសភាពរបស់ស្ថានីយ និងសម្ភារមួយចំនួន ដូចជា ទូដែកដែលប្រើប្រាស់កន្លងមកជាកម្មសិទ្ធិឯកជន។ បច្ចុប្បន្នលេខាធិការដ្ឋានបានរៀបចំស្នើថវិកាគម្រោងចំណាយលើសម្ភារមួយចំនួនជូនទៅដល់ស្ថានីយ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងសាច់ប្រាក់ និងរក្សាសាច់ប្រាក់ឱ្យមានសុវត្ថិភាព។

អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យលើវឌ្ឍនភាពជាបន្តទៀត។

**៣.១.៦.ភាពយឺតយ៉ាវក្នុងការបង់ភាគលាភសហគ្រាស**

អនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការបង្កើតគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ (គ.ប.ច) ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ចបានបញ្ជាក់ថា "គ.ប.ច ត្រូវបង់ប្រាក់ចំណេញពិតប្រាកដប្រចាំឆ្នាំចូលថវិការដ្ឋចំនួន៥០%"។ តាមការពិនិត្យលើកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកភាគលាភរបស់គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ បានរក្សាទុកប្រាក់ចំណេញដែលជាចំណែកថវិការដ្ឋរយៈពេល៨ខែ ទើបធ្វើការបង្វែរចូលរតនាគារជាតិ។ ភាពយឺតយ៉ាវក្នុងការបង់ភាគលាភនេះ អាចធ្វើឱ្យរដ្ឋខ្វះថវិកាបើកផ្តល់។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយឱ្យធ្វើការបង់ភាគលាភចូលថវិការដ្ឋឱ្យបានទាន់ពេលទៅតាមអនុក្រឹត្យ។

ករណីនេះ គ្រឹះស្ថានបោះពុម្ពចែកផ្សាយ បានធ្វើការបំភ្លឺថា ជារៀងរាល់ឆ្នាំ សហគ្រាសបានលក់កម្មសិទ្ធិស្នាដៃសៀវភៅសិក្សាគោលជូនក្រសួងអប់រំ យុវជន និងកីឡា ហើយការប្រគល់-ទទួលធ្វើឡើងក្នុងអំឡុងខែកក្កដា ឬខែសីហានៃឆ្នាំនីមួយៗ។ ការចែងក្នុងកិច្ចសន្យាជាមួយក្រសួងត្រូវទូទាត់ឱ្យសហគ្រាសក្នុងរយៈពេល៤៥ថ្ងៃ ក្រោយការប្រគល់-ទទួល។ ប៉ុន្តែជាក់ស្តែង សហគ្រាសទទួលបានប្រាក់ពីការលក់កម្មសិទ្ធិស្នាដៃសៀវភៅសិក្សាគោលចុងឆ្នាំនីមួយៗ គឺមានការយឺតយ៉ាវប្រហែលជា ២ទៅ៣ខែ។

ចំពោះការលក់សៀវភៅសិក្សាគោល និងដឹកជញ្ជូនឱ្យក្រុមហ៊ុនដែលដេញថ្លៃឈ្នះ ហើយបានចុះកិច្ចសន្យាជាមួយក្រសួងអប់រំ យុវជន និងកីឡានោះមានការយឺតយ៉ាវដូចគ្នាដែរ។ ក្រសួងបានចុះកិច្ចសន្យាបន្តជាមួយក្រុមហ៊ុនដែលដេញថ្លៃឈ្នះនោះ ក្នុងអំឡុងខែសីហា ឬខែកញ្ញា នៃឆ្នាំនីមួយៗ។ ក្នុងនោះសហគ្រាសក៏បានចុះកិច្ចសន្យាបន្តជាមួយក្រុមហ៊ុនដែលដេញថ្លៃឈ្នះនោះដែរ ហើយរយៈពេលនៃការបោះពុម្ពមានតែ៩០ថ្ងៃ ទាំងការបោះពុម្ព

និងដឹកជញ្ជូន ដូច្នេះសហគ្រាសទទួលបានការទូទាត់ពីក្រុមហ៊ុនវិញ នៅចុងខែធ្នូនៃឆ្នាំនីមួយៗ ឬឆ្លងចូលឆ្នាំបន្ទាប់។

ចំពោះការលក់សៀវភៅសិក្សាគោលជូនអតិថិជនទូទៅ សហគ្រាសទទួលបានចំណូលតិច ឬច្រើនទៅតាមខែនីមួយៗ លក់ដាច់ ឬមិនដាច់ ហើយប្រាក់ដែលបានមកពីការលក់សៀវភៅសិក្សាគោលនោះ យកមកទុកដោះស្រាយសម្រាប់បើកប្រាក់បៀវត្សជូននិយោជក-និយោជិក និងចំណាយប្រតិបត្តិតិចតួចប្រចាំថ្ងៃ។ ជាទូទៅការលក់សៀវភៅសិក្សាគោលជូនអតិថិជនទូទៅដាច់ច្រើនពីខែកក្កដា ដល់ខែវិច្ឆិកានៃឆ្នាំនីមួយៗ។

សរុបមក ចំណូលទាំងបីប្រភេទរបស់សហគ្រាសទទួលបាននៅចុងឆ្នាំនីមួយៗ ហេតុដូច្នេះ សហគ្រាសពុំមានលទ្ធភាពបង់ប្រាក់ភាគលាភជូនរដ្ឋនៅអំឡុងពេលដើមឆ្នាំបានទេ។

អាជ្ញាធរសវនកម្មជាតិ បានឃើញការបំភ្លឺរបស់គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ។ អាជ្ញាធរសវនកម្មជាតិ សូមឱ្យគ្រឹះស្ថានបោះពុម្ពចែកផ្សាយអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យខាងលើឱ្យបានខ្ជាប់ខ្ជួន។

### ៣.១.៧.ការពុំទាន់បានរៀបចំបញ្ជីបេឡាសាច់ប្រាក់ចំណូល

សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យ រដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ចំណុច៣.១ បានបញ្ជាក់ថា "បញ្ជីបេឡាសាច់ប្រាក់ប្រើសម្រាប់កត់ត្រានូវចំនួនទឹកប្រាក់រដ្ឋទេយ្យចំណូលដែលបានទទួលពីអតិថិជន និងចំនួនទឹកប្រាក់ដែលបានចំណាយ និងចំនួនទឹកប្រាក់ដែលនៅសល់។ បញ្ជីបេឡាសាច់ប្រាក់រួមមាន បញ្ជីបេឡាសាច់ប្រាក់នៅធនាគារ (គំរូ០១) និងបញ្ជីបេឡាសាច់ប្រាក់នៅក្នុងដៃ(គំរូ០២)" ។

អាជ្ញាធរសវនកម្មជាតិ សង្កេតឃើញថា រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងនៅរដ្ឋបាលកណ្តាលនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ពុំទាន់បានរៀបចំបញ្ជីបេឡាសម្រាប់ធ្វើការតាមដានសាច់ប្រាក់នៅធនាគារ(គំរូ០១) និងរដ្ឋទេយ្យករចំណូល ហើយរដ្ឋទេយ្យករចំណូលរងរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ក៏មិនបានរៀបចំបញ្ជីបេឡាចំណូលសម្រាប់ធ្វើការតាមដានសាច់ប្រាក់ក្នុងដៃ(គំរូ០២)របស់អង្គភាពខ្លួននៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គួរធ្វើការណែនាំដល់រដ្ឋទេយ្យករចំណូលឱ្យធ្វើការរៀបចំបញ្ជីបេឡាតាមដានសាច់ប្រាក់នៅធនាគារ និងសាច់ប្រាក់ចំណូលក្នុងដៃឱ្យបានត្រឹមត្រូវស្របតាមសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងបេឡាសាច់ប្រាក់ចំណូលនៅធនាគារ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងបានបំភ្លឺថា ដោយសារកន្លងមកចំណូលជាក់ស្តែងតាមអង្គភាពជាអ្នកប្រមូលផ្ទាល់ ហើយអង្គភាពទាំងនោះមានរៀបចំបញ្ជីបេឡាតាមដានចំណូលតាមអង្គភាពប្រមូលចំណូលរៀងៗខ្លួន និងផ្ញើរបាយការណ៍ចំណូលមករដ្ឋទេយ្យករចំណូលជាប្រចាំខែ។ រដ្ឋទេយ្យករចំណូលធ្វើការតាមដានចំណូល

តាមរបាយការណ៍ប្រចាំខែទាំងនោះដោយមិនមានរៀបចំបញ្ជីបេឡានោះទេ។ ក្រសួងនឹងធ្វើការកែលម្អចំណុចខ្វះខាតទាំងនោះតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

**៣.១.៨.ការអនុវត្តការងាររបស់ភ្នាក់ងារប្រមូលចំណូលពុំមានលិខិតប្រកាសតែងតាំងជាផ្លូវការ**

តាមការធ្វើសម្ភាសន៍ជាមួយមន្ត្រីប្រមូលចំណូលផ្ទាល់ (ភ្នាក់ងារប្រមូលចំណូល) ពីសេវាសាធារណៈ និងពិនិត្យបញ្ជិកាគណនេយ្យរបស់មន្ត្រីដែលជាភ្នាក់ងារប្រមូលចំណូលរបស់អគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសក្នុងឆ្នាំ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ត្រីដែលជាភ្នាក់ងារប្រមូលចំណូលបានប្រមូលចំណូលពីសេវារៀបចំបែបបទហ្វឹកហ្វឺនកូនជាង និងសេវាចុះបញ្ជីគ្រឹះស្ថានសាធារណៈ ពុំមានលិខិតប្រកាសជាផ្លូវការដើម្បីបញ្ជាក់ថា ពួកគេជាភ្នាក់ងារប្រមូលចំណូលរបស់អគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនោះទេ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គួររៀបចំលិខិតប្រកាសតែងតាំងមន្ត្រីដែលជាភ្នាក់ងារប្រមូលចំណូលជាផ្លូវការឱ្យបានត្រឹមត្រូវ។

ចំពោះចំណុចនេះ ក្រសួងសូមទទួលយកអនុសាសន៍ខាងលើនេះ និងបានណែនាំឱ្យអគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស (នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា) រៀបចំប្រកាសតែងតាំងភ្នាក់ងារប្រមូលចំណូលជាផ្លូវការ។ ករណីនេះ ក្រសួងសូមបញ្ជាក់ថា ដោយសារមានការផ្លាស់ប្ដូរសមាសភាពភ្នាក់ងារប្រមូលចំណូលញឹកញាប់ ទើបមានការយឺតយ៉ាវក្នុងការរៀបចំលិខិតតែងតាំង។ បន្ទាប់ពីមានការណែនាំ អគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសបានរៀបចំលិខិតតែងតាំងផ្លូវការរួចហើយ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៩.ចំណូលការិយបរិច្ឆេទ២០១៩ កត់ត្រាជាចំណូលការិយបរិច្ឆេទ២០២០**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣ ស្ដីពីពន្ធលើប្រាក់ចំណេញ ត្រង់ផ្នែកទី១៣.២ កាតព្វកិច្ចគណនេយ្យ ចំណុច ខ.៥ បានចែងថា "សហគ្រាសត្រូវប្រើប្រាស់គណនេយ្យទ្វេភាគ និងផ្អែកលើមូលដ្ឋានគណនេយ្យបង្គរ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០១៩ ប្រៃសណីយ៍កម្ពុជា បានប្រមូលចំណូលសរុបចំនួន៣៩ ៤៨៤ ០០០រៀល ប៉ុន្តែបែរជាកត់ត្រាជាចំណូលឆ្នាំ២០២០។

អាស្រ័យហេតុនេះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងចំណូល ប្រៃសណីយ៍កម្ពុជាគួរកត់ត្រាចំណូលឱ្យបានត្រូវស្របតាមការិយបរិច្ឆេទ។

ឆ្លើយតបនឹងការលើកឡើង ប្រៃសណីយ៍កម្ពុជា សូមទទួលយកអនុសាសន៍ និងព្យាយាមកត់ត្រាតាមការិយបរិច្ឆេទឱ្យអស់លទ្ធភាព។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.១០. ភាពយឺតយ៉ាវក្នុងការបង់ចំណូលថ្លៃឈ្នួល**

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ផ្នែក៣ មាត្រា៤២ ត្រង់ទី៣បានចែងថា "ផុតរយៈពេល ០៦ខែ (ប្រាំមួយខែ) គិតចាប់ពីថ្ងៃបង់ប្រាក់៖ ក្នុងករណីអ្នកជាប់កាតព្វកិច្ចនៅតែមិនទូទាត់បំណុលរបស់ខ្លួនក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបញ្ជូនសំណុំរឿង និងឯកសារភស្តុតាងទាំងអស់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផ្តល់កិច្ចសហការ ដើម្បីចាត់វិធានការតឹងទារបំណុលតាមរយៈយន្តការក្រុមការងារអន្តរក្រសួងដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" និងបទបញ្ជាលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ ចែងថា "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដាក់ចេញវិធានការជាមួយក្រសួង-ស្ថាប័នសាមី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារបំណុលដែលផ្អែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋដូចជា៖ បញ្ឈប់ការអនុញ្ញាតនាំចេញ-នាំចូល បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាបណ្ណ និងក្នុងករណីការអនុវត្តតឹងទារបំណុលនេះ មិនមានប្រសិទ្ធភាព ក្រសួង-ស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅមានបំណុលត្រូវទារពីថ្លៃឈ្នួលលើការវិនិយោគស្តារជួល និងអភិវឌ្ឍន៍កៅស៊ូឡាបានសៀកខេត្តរតនគីរីសម្រាប់ឆ្នាំ២០១៩ ពីក្រុមហ៊ុនស៊ីហ្វារ៉ាប់បើរីលីមីតធីត មានចំនួន៦៣ ៧៨៥,៤៥ដុល្លារអាមេរិក និងប្រាក់ត្រូវពិន័យ២%ពីការខកខានក្នុងការបង់ថ្លៃឈ្នួលពីការវិនិយោគស្តារជួល និងអភិវឌ្ឍន៍កៅស៊ូឡាបានសៀកខេត្តរតនគីរីសម្រាប់ឆ្នាំ២០១៩ (គិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០)ចំនួន១៥ ៥២៣,៧៤ដុល្លារអាមេរិកនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរធ្វើការណែនាំដល់អគ្គនាយកដ្ឋានកៅស៊ូឱ្យមានវិធានការតឹងទារបំណុលថ្លៃឈ្នួលពីការវិនិយោគកៅស៊ូខាងលើ និងប្រាក់ពិន័យ២%ពីក្រុមហ៊ុនស៊ីហ្វារ៉ាប់បើរីលីមីតធីតខាងលើ ដើម្បីធ្វើការបង់ចូលថវិកាជាតិឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសូមធ្វើការបញ្ជាក់ថា ករណីក្រុមហ៊ុន ស៊ីហ្វារ៉ាប់បើរីលីមីធីត ពុំទាន់បានបង់ថ្លៃឈ្នួលចម្ការកៅស៊ូរដ្ឋ ឡាបានសៀកសម្រាប់ឆ្នាំ២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានវិធានការជាបន្តបន្ទាប់ដោយបានចេញសេចក្តីជូនដំណឹងជូនទៅលោកស្រីអគ្គនាយិកា ក្រុមហ៊ុនស៊ីហ្វារ៉ាប់បើរីលីមីធីត

(យោងលិខិតលេខ៤០៨១ កសិក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩)។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជូនដំណឹងទៅលោកស្រីអគ្គនាយិកា ក្រុមហ៊ុនស៊្វីហ្វរ៉ាប់បើរលីមីធីត ជាថ្មីម្តងទៀត (លិខិតលេខ៥៤២ អក.រន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០) ដើម្បីឱ្យក្រុមហ៊ុនស៊្វីហ្វរ៉ាប់បើរលីមីធីត បំពេញកាតព្វកិច្ចបង់ប្រាក់ឈ្នួលចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគិរី ។

ផ្អែកលើការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការជំរុញ និងចាត់វិធានការតឹងទារបំណុលថ្លៃឈ្នួលវិនិយោគកៅស៊ូខាងលើ និងប្រាក់ពិន័យ២%ពីក្រុមហ៊ុនស៊្វីហ្វរ៉ាប់បើលីមីតធីតខាងលើ ដើម្បីធ្វើការបង់ចូលថវិកាជាតិឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

**៣.១.១១.ភាពយឺតយ៉ាវក្នុងការទូទាត់ប្រតិបត្តិការចំណាយ**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ត្រង់មាត្រា១១ បានចែងថា“ ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់ថ្ងៃទី៣១ ខែធ្នូ” និងប្រកាសលេខ១៥៨៩ សហវ.ប្រក ស្តីពីនីតិវិធី និងវិធាននៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ប្រការ២២បានកំណត់ថា “រាល់បេសកកម្មក្នុង និងក្រៅប្រទេស ដែលបានអនុវត្តក្នុងឆ្នាំនៅមិនទាន់បានស្នើសុំទូទាត់ ត្រូវបានអនុញ្ញាតឱ្យទូទាត់យ៉ាងយូរបំផុតត្រឹមត្រីមាសទី១នៃឆ្នាំបន្ទាប់ ដោយប្រើប្រាស់ឥណទានឆ្នាំថ្មី...”។

អាជ្ញាធរសវនកម្មជាតិ សង្កេតឃើញថា អង្គភាពថវិកានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៅមានភាពយឺតយ៉ាវក្នុងការប្រមូលឯកសារទូទាត់ប្រតិបត្តិការចំណាយប្រាក់បេសកកម្មក្រៅប្រទេសក្នុងឆ្នាំ២០១៨ ចំនួន១៣១ ៦៩៩ ៣៤០រៀល ដោយបានមកធ្វើការទូទាត់ឥណទានថវិកាចំណាយឆ្នាំ២០១៩ រហូតដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរធ្វើការប្រមូលសក្ខីបត្រទូទាត់ចំណាយថវិកាឱ្យបានទាន់ពេលវេលា ដើម្បីជៀសវាងការយកប្រតិបត្តិការចំណាយឆ្នាំចាស់មកធ្វើការទូទាត់ឆ្នាំថ្មីដែលនាំឱ្យប៉ះពាល់ដល់ឥណទានថវិកាសម្រាប់ចំណាយក្នុងឆ្នាំ និងធ្វើឱ្យប៉ះពាល់ការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាជាតិប្រចាំឆ្នាំ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសូមធ្វើការបញ្ជាក់ថា ចំពោះការអនុវត្តការងារជាក់ស្តែង ការទូទាត់មិនអាចធ្វើឡើងក្នុងឆ្នាំអនុវត្តបានទាំងអស់នោះទេ ដោយអាស្រ័យថវិកាមិនមានគ្រប់គ្រាន់ ការចុះបំពេញបេសកកម្មនៅក្រៅប្រទេសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅចុងឆ្នាំ។ ដូច្នេះការទូទាត់ដែលនៅសល់ក្នុងឆ្នាំ២០១៨ មិនខុសនីតិវិធីចំណាយនោះទេ ព្រោះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំគោលការណ៍ធានាចំណាយ និងក៏មានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចហើយដែរ។

ផ្អែកលើការបញ្ជាក់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១២.ការអនុវត្តចំណាយលើសឥណទានថវិកាប្រចាំឆ្នាំ

ព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រង់ផ្នែកទី២ មាត្រា២៩បានចែងថា "ថវិកាត្រូវតែមានតុល្យភាពរវាងចំណូល និងចំណាយ។ ចំណូល និងចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន។ ចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមាន ការឧបត្ថម្ភពីថវិការដ្ឋ ចំណូលផ្ទាល់ និងចំណូលផ្សេងៗ។ ចំណូល និងចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិការដ្ឋដែរ។ ចំណាយត្រូវឆ្លុះបញ្ចាំងនូវគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។ គ្រឹះស្ថានសាធារណៈរដ្ឋបាលមិនអាចបង្កើតលក្ខខណ្ឌដែលនាំឱ្យមានឱនភាពថវិកាឡើយក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានអនុវត្តចំណាយថវិកាប្រចាំឆ្នាំ២០១៩ របស់ខ្លួនលើសឥណទានថវិកាឧបត្ថម្ភធនបើកផ្តល់ពីរដ្ឋ និងចំណូលផ្ទាល់គ្រឹះស្ថានដែលបានទទួលក្នុងឆ្នាំ២០១៩។ ការចំណាយនេះធ្វើឱ្យមានឱនភាពថវិកាប្រចាំឆ្នាំ២០១៩របស់អង្គភាពថវិកាវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

ឯកតាគិតជារៀល

| ល.រ | កម្មវត្ថុ | ចំណូល | ចំណាយ | នៅសល់ |
|---|---|---|---|---|
| ១ | ឧបត្ថម្ភធនផ្តល់ជូន | ១ ៨៧០ ០០០ ០០០ | ១ ៨១៩ ៩២០ ០០០ | ៥០ ០៨០ ០០០ |
| ២ | ចំណូលផ្ទាល់គ្រឹះស្ថាន | ២ ១៨៩ ៩៥៩ ២៨៦ | ២ ៩៥២ ២៥២ ៣៧៩ | -៧៦២ ២៩៣ ០៩៣ |
| **សរុប** | | **៤ ០៥៩ ៩៥៩ ២៨៦** | **៤ ៧៧២ ១៧២ ៣៧៩** | **-៧១២ ២១៣ ០៩៣** |

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរធ្វើការណែនាំដល់អង្គភាពថវិកាវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឱ្យធ្វើការចំណាយឥណទានថវិកាប្រចាំឆ្នាំរបស់ខ្លួនឱ្យស្របទៅនឹងប្រភពឥណទានថវិកាដែលបានទទួលក្នុងឆ្នាំ ដើម្បីជៀសវាងការចំណាយលើសឥណទានថវិកាប្រចាំឆ្នាំដែលជាហេតុធ្វើឱ្យមានឱនភាពថវិកាប្រចាំឆ្នាំ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសូមធ្វើការបញ្ជាក់ថា ក្រសួងបានធ្វើការកែលម្អជាបន្តបន្ទាប់។

ផ្អែកតាមការបញ្ជាក់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៣.ការចំណាយ និងការទូទាត់ចំណាយពុំមានភ្ជាប់សក្ខីបត្រគ្រប់គ្រាន់

សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ ស្តីពីការកែលម្អនីតិវិធីអនុវត្តថវិកា ត្រង់ចំណុច៦បានចែងថា "កិច្ចជម្រះបញ្ជីនេះ ត្រូវធ្វើឡើងក្រោយ

ចំណាយទាំងឡាយរបស់រដ្ឋត្រូវបានបញ្ចប់ ព្រមជាមួយនឹងការបញ្ជាក់ពីភាពត្រឹមត្រូវលើគ្រប់សក្ខីបត្រ...”។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានអនុវត្តចំណាយថវិកាបុរេប្រទានកម្មវិធីខាងលើ ដោយពុំមានភ្ជាប់សក្ខីបត្រសម្រាប់ធ្វើការទូទាត់ចំណាយឱ្យបានគ្រប់គ្រាន់។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គួរធ្វើការចំណាយថវិកាកម្មវិធីដោយត្រូវភ្ជាប់សក្ខីបត្រចំណាយឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃតួលេខចំណាយ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមធ្វើការបញ្ជាក់ថា ដោយសារមន្ត្រីដែលទទួលបន្ទុកធ្វើការថតចម្លង ឬភ្ជាប់នូវសក្ខីបត្រចំណាយមិនបានគ្រប់គ្រាន់ជាមួយឯកសារគាំទ្រដល់ការចំណាយ និងឯកសារច្បាប់ដើមត្រូវបានបញ្ជូនទៅរតនាគារជាតិអស់ ទើបធ្វើឱ្យមានកង្វះខាតភ្ជាប់សក្ខីបត្រចំណាយឱ្យបានគ្រប់គ្រាន់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៤.ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃមិនទាន់មានលក្ខណសម្បត្តិស្របទៅនឹងកម្មវត្ថុនៃការដេញថ្លៃ

ប្រកាសលេខ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៨ វាក្យខណ្ឌ២បានចែងថា "ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកជាប់ពន្ធត្រូវមានបណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួន ស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់សេវាទាំងនោះ”។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃ និងពិគ្រោះថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាដែលមានផលរបរអាជីវកម្មក្នុងបណ្ណប៉ាតង់មិនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរធ្វើការណែនាំអង្គភាពលទ្ធកម្មឱ្យធ្វើការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់សេវានៃការអនុវត្តកិច្ចលទ្ធកម្ម។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការបញ្ជាក់ថា ដោយសារនៅ

ពេលក្រុមហ៊ុនដាក់ពាក្យចូលរួមដេញថ្លៃ ឬពិគ្រោះថ្លៃគឺស្ថិតក្នុងស្រោមសំបុត្របិទជិតនៅពេលបើកឯកសារដេញថ្លៃទើបដឹងថាមានក្រុមហ៊ុនមួយចំនួនខុសផលរបរ។ ដូចនេះក្រសួងនឹងធ្វើការកែលម្អនៅកំហុសឆ្គងនេះនៅឆ្នាំបន្ទាប់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវការអនុវត្តាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.១.១៥.សក្ខីបត្រទូទាត់ចំណាយពុំស្របទៅនឹងប្រតិបត្តិការជាក់ស្តែង**

ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ត្រង់ផ្នែកទី២ ប្រការ១៥ បានចែងថា "ជាគោលការណ៍ រដ្ឋទេយ្យករបុរេប្រទានត្រូវចំណាយជាសាច់ប្រាក់ដោយមានសក្ខីបត្របញ្ជាក់ត្រឹមត្រូវ..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាកម្មវិធីអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអនុវត្តចំណាយលើការរៀបចំសិក្ខាសាលា និងចំណាយបុរេប្រទានរៀបចំមហោស្រពភាពយន្តអន្តរជាតិលើកទី៩ ដោយបានចំណាយលើការរៀបចំទីតាំងអាហារ ការទិញផ្លែឈើ និងនំ មិនស្របទៅនឹងប្រតិបត្តិការជាក់ស្តែង។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គួរណែនាំអង្គភាពថវិកាខាងលើឱ្យធ្វើការចំណាយថវិកាខាងលើឱ្យស្របទៅនឹងសកម្មភាពជាក់ស្តែង ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការអនុវត្តចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមធ្វើការបញ្ជាក់ថា វាជាកំហុសរបស់មន្ត្រីទទួលបន្ទុកដែលមិនបានពិនិត្យឱ្យបានច្បាស់លាស់ និងភ្ជាប់ឯកសារជាក់ស្តែងដោយសារកម្មវិធីសិក្ខាសាលាត្រូវបានផ្លាស់ប្តូរដែលធ្វើឱ្យអ្នកទទួលបន្ទុកការងារមិនបានភ្ជាប់ឯកសារ ឬបញ្ជាក់ពីថ្ងៃខែផ្លាស់ប្តូរសិក្ខាសាលាទើបធ្វើឱ្យមានសក្ខីបត្រចំណាយលើអាហារខុសទៅនឹងកម្មវិធីសិក្ខាសាលាជាក់ស្តែង។ ក្រសួងនឹងព្យាយាមកែលម្អចំណុចខ្វះខាតទាំងនេះតាមអនុសាសន៍។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

**៣.១.១៦.ភាពយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយថវិកាឆ្នាំ២០១៩សម្រាប់ទំនិញចាំបាច់**

សារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ទំនិញ និងសេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា ត្រង់ចំណុចទី១ បានចែងថា "ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពថវិកា និងអង្គភាពដទៃទៀតត្រូវរៀបចំគម្រោង និងសុំធានាចំណាយថវិកាឆ្នាំបន្ទាប់(ឆ្នាំN+1) សម្រាប់ការទិញទំនិញ និងសេវាកម្មចាំបាច់ និងមានលក្ខណៈជាប្រចាំមួយចំនួនរួមមានជាអាទិ៍៖ សម្ភារការិយាល័យ ប្រេងឥន្ធនៈ... មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តនៅក្នុងត្រីមាសទី៤ នៃឆ្នាំN"។

តាមការពិនិត្យឯកសារសំណើសុំធានាចំណាយថវិកាឆ្នាំ២០១៩ សម្រាប់ការទិញសម្ភារការិយាល័យ និងប្រេងឥន្ធនៈឆមាសទី១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងផែនការ ពុំបានរៀបចំស្នើសុំធានាចំណាយថវិកាឆ្នាំ២០១៩ សម្រាប់ទិញទំនិញចាំបាច់នៅក្នុងត្រីមាសទី៤នៃឆ្នាំ២០១៨ទេ។ ជាក់ស្តែង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំស្នើសុំធានាចំណាយថវិកាឆ្នាំ២០១៩ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ សម្រាប់ទិញប្រេងឥន្ធនៈឆមាសទី១ និងនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ សម្រាប់ទិញសម្ភារការិយាល័យ។ ចំណែកឯក្រសួងផែនការ បានរៀបចំស្នើសុំធានាចំណាយថវិកាឆ្នាំ២០១៩ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ សម្រាប់ទិញប្រេងឥន្ធនៈ និងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ សម្រាប់ទិញសម្ភារការិយាល័យ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងផែនការ គួររួសរាន់ស្នើសុំធានាចំណាយថវិកាសម្រាប់ចំណាយលើទំនិញចាំបាច់ ដូចជា ប្រេងឥន្ធនៈ និងសម្ភារការិយាល័យនៅក្នុងត្រីមាសទី៤នៃឆ្នាំN ដើម្បីអនុវត្តកិច្ចលទ្ធកម្មក្នុងឆ្នាំN+1ឱ្យបានទាន់ពេលវេលា។

ឆ្លើយតបចំពោះចំណុចនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងផែនការសូមឯកភាព និងខិតខំពង្រឹងការរៀបចំគម្រោង ដើម្បីធានាបានប្រសិទ្ធភាពនៃកំណើរការការងារនេះ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.១៧.ការចំណាយ និងកត់ត្រាចំណាយពុំទាន់ស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ**

ប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានកំណត់ដូចតទៅ៖

- គណនី និងអនុគណនី៦០០៥១ បានកំណត់ពីការចំណាយលើការទិញសម្ភារ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ដូចជា៖ ដំបងឆក់ របាំងការពារផ្សែង ទូរទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង ម៉ាស៊ីនបូមទឹក បំពង់ពន្លត់អគ្គីភ័យ អាគុយ ឧបករណ៍បំពងសម្លេង ។ល។
- គណនី អនុគណនី៦០០៥២ បានកំណត់ពីការចំណាយលើការទិញគ្រឿងសង្ហារឹម ដូចជា៖ តុ ទូដាក់ឯកសារ សាឡុង កៅអី ។ល។
- គណនី និងអនុគណនី៦០០៥៣ បានកំណត់ពីការចំណាយលើការទិញសម្ភារប្រើប្រាស់ដូចជា៖ សម្ភារកីឡាគ្រប់ប្រភេទ ថ្មពិលគ្រប់ប្រភេទ ហ្វីលថត(អង្គចងចាំ) កាសែតថតសំលេង កាសែតវីដេអូ ញញួរ សោរចាក់ ម៉ាស៊ីនច្រោះឬខ្លួង ម៉ាស៊ីនខាត់ ចប កង់កៅស៊ូ រណា រាំងនន ។ល។

- គណនី និងអនុគណនី៦០០៥៥ បានកំណត់ពីការចំណាយលើការទិញសម្ភារ និងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យាដូចជា៖ កុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនថត ទូរស័ព្ទ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនស្កេន។ល។
- គណនី និងអនុគណនី៦៥០២២ បានកំណត់ពីការចំណាយលើការឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម ដូចជា៖ គណៈកម្មាធិការជាតិសិទ្ធិមនុស្សកម្ពុជា អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គណៈកម្មាធិការជាតិអេស្កាប់ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ គណៈកម្មការស្រាវជ្រាវរុករកអដ្ឋិធាតុជនជាតិអាមេរិក និងកងទ័ពវៀតណាមដែលបាត់ខ្លួននៅកម្ពុជា ។ល។
- គណនី និងអនុគណនី៦៥០៣២ បានកំណត់ពីការចំណាយលើការឧបត្ថម្ភធនមិនមែនអចលកម្ម និងមិនមែនហិរញ្ញវត្ថុដល់អង្គភាពសាធារណៈមានលក្ខណៈរដ្ឋបាលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួង មានដូចជា៖ បេឡាជាតិអតីតយុទ្ធជន បេឡាជាតិរបបសន្តិសុខសង្គម មូលនិធិជនពិការ អាជ្ញាធរអប្សរា សាកលវិទ្យាល័យ វិទ្យាស្ថាន-មន្ទីរពេទ្យ ។ល។
- អនុគណនី៦១១០២ បានកំណត់ពីការចំណាយដែលពាក់ព័ន្ធនឹងការទទួលភ្ញៀវបរទេស ដូចជា៖ តែ កាហ្វេ ទឹកក្រូច ស្ករ នំ ផ្លែឈើ ។ល។ និងចំណាយផ្សេងៗទៀត ដែលទាក់ទងនឹងការរៀបចំពិធីជប់លៀង ក្នុងការទទួលភ្ញៀវ លើកលែងតែចំណាយលើសោហ៊ុយបេសកកម្មក្រៅប្រទេសដែលត្រូវកត់ត្រាចូលក្នុងគណនីលេខ៦១១៣។
- អនុគណនី៦១១០៣ បានកំណត់ពីការចំណាយលើការប្រជុំ សិក្ខាសាលា សម្ពោធសមិទ្ធផល សន្និសីទ សន្និបាត ដូចជា៖ ការរៀបចំឯកសារ និងសម្ភារៈតូចតាច ការជួលទីតាំងនិងការរៀបចំទីកន្លែង អាហារ ការឧបត្ថម្ភគ្រូឧទ្ទេស និងអ្នកសម្របសម្រួល សន្តិសុខ និងចំណាយផ្សេងៗ។ ករណីសិក្ខាសាលាដែលតម្រូវឱ្យមានបេសកកម្មត្រូវប្រើគណនី៦១១២ សម្រាប់ទូទាត់ចំណាយសោហ៊ុយបេសកកម្មក្នុងប្រទេស និងគណនី៦១១៣ សម្រាប់ទូទាត់ចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេស។ ចំណាយលើការប្រជុំ សិក្ខាសាលា សម្ពោធសមិទ្ធផល សន្និសីទ សន្និបាត ដូចជា៖ ឯកសារ សម្ភារៈរៀបចំទីតាំង អាហារ សន្តិសុខ និងការឧបត្ថម្ភផ្សេងៗ។

តាមការពិនិត្យ និងធ្វើតេស្តលើអាណត្តិបើកប្រាក់នៃគម្រោងលទ្ធកម្មចំនួន០៦ នៃគម្រោងសរុបចំនួន៣៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **អាជ្ញាធរសវនកម្ម**ជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៩ ក្រសួងបានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយធ្វើការកត់ត្រាការចំណាយពុំទាន់ស្របទៅនឹងចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាល

ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានចំនួនទឹកប្រាក់ ៩៨៤ ២២៨ ០០០រៀល។ តាមការពិនិត្យអាណត្តិបើកប្រាក់ក្នុងរបាយការណ៍ចំណាយ និងសក្ខីបត្រនៃការចំណាយលើសិក្ខាសាលារបស់ក្រសួងផែនការ ឃើញថា ក្រសួងបានអនុវត្តការចំណាយលើសិក្ខាសាលាចំនួន០៣ ដែលមានទឹកប្រាក់ចំនួន២៥ ០៣៨ ០០០ រៀល ដោយបានកត់ត្រាក្នុងអនុគណនី ៦១១០៣ ក្នុងនោះ ក្រសួងបានចំណាយលើពីធីជប់លៀងមានទឹកប្រាក់ចំនួន៨ ២៦៨ ០០០ រៀល ដែលចំណាយនេះគួរកត់ត្រានៅក្នុងអនុគណនី៦១១០២។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងផែនការ គួរធ្វើការកត់ត្រាចំណាយឱ្យបានត្រឹមត្រូវស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ។

ចំពោះចំណុចខាងលើ ក្រសួងសូមទទួលយកអនុសាសន៍ខាងលើនេះ និងលើកទិសដៅអនុវត្តនៅឆ្នាំបន្ទាប់ឱ្យបានត្រឹមត្រូវស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការកត់ត្រា។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.១៨.ការបំបែកគម្រោងលទ្ធកម្មសាធារណៈ**

សារាចរណែនាំលេខ០០៧ សហវ.សរណន ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី៣ "មិនអនុញ្ញាតឱ្យមានការសម្របសម្រួលណាមួយ ដើម្បីបំបែក ឬអង្គន់គម្រោងធានាចំណាយឱ្យទៅជាគម្រោងតូចៗតម្រូវតាមកម្រិតទឹកប្រាក់ដែលបានប្រគល់សម្រេចក្នុងការអនុវត្តកិច្ចលទ្ធកម្មឡើយ។ ករណីមានការបំបែក ឬអង្គន់ធានាចំណាយលើមុខសញ្ញាតែមួយនោះ បុគ្គល ឬស្ថាប័នដែលមានសមត្ថកិច្ចត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន"។

តាមការពិនិត្យលើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ២០១៩ និងសំណុំឯកសារគម្រោងលទ្ធកម្មនីមួយៗ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងផែនការបានអនុវត្តកិច្ចលទ្ធកម្មចំនួន១៣ មានទឹកប្រាក់សរុបចំនួន៧ ១៧៥ ១៥០ ០០០រៀល ក្នុងនោះក្រសួងបានអនុវត្តកិច្ចលទ្ធកម្មចំនួន០៦គម្រោង ដែលមានទឹកប្រាក់ចំនួន១ ៦៥២ ០៨០ ០០០រៀល ដោយបានបំបែកគម្រោងលទ្ធកម្មដែលមានយថាប្រភេទដូចគ្នាឱ្យទៅជាគម្រោងតូចៗ។

អាស្រ័យហេតុនេះ ក្រសួងផែនការ គួរធ្វើការណែនាំអង្គភាពលទ្ធកម្មឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងផែនការឯកភាពចំពោះអនុសាសន៍នេះ និងលើកទិសដៅអនុវត្តឱ្យមានប្រសិទ្ធភាពនៅឆ្នាំបន្ទាប់។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១៩.ការចុះកិច្ចសន្យាពុំបានតម្រូវឱ្យអ្នកផ្គត់ផ្គង់បំពេញបែបបទចុះបញ្ជីធ្វើអាជីវកម្មយានយន្ត

អនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រង់ជំពូក២ មាត្រា៥ បានចែងថា "ក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង មានសមត្ថកិច្ចក្នុងការគ្រប់គ្រងចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងកែច្នៃដំឡើងយានយន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា....."។

ប្រកាសលេខ៣២៥ សហវ ប្រក.ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់ ត្រង់ចំណុចសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ សម្រាប់ការផ្គត់ផ្គង់ទំនិញ បានចែងថា "ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាងបង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួនដូចខាងក្រោម៖

- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់
- បណ្ណប៉ាតង់ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់
- ច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម ចេញដោយក្រសួងជំនាញពាក់ព័ន្ធ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអ្នកផ្គត់ផ្គង់ទំនិញ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់
- ប៉ាន់គំរូ ឬកាតាឡុក (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព"ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន០៣ច្បាប់

តាមការពិនិត្យសំណុំឯកសារលទ្ធកម្មសេវាកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងការិយបរិច្ឆេទ២០១៩ ក្រសួងកិច្ចការនារី បានចុះកិច្ចសន្យាស្តីពីការងារជួសជុលរថយន្ត ចំនួន៣៤គ្រឿង ដែលមានកិច្ចសន្យាលេខ០៦៣ កកន/លក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ទឹកប្រាក់សរុបចំនួន១៩៩ ១៧០ ០០០រៀល ដោយសំណុំឯកសារលទ្ធកម្មទាំងនេះ ពុំបានភ្ជាប់ឯកសារលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងកែច្នៃដំឡើងយានយន្តចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនឱ្យបានត្រឹមត្រូវឡើយ។

ក្រសួងសាធារណការ នឹងដឹកជញ្ជូនមិនទាន់បានឆ្លើយបំភ្លឺ។

### ៣.១.២០.ការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្ម

សារាចរណែនាំលេខ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវប្រមូលផ្តុំគម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងអស់កត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។ រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយណាដែលមិនបានកត់ត្រានៅក្នុងផែនការលទ្ធកម្មមិនអនុញ្ញាតឱ្យស៊ុំ ឬផ្តល់ការធានាចំណាយឡើយ។

តាមការពិនិត្យផែនការលទ្ធកម្ម និងរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មរបស់អង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មបានអនុវត្តកិច្ចលទ្ធកម្មលើសមួយគម្រោងប្រចាំឆ្នាំ។

ករណីនេះ នាំឱ្យការរៀបចំផែនការលទ្ធកម្មពុំទាន់ត្រឹមត្រូវ និងមិនស្របតាមសង្គតិភាពថវិកាដែលបានលើក។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពលទ្ធកម្មឱ្យអនុវត្តកិច្ចលទ្ធកម្មស្របតាមផែនការប្រចាំឆ្នាំដែលបានលើកឡើងឱ្យបានត្រឹមត្រូវ។

ឆ្លើយតបទៅនឹងបញ្ហាខាងលើ ក្រសួងទទួលយកអនុសាសន៍សម្រាប់ធ្វើការកែលម្អនាឆ្នាំក្រោយៗទៀត។

អាជ្ញាធរសវនកម្មជាតិ នឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២១.ការចុះកិច្ចសន្យាសាងសង់ជាមួយក្រុមហ៊ុនដែលពុំទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់

ប្រកាសលេខ៣៨១ សហវ ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្ម (ការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ) និងសេចក្តីណែនាំលេខ០១៣ សហវ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ បានកំណត់ថា "អ្នកទទួលការសាងសង់ដែលបានចុះបញ្ជីរួច អាចមានសិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ តាមតម្លៃគម្រោងដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ចំណាត់ប្រភេទ | តម្លៃគម្រោង |
|---|---|
| ប្រភេទតូច | តិចជាង ៥០០លានរៀល |
| ប្រភេទមធ្យម | មិនលើសពី៣ ០០០លានរៀល |
| ប្រភេទធំ | មិនកំណត់ |

តាមការពិនិត្យឯកសារកិច្ចលទ្ធកម្មរបស់អង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មបានធ្វើការចរចាថ្លៃ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុន អ៊ីឡាយអិន ឌីហ្សាញ អេន ខនស្ត្រាក់សិន ឯ.ក ស្តីពីការជួសជុល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធអប់រំ ដែលមានទឹកប្រាក់ចំនួន៨២៩

លានរៀល ដោយក្រុមហ៊ុននេះមិនមានលក្ខណៈសម្បត្តិពេញលេញនៅឡើយ ដូចជា វិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់ហួសសុពលភាព និងវិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ប្រភេទតូច។

ករណីនេះ បណ្តាលឱ្យការអនុវត្តវិធាន និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈពុំមានតម្លាភាព។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពលទ្ធកម្មឱ្យអនុវត្តតាមប្រកាស និងសេចក្តីណែនាំខាងលើឱ្យបានខ្ជាប់ខ្ជួន។

ឆ្លើយតបទៅនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានបំភ្លឺថា៖

- អង្គភាពថវិកាមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មិនបានបញ្ជូនតម្រូវការផ្គត់ផ្គង់មកអង្គភាពលទ្ធកម្មសម្រាប់បញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំទេ។
- អង្គភាពថវិកាមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា បានធ្វើការស្នើសុំគោលការណ៍ធានាចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសាមីអង្គភាពផ្ទាល់ តាមរយៈលិខិតលេខ៣៤៣៥ អយក.ហវ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់គោលការណ៍ធានាចំណាយ ផ្អែកតាមលិខិតលេខ១០៣៤២ សហវ.អថ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ និងបានបញ្ជាក់ថា "ដោយត្រូវអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន"។ បន្ទាប់មកអង្គភាពថវិកាមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡាបានផ្តល់លិខិតគោលការណ៍ធានាចំណាយមកអង្គភាពលទ្ធកម្ម ដើម្បីស្នើសុំឱ្យអនុវត្តនីតិវិធីលទ្ធកម្ម។
- យោងតាមប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ត្រង់ជំពូកទី៨ ប្រការ៣១ "ការកែតម្រូវផែនការលទ្ធកម្មត្រូវបានឈប់ទទួលពិនិត្យត្រឹមថ្ងៃទី៣១ ខែតុលា នៃឆ្នាំអនុវត្តថវិកា"
- ផ្អែកតាមកាលបរិច្ឆេទកំណត់នេះ អង្គភាពលទ្ធកម្មពុំអាចស្នើសុំរៀបចំផែនការកែតម្រូវឡើយ ហើយអង្គភាពលទ្ធកម្មក៏បានជម្រាបជូនគណៈកម្មាធិការលទ្ធកម្មបានជ្រាបថា គម្រោងនេះគឺមិនមាននៅក្នុងផែនការលទ្ធកម្មទេ។

អាជ្ញាធរសវនកម្មជាតិ នឹងបន្តតាមដាននូវវឌ្ឍនភាពបន្តទៀត។

### ៣.១.២២.កង្វះខាតក្នុងការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់

ប្រកាសលេខ៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្ម ស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងសារាចរណែនាំលេខ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ការរៀបចំផែនការលទ្ធកម្ម ត្រូវធ្វើឡើងដោយចងជាឡូត៍ ឬជាកញ្ចប់លទ្ធកម្មចំពោះមុខសញ្ញាលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬប្រហាក់

ប្រហែលគ្នាស្របតាមតម្រូវការជាក់ស្តែងរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្មនីមួយៗ។ រាល់ការបំបែកគម្រោងលទ្ធកម្ម ទៅជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ឬតម្រូវតាមសិទ្ធិសម្រេចរបស់ខ្លួន ត្រូវជៀសវាងឱ្យបានដាច់ខាត"។

តាមការពិនិត្យសំណុំឯកសារលទ្ធកម្មក្នុងឆ្នាំ២០១៩ របស់សាកលវិទ្យាល័យស្វាយរៀង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មនៃសាកលវិទ្យាល័យស្វាយរៀង ពុំបានធ្វើការប្រមូលផ្តុំលើការងារជួសជុលដំបូលសាលា និងការចាក់សាបមុខអគារដាក់ជាកញ្ចប់លទ្ធកម្មដែលស្ថិតនៅក្នុងប្រភេទដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឱ្យការងារតែមួយ ដើម្បីធ្វើលទ្ធកម្មតែមួយលើកដូចមានក្នុងតារាងខាងក្រោម៖

| លរ. | ឈ្មោះក្រុមហ៊ុន | បរិយាយ | គណនី | កាលបរិច្ឆេទចុះកិច្ចសន្យា | ទឹកប្រាក់ |
|---|---|---|---|---|---|
| ១ | អិប ខេអិល ឌីវេឡុប មេន | ជួសជុលដំបូលអគារ | ៦១០៥២ | ២៣.០៥.១៩ | ៩៨៦ ៩៩០ ០០០ |
| ២ | អិម អេស វ៉ាយឯក. | ជួសជុលផ្លូវបេតុង | ៦១០៥៣ | ០១.១១.១៩ | ១៣៨ ៩០០ ០០០ |

ករណីនេះ នាំឱ្យការអនុវត្តប្រកាស និងសារាចរណែនាំខាងលើពុំទាន់មានប្រសិទ្ធភាព។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពលទ្ធកម្មនៃសាកលវិទ្យាល័យស្វាយរៀងឱ្យអនុវត្តតាមប្រកាស និងសារាចរណែនាំខាងលើឱ្យបានខ្ជាប់ខ្ជួន។

សាកលវិទ្យាល័យស្វាយរៀងបានទទួលយកអនុសាសន៍សវនកម្មនេះសម្រាប់អនុវត្តនាពេលខាងមុខមិនឱ្យមានការខុសឆ្គងទៀត។

អាជ្ញាធរសវនកម្មជាតិ បានឃើញការបំភ្លឺរបស់សាកលវិទ្យាល័យស្វាយរៀង។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពបន្តទៀត។

### ៣.១.២៣.ការបំបែកបណ្តុំចំណាយដើម្បីគេចវេះកិច្ចលទ្ធកម្ម

ប្រកាសលេខ៨២៩ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិបានបញ្ជាក់ថា "រជ្ជទេយ្យបុរេប្រទាន ត្រូវជៀសវាងដាច់ខាតនូវការបំបែកបណ្តុំចំណាយទៅតាមទីកន្លែង ឬគោលដៅចំណាយ ពេលវេលា និងទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលដៅគេចវេះការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ"។ ប្រកាសលេខ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មបានបញ្ជាក់ថា "ត្រូវកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវានៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចក្នុងតារាងឧបសម្ព័ន្ធទី១នៃប្រកាសនេះ សម្រាប់ទឹកប្រាក់ក្រោម ២០ លានរៀល ត្រូវអនុវត្តវិធីសាស្ត្រស្ទង់តម្លៃ ទឹកប្រាក់ចាប់ពី២០ លានរៀល ដល់ក្រោម១០០ លានរៀល អនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃ ចាប់ពី១០០ លានរៀល ដល់ក្រោម៥ ០០០ លានរៀល ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃក្នុងស្រុក និងទឹកប្រាក់ចាប់ពី៥ ០០០ លានរៀលឡើង ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃលក្ខណៈអន្តរជាតិ។

តាមការពិនិត្យអាណត្តិបើកប្រាក់ និងសក្ខីបត្រទូទាត់ការចំណាយថវិការដ្ឋទេយ្យបុរេប្រទានរបស់នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ នៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋាននេះបានចំណាយថវិការដ្ឋទេយ្យបុរេប្រទានកម្មវិធីចំនួន៥៣ ៦៣១ ៦០០ រៀល លើការងារជួសជុលអន្តេវាសិកដ្ឋានស្នាក់នៅរបស់និស្សិតដោយធ្វើការបំបែកបណ្ណមុខចំណាយផ្សេងៗ ក្នុងគោលដៅគេចវេះពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

ការបំបែកបណ្ណចំណាយ ដើម្បីគេចវេះកិច្ចលទ្ធកម្មនាំឱ្យការអនុវត្តតាមប្រកាសខាងលើពុំមានប្រសិទ្ធភាព។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពថវិកាក្រោមឱវាទអនុវត្តតាមប្រកាសខាងលើឱ្យបានខ្ជាប់ខ្ជួន។

នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ បានធ្វើការបំភ្លឺថា ដោយសារនិស្សិតបរទេសមានចំនួនច្រើន ហើយតម្រូវការជួសជុលមិនអាចរង់ចាំបានទៅតាមបន្ទប់នីមួយៗ តាមនីតិវិធីលទ្ធកម្មបានទេ ព្រោះពាក់ព័ន្ធនឹងផាសុខភាព និងការសិក្សារបស់និស្សិត ក៏ដូចជាការលើកកម្ពស់ទំនាក់ទំនងការទូតជាមួយប្រទេសជាមិត្ត និងកិត្តិយសរបស់ក្រសួង។

អាជ្ញាធរសវនកម្មជាតិ បានឃើញការបំភ្លឺរបស់នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពបន្តទៀត។

### ៣.១.២៤.ការចេញបណ្ណចំណាយពុំត្រឹមត្រូវតាមគណនេយ្យភាព

អនុក្រឹត្យលេខ១២៦ អនក្រ.ប្រក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៩ ត្រង់មាត្រា១ ចំណុចទី៤ បានបញ្ជាក់ថា "ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាបានឈប់សម្រាកការងារមួយថ្ងៃ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩ ជាទិវាសិទ្ធិនារីអន្តរជាតិ"។

តាមការពិនិត្យអាណត្តិទូទាត់ និងសក្ខីបត្រទូទាត់ថវិការដ្ឋទេយ្យបុរេប្រទាននៅអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពខាងលើបានធ្វើការចេញបណ្ណចំណាយនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩ ចំថ្ងៃឈប់សម្រាកទិវាសិទ្ធិនារីអន្តរជាតិ។

ករណីនេះ បណ្តាលឱ្យការកត់ត្រាចំណាយពុំត្រឹមត្រូវតាមគណនេយ្យភាព។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពថវិកាក្រោមឱវាទអនុវត្តតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលឱ្យបានខ្ជាប់ខ្ជួន និងមានគណនេយ្យភាព។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានទទួលយកនូវអនុសាសន៍។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពបន្តទៀត។

### ៣.១.២៥.ការចេញបណ្ណចំណាយពុំមានភ្ជាប់គោលការណ៍ចំណាយ

ប្រកាសលេខ៨២៩ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ បានបញ្ជាក់ថា "រាល់បណ្ណចំណាយត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ វិក្កយបត្រ ឬសក្ខីបត្រចំណាយ ដែលរជ្ជទេយ្យករបុរេប្រទានបានធ្វើការទូទាត់ដោយមានបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិ។

តាមការពិនិត្យលើអាណត្តិទូទាត់ និងសក្ខីបត្រចំណាយថវិការជ្ជទេយ្យបុរេប្រទានរបស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋាននេះ បានចេញបណ្ណចំណាយលើការទូទាត់ប្រាក់បេសកកម្មដែលមានទឹកប្រាក់សរុបចំនួន៦២៣ ២៦៤ ៦០០ រៀល ដោយពុំមានភ្ជាប់គោលការណ៍ចំណាយ និងរបាយការណ៍លទ្ធផលឱ្យបានគ្រប់ចំនួននោះឡើយ ។

ករណីនេះ អាចបណ្ដាលឱ្យការចំណាយថវិកាខាងលើពុំមានតម្លាភាព។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពថវិកាឱ្យអនុវត្តប្រកាសខាងលើឱ្យបានខ្ជាប់ខ្ជួន។

ចំពោះករណីនេះ នាយកដ្ឋានហិរញ្ញវត្ថុ បានបំភ្លឺថា ជានីតិវិធីរាល់ការអនុវត្តសកម្មភាពដូចជា សិក្ខាសាលា ការបណ្ដុះបណ្ដាល និងបេសកកម្ម ត្រូវមានគោលការណ៍អនុញ្ញាតឱ្យអនុវត្តសកម្មភាពជាមុនសិន ពេលចេញការចំណាយជូនអង្គភាពអនុវត្តសកម្មភាព ហើយនៅពេលទូទាត់ត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ និងរបាយការណ៍អនុវត្តសកម្មភាព ប៉ុន្តែករណីមួយចំនួននៅឆកល្វែង។ នាយកដ្ឋានហិរញ្ញវត្ថុនឹងពង្រឹងនូវចំណុចខ្វះខាតទាំងនេះ។

អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.២៦.ការទូទាត់ចំណាយថវិកាកម្មវិធីពុំស្របតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព

អនុក្រឹត្យលេខ៨២៦ អនក្រ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា បានបញ្ជាក់ថា "ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនូវអង្គភាពថវិកា ដែលជាអង្គភាពត្រូវបានទទួលអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ អាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន។ អង្គភាពថវិកាត្រូវមានសមត្ថភាពទទួលខុសត្រូវ និងធ្វើជាម្ចាស់ក្នុងការអនុវត្តសកម្មភាពការងារក្នុងការរៀបចំ និងគ្រប់គ្រងការអនុវត្តថវិកា ព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងការអនុវត្តថវិការបស់ខ្លួនស្របតាមគោលការណ៍ និងនីតិវិធីដែលកំណត់ដោយក្រសួងស្ថាប័ន"។

ប្រកាសលេខ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា បានបញ្ជាក់ថា "អង្គភាពថវិកាជាអង្គភាពដែលត្រូវបានទទួលអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារ ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន។ អង្គភាពថវិកាមានសិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពក្នុងការរៀបចំ និងគ្រប់គ្រងការអនុវត្តថវិកា ព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងអនុវត្តថវិការបស់ខ្លួនស្របតាមគោលការណ៍កំណត់ដោយក្រសួង ស្ថាប័ន និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

តាមការពិនិត្យលើអាណត្តិទូទាត់ និងសក្ខីបត្រចំណាយលើការជួសជុលអគាររបស់នាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា និងការទូទាត់ប្រាក់ម៉ោងបន្ថែមរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះដឹងទូទៅនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានសំណង់ បានយកថវិការបស់ខ្លួនក្នុងចង្កោមសកម្មភាពទី៥.៩.២ អនុកម្មវិធី៥.៩ កម្មវិធីទី៥ ទៅធ្វើការទូទាត់លើការជួសជុលជូនអគ្គនាយកដ្ឋានគោលនយោបាយនៅក្នុងអនុកម្មវិធី៥.១៤ នៃកម្មវិធីទី៥ ដែលមានទឹកប្រាក់ចំនួន៤ ៩៤០ ០០០រៀល រីឯនាយកដ្ឋានមធ្យមសិក្សាចំណេះដឹងទូទៅ បានយកថវិការបស់ខ្លួននៅក្នុងកម្មវិធីទី១ មកធ្វើការទូទាត់ប្រាក់ម៉ោងបន្ថែមដែលមានទឹកប្រាក់ចំនួន៨៩ ៦៤០ ០០០រៀល ជូនសាកលវិទ្យាល័យក្រចេះដែលស្ថិតនៅក្នុងកម្មវិធីទី២ ។

ករណីនេះ នាំឱ្យការចំណាយថវិកាកម្មវិធីរបស់ខ្លួនពុំអាចវាស់វែងបាន និងមិនអាចរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយជាអាទិភាពរបស់ស្ថាប័ន។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំនាយកដ្ឋានសំណង់ និងនាយកដ្ឋានមធ្យមសិក្សាចំណេះដឹងទូទៅឱ្យធ្វើការទូទាត់ចំណាយថវិកាសម្រាប់អង្គភាពរបស់ខ្លួន។

នាយកដ្ឋានទាំងពីរខាងលើនៃក្រសួងអប់រំ យុវជន និងកីឡា បានទទួលយកនូវអនុសាសន៍សវនកម្ម។

អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.២៧.ការគ្រោងថវិកាប្រាក់បេសកកម្មពុំសមស្របតាមគោលការណ៍

អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រង់ប្រការ៣ បានបញ្ជាក់ថា "ប្រាក់បេសកកម្ម រួមមាន ប្រាក់ហោប៉ៅ ប្រាក់ហូបចុក ប្រាក់ស្នាក់នៅ សោហ៊ុយធ្វើដំណើរ ប្រាក់ចំណាយលើការទិញវត្ថុអនុស្សាវរីយ៍ និងប្រាក់ចំណាយផ្សេងៗដែលត្រូវកំណត់ និងផ្តល់ជូនតាមប្រភេទបេសកកម្មនីមួយៗ"។

ប្រកាសលេខ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់

ប្រការ៤ បានបញ្ជាក់ថា "សោហ៊ុយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសត្រូវផ្តល់ជូនជាសាច់ប្រាក់ អាស្រ័យលើមធ្យោបាយធ្វើដំណើរ និងចម្ងាយនៃការធ្វើដំណើរក្នុងការបំពេញបេសកកម្មក្នុងប្រទេស"។

តាមការពិនិត្យលើផែនការថវិកាដើមឆ្នាំ២០១៩ និងសំណុំឯកសារទូទាត់ប្រាក់បេសកកម្មរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ពុំបានលើកគ្រោងថវិកាអនុគណនីលេខ៦១១២១ (សោហ៊ុយធ្វើដំណើរ) ក្នុងផែនការដើមឆ្នាំ ប៉ុន្តែមានថ្នាក់ដឹកនាំ និងមន្ត្រីរាជការមួយចំនួនរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ បានចុះបំពេញបេសកកម្មឆ្លងខេត្តដូចជាៈ បេសកកម្មទៅខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកោះកុង ខេត្តសៀមរាប និងខេត្តបាត់ដំបង។

កត្តានេះ នាំឱ្យការចុះបេសកកម្មរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ពុំទទួលបានថវិកាសម្រាប់ធ្វើដំណើរ។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពថវិកាមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញឱ្យអនុវត្តអនុក្រឹត្យ និងប្រកាសខាងលើឱ្យបានខ្ជាប់ខ្ជួន។

មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ បានឯកភាពលើចំណុចខ្វះខាតនេះ និងខិតខំរៀបចំការគ្រោងថវិកាឆ្នាំ សម្រាប់សោហ៊ុយធ្វើដំណើរឱ្យបានត្រឹមត្រូវសមស្របតាមគោលការណ៍របបកំណត់។

អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

**៣.១.២៨.ការអនុវត្តប្រព័ន្ធFMIS**

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានករណីមួយចំនួនដែលការអនុវត្តកត់ត្រានៅក្នុងដំណើរការក្នុងប្រព័ន្ធFMISទៅលើដំណើរការស្នើសុំធានាចំណាយ ឬទូទាត់ចំណាយមួយចំនួនរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមានជួបប្រទះមានភាពយឺតយ៉ាវជាងដំណើរការនៃការអនុវត្តកត់ត្រាឯកសារដោយដៃ (Hard Copy)។ ភាពយឺតយ៉ាវនៃដំណើរកត់ត្រាក្នុងប្រព័ន្ធFMISជាងដំណើរការអនុវត្តកត់ត្រាឯកសារដោយដៃនេះ បណ្តាលមកពីការពិនិត្យ និងអនុម័តបញ្ជូនការកត់ត្រាក្នុងប្រព័ន្ធFMISនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអគ្គនាយកដ្ឋានរតនាគារជាតិមានភាពយឺតយ៉ាវក្នុងការពិនិត្យ និងអនុម័តបញ្ជូនការកត់ត្រាក្នុងប្រព័ន្ធFMIS ក្រោយឯកសារកត់ត្រាដោយដៃ(Hard Copy)របស់ក្រសួង ទើបធ្វើឱ្យមន្ត្រីទទួលបន្ទុកដំណើរការឯកសាររបស់អង្គភាពក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការស្នើសុំធានាចំណាយ ឬស្នើសុំថវិកាចំណាយ និងទូទាត់ចំណាយមួយចំនួនរបស់ក្រសួងត្រូវរង់ចាំដំណើរការឯកសារកត់ត្រាក្នុងប្រព័ន្ធបញ្ជូន ឬអនុម័តរួចរាល់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអគ្គនាយកដ្ឋានរតនាគារជាតិរួចរាល់សិន ទើបអាចស្នើសុំធានាចំណាយ ឬបើកសាច់ប្រាក់ និងទូទាត់ឯកសារចំណាយបាន។ ភាពយឺតយ៉ាវក្នុងការកត់ត្រាក្នុងប្រព័ន្ធបញ្ជូន ឬអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអគ្គនាយកដ្ឋានរតនាគារជាតិក្រោយដំណើរការ

ឯកសារដោយដៃនេះធ្វើឱ្យដំណើការអនុវត្តចំណាយថវិកា និងទូទាត់ចំណាយថវិការបស់អង្គភាពក្រសួងមានភាពយឺតយ៉ាវក្នុងការស្នើសុំថវិកាចំណាយ និងទូទាត់ចំណាយ ព្រមទាំងមិនទាន់មានការឆ្លើយតបបានទាន់ពេលវេលា។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យពិនិត្យ និងកែសម្រួលនៅចំណុចមួយចំនួននៅក្នុងការកត់ត្រាអនុវត្តប្រព័ន្ធFMISរបស់ខ្លួនឱ្យមានភាពប្រសើរឡើង ដើម្បីឱ្យដំណើរការពិនិត្យ និងអនុម័តការកត់ត្រាក្នុងប្រព័ន្ធFMISមានភាពឆាប់រហ័ស ដើម្បីឱ្យដំណើរការអនុវត្តថវិកា និងទូទាត់ថវិកាចំណាយររបស់ក្រសួងបានទាន់ពេលវេលា និងឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួង។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសូមធ្វើការបញ្ជាក់ថា ករណីមួយចំនួនដែលការអនុវត្តប្រព័ន្ធFMIS មានភាពយឺតយ៉ាវជាងឯកសារទូទាត់ចំណាយ (Hard Copy) នេះបណ្តាលមកពីមានភាពយឺតយ៉ាវនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសារមន្ត្រីទទួលបន្ទុកឯកសារស្នើសុំបើកសាច់ប្រាក់ និងទូទាត់ចំណាយមិនបានយល់ដឹងពីប្រព័ន្ធFMIS រួចរាល់សិនពីមន្ត្រី ឬថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអគ្គនាយកដ្ឋានរតនាជាតិ ទើបអាចស្នើសុំបើកសាច់ប្រាក់ ឬទូទាត់ចំណាយបាន។

ផ្អែកតាមការបញ្ជាក់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២៩.កង្វះខាតក្នុងការកត់ត្រាបញ្ចូលសម្ភារ បរិក្ខារបច្ចេកទេសមួយចំនួនចូលទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះឆ្នាំ២០១៩

សារាចរណែនាំលេខ០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ចំណុច២ បានចែងថា "អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវកត់ត្រាទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួននូវអចលនវត្ថុ និងចលនវត្ថុទាំងអស់សម្រាប់ប្រើប្រាស់ជាទ្រព្យសម្បត្តិរដ្ឋ និងទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ..." ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានយកថវិការដ្ឋទេយ្យបុរេប្រទានកម្មវិធីចំណាយទិញសម្ភារព័ត៌មានវិទ្យា មិនមែនព័ត៌មានវិទ្យា និងគ្រឿងសង្ហារឹម ប៉ុន្តែសម្ភារៈទាំងនោះមិនទាន់បានកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះឆ្នាំ២០១៩ ឡើយ។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរណែនាំរដ្ឋបាលព្រៃឈើឱ្យកត់ត្រាសម្ភារៈដែលបានទិញចូលក្នុងតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ ឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួន ដើម្បីជៀសវាងការបាត់បង់ជាយថាហេតុ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសូមធ្វើការបញ្ជាក់ថា ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំតារាងប្រៀបធៀបកើនឡើង និង

ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំនីមួយៗ គឺជាភារកិច្ចរបស់អង្គភាព និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដែលជាអង្គភាពប្រើប្រាស់ផ្ទាល់ ត្រូវធ្វើការកត់ត្រានូវរាល់ទ្រព្យសម្បត្តិរដ្ឋស្ថិតក្រោមការកាន់កាប់របស់ខ្លួន និងត្រូវមានការចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់ពីតំណាងក្រសួងសាមី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សម្រាប់ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ(ឆ្នាំគោល)ឆ្នាំ២០១៩ រដ្ឋបាលព្រៃឈើបានរៀបចំ និងបានដាក់ជូនគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់រួចរាល់ផងដែរ។ ចំពោះទ្រព្យសម្បត្តិរដ្ឋខាងលើ គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងបានជំរុញឱ្យរដ្ឋបាលព្រៃឈើធ្វើការកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ឆ្នាំ២០១៩ រួចហើយ។

អាជ្ញាធរសវនកម្មជាតិ នឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៣០.ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍សមិទ្ធកម្មចំណាយថវិកាកម្មវិធី

ប្រកាសលេខ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ត្រង់ប្រការ២១ បានចែងថា "អង្គភាពថវិភាពរបស់ក្រសួង ស្ថាប័នថវិកាកម្មវិធីមានកាតព្វកិច្ចរៀបចំរបាយការណ៍ពីរប្រភេទគឺ (១) របាយការណ៍ហិរញ្ញវត្ថុ និង(២) របាយការណ៍សមិទ្ធកម្មទៅតាមគោលការណ៍ និងទម្រង់ដែលបានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី និងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ" និងប្រកាសលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល ត្រង់ជំពូក៤ មាត្រា២៥ បានកំណត់ថា "គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាលមានកាតព្វកិច្ចរៀបចំរបាយការណ៍បីប្រភេទគឺ របាយការណ៍អនុវត្តថវិកា របាយការណ៍សមិទ្ធកម្ម និងរបាយការណ៍ហិរញ្ញវត្ថុ។ របាយការណ៍សមិទ្ធកម្មជារបាយការណ៍ដែលឆ្លុះបញ្ចាំងអំពីលទ្ធផល និងវឌ្ឍនភាពនៃការអនុវត្តការងារតាមកម្មវិធី អនុកម្មវិធី ឬចង្កោមសកម្មភាព ដើម្បីរួមចំណែកសម្រេចគោលដៅ និងគោលនយោបាយរបស់ក្រសួង ស្ថាប័ន..." ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាកម្មវិធីទី១អគ្គនាយកដ្ឋានបេតិកភណ្ឌវប្បធម៌ អង្គភាពថវិកាកម្មវិធីទី២អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អង្គភាពថវិកាកម្មវិធីទី៣អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអង្គភាពថវិកាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅមានភាពយឺតយ៉ាវក្នុងការរៀបចំបូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំនៃការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ ដើម្បីឆ្លុះបញ្ចាំងអំពីលទ្ធផល និងវឌ្ឍនភាពនៃការអនុវត្តថវិកាកម្មវិធី អនុកម្មវិធី ឬចង្កោមសកម្មភាពប្រចាំឆ្នាំរបស់អង្គភាពថវិកា និងក្រសួងនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គួរធ្វើការណែនាំដល់អង្គភាពថវិកាកម្មវិធីទាំង០៣ និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈឱ្យធ្វើការរៀបចំបូកសរុបរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តចំណាយថវិកាកម្មវិធី អនុកម្មវិធី ឬចង្កោមសកម្មភាព ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផល និងវឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងបានបំភ្លឺថា នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុកំពុងជំរុញឱ្យអង្គភាពថវិកាកម្មវិធីរៀបចំរបាយការណ៍សមិទ្ធកម្មរបស់ខ្លួនឱ្យបានរួចរាល់ក្នុងអំឡុងខែមិថុនា ដើម្បីផ្ញើជូននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុធ្វើការបូកសរុប។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមការអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.១.៣១.ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ**

ប្រកាសលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ត្រង់ប្រការ៤ បានកំណត់ថា "ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ពុំទាន់រៀបចំបង្កើតទីតាំងច្រកចេញ ចូលតែមួយក្នុងការផ្តល់សេវាសាធារណៈលើវិស័យសិល្បៈ វប្បធម៌ និងភាពយន្តជូនអតិថិជនឱ្យស្របទៅនឹងប្រកាសខាងលើនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គួររៀបចំទីតាំងដែលមានភាពសមស្របណាមួយដើម្បីបង្កើតជាច្រកចេញ ចូលតែមួយក្នុងការផ្តល់សេវាសាធារណៈលើវិស័យវប្បធម៌ សិល្បៈ និងភាពយន្តជូនដល់អ្នកស្នើសុំសេវា។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងបានបំភ្លឺថា ដោយកន្លងមក ការប្រមូលចំណូលគឺអង្គភាព ឬនាយកដ្ឋានជាអ្នកផ្តល់សេវា ប៉ុន្តែបច្ចុប្បន្នក្រសួងកំពុងជំរុញ ដើម្បីរៀបចំបង្កើតនៅច្រកចេញ-ចូលតែមួយក្នុងការគ្រប់គ្រង និងផ្តល់សេវាសាធារណៈឱ្យមានភាពងាយស្រួល។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានការអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.១.៣២.ភាពយឺតយ៉ាវក្នុងការបូកសរុបចំណាយថវិកាកម្មវិធីទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព**

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីត្រង់ចំណុចទី១ វាក្យខណ្ឌ២ បានកំណត់ថា "ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត

តម្រូវឱ្យធ្វើរបាយការណ៍តាមគំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍នីមួយៗដូចមានភ្ជាប់នៅក្នុងតារាងឧបសម្ព័ន្ធទី១៦ដល់ទី២៣។ របាយការណ៍ហិរញ្ញវត្ថុទាំងអស់ត្រូវរៀបចំ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមការិយបរិច្ឆេទ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ) ដូចខាងក្រោម៖ របាយការណ៍ចំណាយប្រចាំឆ្នាំនៃការអនុវត្តថវិកាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមជំពូកចំណាយត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមករានៃឆ្នាំបន្ទាប់"។

តាមការពិនិត្យ និងផ្ទៀងផ្ទាត់ការគ្រប់គ្រងថវិកាកម្មវិធីឆ្នាំ២០១៩ ចំណាយថវិកាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពតាមជំពូករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេចក្តីព្រាងរបាយការណ៍សម្រេចទូទាត់ថវិកាថ្នាក់ជាតិសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅពុំទាន់បានបញ្ចប់ការរៀបចំបូកសរុបចំណាយថវិកាកម្មវិធីរបស់ខ្លួនទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំតាមគម្រោងចំណាយថវិកាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនៅឡើយ ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួររួសរាន់ធ្វើការរៀបចំបូកសរុបចំណាយថវិកាកម្មវិធីរបស់ខ្លួនទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំឱ្យបានទាន់ពេលវេលាស្របតាមប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសូមទទួលយកអនុសាសន៍ខាងលើនេះ និងខិតខំបូកសរុបចំណាយថវិកាកម្មវិធីតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំឱ្យទាន់ពេលវេលា ដើម្បីស្របតាមប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៣៣.ការអនុវត្តថវិកាកម្មវិធីពុំទាន់បានពេញលេញ**

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុច III.២ វាក្យខណ្ឌទី២ បានចែងថា "ដើម្បីឱ្យអង្គភាពថវិកាទទួលខុសត្រូវលើការអនុវត្តថវិកា និងការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ពិសេសដើម្បីបង្កើនគណនេយ្យភាពចំណាយឱ្យកាន់តែប្រសើរ រដ្ឋមន្ត្រីប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវវិភាជថវិកាជូនអង្គភាពថវិកាក្រោមឱវាទឱ្យបានទាន់ពេលវេលាស្របតាមការិយបរិច្ឆេទនៃឆ្នាំសារពើពន្ធនៃការអនុវត្តថវិកា"។

តាមការពិនិត្យរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំឆ្នាំ២០១៩ និងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ ស្តីពីការដាក់ឱ្យអនុវត្តអង្គ

ភាពថវិកាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៩ មាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ និងមន្ទីរផែនការរាជធានី-ខេត្តចំនួន២៥ទៀត ដែលបានអនុវត្តថវិកាកម្មវិធីបានពេញលេញ រីឯអង្គភាពថវិកាចំនួន០៤ (១.អគ្គនាយកដ្ឋានផែនការ ២.វិទ្យាស្ថានជាតិស្ថិតិ ៣.អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍន៍ និង៤.អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា) ពុំទាន់បានអនុវត្តថវិកានេះឱ្យបានពេញលេញនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងផែនការ គួរអនុវត្តថវិកាកម្មវិធីឱ្យបានពេញលេញស្របតាមប្រកាសខាងលើ។

ចំពោះចំណុចខាងលើ ក្រសួងផែនការសូមឯកភាព និងសូមជម្រាបជូនជ្រាបដែរថា ដោយអង្គភាពថវិកាចំនួន០៤ ដូចជា: ១-អគ្គនាយកដ្ឋានផែនការ ២-វិទ្យាស្ថានជាតិស្ថិតិ ៣-អគ្គលេខាធិការដ្ឋានប្រជាជននិងការអភវឌ្ឍន៍ និង៤-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពុំទាន់បានអនុវត្តថវិកាឱ្យបានពេញលេញ ដោយសារមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃអង្គភាពថវិកានីមួយៗនៅមានកម្រិត នាំឱ្យការរៀបចំគម្រោងចំណាយថវិកាតាមកម្មវិធីនីមួយៗពុំទាន់បានត្រឹមត្រូវពេញលេញគ្រប់ជ្រុងជ្រោយ មានសូចនាករសមិទ្ធកម្មច្បាស់លាស់។ ដូចនេះ ក្រសួងផែនការបាននិងកំពុងពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលមន្ត្រីនៃអង្គភាពថវិកាទាំង០៤ ដើម្បីអនុវត្តថវិកាកម្មវិធីឱ្យបានពេញលេញ។ ជារួម ក្រសួងផែនការសូមឯកភាពចំពោះអនុសាសន៍នេះ និងលើកទិសដៅអនុវត្តបន្តឱ្យមានប្រសិទ្ធភាព។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៣៤.ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃពុំទាន់ស្របនឹងកម្មវត្ថុនៃការដេញថ្លៃ**

ប្រកាសលេខ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៨ បានកំណត់ថា "ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកជាប់ពន្ធត្រូវមានបណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះ"។

តាមការពិនិត្យសំណុំឯកសារគម្រោងលទ្ធកម្មចំនួន០៤នៃគម្រោងសរុបចំនួន១៣ របស់ក្រសួងផែនការ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៩ ក្រុមហ៊ុនចូលរួមដេញថ្លៃដើម្បីធ្វើការផ្គត់ផ្គង់លើការបោះពុម្ព បានប្រើប្រាស់បណ្ណប៉ាតង់ពុំស្របនឹងកម្មវត្ថុនៃការដេញថ្លៃ។

អាស្រ័យហេតុនេះ អង្គភាពលទ្ធកម្មរបស់ក្រសួងផែនការ គួរអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសខាងលើ។

ចំពោះចំណុចនេះ ក្រសួងផែនការសូមឯកភាព និងលើកទិសដៅអនុវត្តនៅឆ្នាំបន្ទាប់។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.៣៥.ភាពយឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពសេវាសាធារណៈ

សេចក្ដីណែនាំលេខ១១ អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្ដីពីការអនុវត្តប្រកាសលេខ២៧៩២ អយក.ប្រក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ច្រកចេញចូលតែមួយ និងកន្លែងទទួលពាក្យបណ្ដឹងតវ៉ាលើការផ្ដល់សេវាសាធារណៈនៃក្រសួងអប់រំ យុវជន និងកីឡា (តួនាទីភារកិច្ចច្រកចេញចូលតែមួយ និងកន្លែងទទួលពាក្យបណ្ដឹងតវ៉ា) បានបញ្ជាក់ថា "ធ្វើបច្ចុប្បន្នភាពសេវាសាធារណៈវិស័យអប់រំ យុវជន និងកីឡា"។ លិខិតលេខ១៣០២ ស.ជ.ណ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការលើកលែងការតម្កល់ប្រាក់កក់លើការស្នើសុំបើកគ្រឹះស្ថានសិក្សា និងការចាត់ទុកជាមោឃភាពជាថ្មីនៃអាជ្ញាបណ្ណឡើងវិញ៥ឆ្នាំរបស់គ្រឹះស្ថានសិក្សាឯកជនគ្រប់កម្រិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

តាមការពិនិត្យឯកសារលើការផ្ដល់សេវាសាធារណៈរបស់ច្រកចេញចូលតែមួយលើការចេញអាជ្ញាបណ្ណគ្រឹះស្ថានសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមដំណាច់ខែមករា ឆ្នាំ២០២០ ច្រកចេញចូលតែមួយ មិនទាន់បានធ្វើការកែសម្រួលប្រកាសរួមលេខ១០១១ស្ដីពីការផ្ដល់សេវាសាធារណៈ ត្រង់ចំណុចបន្តអាជ្ញាបណ្ណឡើងវិញរបស់គ្រឹះស្ថានឱ្យស្របតាមលិខិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីនៅឡើយ។

កត្តានេះ នាំឱ្យការអនុវត្តសេចក្ដីណែនាំខាងលើពុំទាន់មានប្រសិទ្ធភាព។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពច្រកចេញ ចូលតែមួយធ្វើបច្ចុប្បន្នភាពលើការផ្ដល់សេវាសាធារណៈឱ្យស្របតាមការចង្អុលបង្ហាញរបស់ប្រមុខរាជរដ្ឋាភិបាល។

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការបំភ្លឺថា៖

- អនុវត្តតាមលិខិតលេខ១៣០២ សជណ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីពាក់ព័ន្ធនឹងការលើកលែងដាក់ប្រាក់តម្កល់របស់គ្រឹះស្ថានសិក្សាឯកជន ច្រកចេញ ចូលតែមួយបានចេញលិខិតជូនដំណឹងលេខ១៥៥ អយក.នក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ ដើម្បីជូនដំណឹងម្ចាស់គ្រឹះស្ថានឯកជនមកដកប្រាក់តម្កល់អប្បរមាវិញ។
- ក្នុងឆ្នាំ២០១៨ ច្រកចេញ ចូលតែមួយមមាញឹកក្នុងការរៀបចំលិខិតដកប្រាក់តម្កល់ជូនម្ចាស់គ្រឹះស្ថានសិក្សាវិញឱ្យបានទាន់ពេលដែលមានចំនួន៨៣សាលា ក្នុងចំណោម៩២សាលាដែលបានដាក់ប្រាក់តម្កល់ និងម្យ៉ាងទៀតជាពេលវេលាជាប់រវល់ការបោះឆ្នោតផងធ្វើឱ្យមានការខកខានក្នុងការធ្វើបច្ចុប្បន្នភាពសេវាសាធារណៈ។
- ក្នុងឆ្នាំ២០១៩ ច្រកចេញ ចូលតែមួយ បានរៀបចំដើម្បីកែសម្រួលប្រកាសរួមលេខ១០១១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ លើប្រភេទសេវាសាធារណៈ

កម្រៃសេវា។ ប៉ុន្តែទន្ទឹមនឹងនេះ នាយកដ្ឋានជំនាញមួយចំនួនបានស្នើសុំបញ្ចូលសេវាមួយចំនួនបន្ថែមទៀតដូចជា៖

- ប្តូរឈ្មោះគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន
- ប្តូរឈ្មោះគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន
- សេវាពាក់ព័ន្ធនឹងការងារអប់រំក្រៅប្រព័ន្ធ
- សេវាបង់សិទ្ធិប្រឡង
- សេវាបញ្ជាក់សញ្ញាបត្រកម្រិតសមមូលក្រៅប្រទេស
- សាលាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ

សេវាទាំងនេះ ត្រូវប្រជុំកម្រិតអន្តរនាយកដ្ឋាន ដើម្បីពិភាក្សាលើកម្រៃសេវា រយៈពេល និងទម្រង់បែបបទស្នើសុំ ដែលធ្វើឱ្យការកែសម្រួលសេវាមានភាពយឺតយ៉ាវ។

- ដោយសារស្ថានភាពនៃការរាតត្បាតនៃជំងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតលេខ១៦៩៨ អយក.នក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្អាកនីតិវិធីក្នុងការផ្តល់សេវា ធ្វើឱ្យផែនការនៃការរៀបចំប្រជុំត្រូវបានពន្យារពេល។
- ការកែសម្រួលប្រកាស១០១១ សហវ.ប្រក ក្រុមការងារច្រកចេញ ចូលតែមួយបាននិងកំពុងសុំគោលការណ៍ថ្នាក់ដឹកនាំក្រសួងពិនិត្យមុននឹងប្រជុំឆ្លងក្រុមការងារអន្តរក្រសួង (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ)។

អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.៣៦.ការចេញអាជ្ញាបណ្ណមិនស្របតាមកម្រិតសិក្សារបស់គ្រឹះស្ថានដែលអនុវត្តជាក់ស្តែង

ប្រកាសរួមលេខ១០១១ ចុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា និងរបាយការណ៍លទ្ធផលការងារច្រកចេញចូលតែមួយ និងកន្លែងទទួលពាក្យបណ្តឹងតវ៉ា នៃការផ្តល់សេវាអប់រំ យុវជន និងកីឡាប្រចាំឆ្នាំ២០១៩។

តាមការពិនិត្យឯកសារស្នើសុំអាជ្ញាបណ្ណបើកគ្រឹះស្ថានសិក្សាចំណេះដឹងទូទៅឯកជន សាលាចំណេះដឹងទូទៅមីគីវ៉េ រូបភាពអាជីវកម្មទីតាំងចុះនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ដែលបានបង្ហាញពីការលើកស្លាកសាលា "មត្តេយ្យ បឋម និងមធ្យមសិក្សា មីគីវ៉េ" និងរបាយការណ៍ស្តីពីការចុះពិនិត្យទីតាំង និងប្រមូលព័ត៌មានរបស់គ្រឹះស្ថានរបស់ក្រសួងអប់រំ យុវជន និងកីឡា ចុះនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ លើគ្រឹះស្ថានចំណេះដឹងទូទៅមីគីវ៉េ សាខាទី២៦ កម្មវិធីសិក្សាជាតិកម្រិត "មត្តេយ្យដល់មធ្យមសិក្សាទុតិយភូមិ" ដែលមានទីតាំងនៅផ្ទះលេខ ១៦៤-១៦៦ និង១៦៨ ផ្លូវ១៩ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងនៅតែចេញអាជ្ញាបណ្ណបើកគ្រឹះស្ថានសិក្សាចំណេះដឹងទូទៅឯកជន សាលាចំណេះទូទៅមីគីវ៉េ សាខាទី២៦ ចាប់ពីកម្រិតមត្តេយ្យសិក្សាដល់បឋមសិក្សា ដែល

មានទីតាំងនៅផ្ទះលេខ១៦៤-១៦៦ និង១៦៨ ផ្លូវ១៩ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយពុំសមស្របតាមការលើកស្លាកសាលាជាក់ស្តែង។

កត្តានេះ នាំឱ្យការអនុវត្តប្រកាសខាងលើពុំសមស្របត្រឹមត្រូវ។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំច្រកចេញចូលតែមួយអនុវត្តតាមប្រកាសរួមខាងលើឱ្យបានខ្ជាប់ខ្ជួន។

ក្រសួងអប់រំ យុវជន និងកីឡា បានបំភ្លឺថា សាលាមីគីវ៉េសាខាទី២៦ ដែលមានទីតាំងនៅផ្ទះលេខ១៦៤ ១៦៦ ផ្លូវ១៩ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ បានលើកស្លាក "មត្តេយ្យដល់បឋមសិក្សា"។ ករណីនេះ ក្រុមការងារ៖

- បានអញ្ជើញម្ចាស់គ្រឹះស្ថានសិក្សាចំណេះទូទៅមីគីវ៉េ មកណែនាំនិងផ្តល់នូវជម្រើសចំនួន២៖
    - ម្ចាស់គ្រឹះស្ថានសិក្សាចំណេះទូទៅមីគីវ៉េ ត្រូវកែតម្រូវស្លាកសាលាពីកម្រិត "មត្តេយ្យ ដល់ មធ្យមសិក្សា" មកកម្រិត "មត្តេយ្យ ដល់បឋមសិក្សា" ស្របតាមបេសកកម្មដែលបានស្នើសុំយ៉ាងយូរ១៥ថ្ងៃ ចាប់ពីថ្ងៃដែលបានប្រជុំ។
    - ម្ចាស់គ្រឹះស្ថានសិក្សាចំណេះទូទៅមីគីវ៉េ ត្រូវស្នើសុំតម្លើងកម្រិតដល់មធ្យមសិក្សា ករណីនេះ ម្ចាស់គ្រឹះស្ថានសិក្សាចំណេះទូទៅមីគីវ៉េបានស្នើសុំយកជម្រើស២ដោយស្នើសុំពាក្យ ដើម្បីបន្ថែមកម្រិតដល់មធ្យមសិក្សាស្របតាមស្លាកដែលបានលើក។
- ដោយសារស្ថានភាពនៃការរាលត្បាតនៃជំងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតលេខ១៦៩៨ អយក.នក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្អាកនីតិវិធី ក្នុងការរៀបចំប្រកាសទទួលស្គាល់ និងបង្កើតគ្រឹះស្ថានសិក្សាឯកជនគ្រប់កម្រិត គ្រប់ប្រភេទរបស់ច្រកចេញ ចូលតែមួយនៃក្រសួងអប់រំ យុវជន និងកីឡា ដូច្នេះនីតិវិធីក្នុងការរៀបចំប្រកាសទទួលស្គាល់គ្រឹះស្ថានសិក្សាចំណេះទូទៅមីគីវ៉េ ត្រូវបានពន្យារពេលរហូតដល់មានការណែនាំថ្មីពីការបន្តនីតិវិធីក្នុងការរៀបចំប្រកាសទទួលស្គាល់។
- ក្រុមការងារច្រកចេញ ចូលតែមួយ នឹងពង្រឹងយន្តការការងារ ជាពិសេសការពិនិត្យលើសំណុំឯកសារស្នើសុំ និងការចុះពិនិត្យទីតាំងរបស់គ្រឹះស្ថានសិក្សាឯកជន។

អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៣៧.ការអនុវត្តកិច្ចលទ្ធកម្មដោយអង្គភាពថវិកាដែលមិនមែនជាអង្គភាពលទ្ធកម្ម

អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម បានបញ្ជាក់ថា "អង្គភាពលទ្ធកម្មបំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម ដោយមានភារកិច្ចជាសារវ័ន្តដូចខាងក្រោម៖ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និង/ឬផែនការ

លទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់ ...រហូតដល់រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ" ។ សារាចរណែនាំលេខ០០២ សហវ .អលស ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវប្រមូលផ្តុំគម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងអស់កត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។ រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយណាដែលមិនបានកត់ត្រានៅក្នុងផែនការលទ្ធកម្មមិនអនុញ្ញាតឱ្យស្នើសុំ ឬផ្តល់ការធានាចំណាយឡើយ"។

តាមការពិនិត្យអាណត្តិទូទាត់ និងសំណុំឯកសារលទ្ធកម្មរបស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការអនុវត្តកិច្ចលទ្ធកម្មដោយអង្គភាពថវិកា (នាយកដ្ឋានហិរញ្ញវត្ថុ) ដែលមិនមែនជាអង្គភាពលទ្ធកម្ម មិនមានជំនាញតួនាទីភារកិច្ច មិនបានអញ្ជើញតំណាងអង្គភាពប្រឆាំងអំពើពុករលួយ និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចូលរួមបើកឯកសារដេញថ្លៃ ប្រគល់ទទួលទំនិញលើការផ្គត់ផ្គង់សម្ភារពិសោធន៍ផ្នែកអគ្គិសនី គ្រឿងអេឡិចត្រូនិច សម្ភារបរិក្ខារបច្ចេកទេស និងរថយន្តចំនួន០២គ្រឿង ដែលមានទឹកប្រាក់សរុបចំនួន៧ ០៦០ ០០០ ០០០រៀល។

កត្តានេះ នាំឱ្យការអនុវត្តកិច្ចលទ្ធកម្មពុំមានតម្លាភាព និងពុំត្រឹមត្រូវតាមនីតិវិធីលទ្ធកម្ម។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំនាយកដ្ឋានហិរញ្ញវត្ថុអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន។

នាយកដ្ឋានហិរញ្ញវត្ថុ បានធ្វើការបំភ្លឺថា នាយកដ្ឋានហិរញ្ញវត្ថុ គឺជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាយកដ្ឋានហិរញ្ញវត្ថុទទួលអនុវត្តរាល់កិច្ចការដែលថ្នាក់ដឹកនាំប្រគល់ជូន។

អាជ្ញាធរសវនកម្មជាតិ បានឃើញការបំភ្លឺរបស់ក្រសួងអប់រំ យុវជន និងកីឡា។ អាជ្ញាធរសវនកម្មជាតិ សូមឱ្យក្រសួងអនុវត្តឱ្យស្របតាមប្រកាសខាងលើ។

### ៣.១.៣៨.ការពុំបានកាត់ប្រាក់១០%ពីគម្រោង ដែលបានអនុវត្តដោយអង្គភាពរដ្ឋ

សារាចរណែនាំលេខ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ក្នុងករណីការងារទទួលអនុវត្តដោយអង្គភាពជំនាញរបស់រដ្ឋ ការទូទាត់ត្រូវរក្សាទឹកប្រាក់ចំនួន១០% នៃតម្លៃកិច្ចសន្យាសរុប ដើម្បីទុកជាការធានាគុណភាពជំនួសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យារហូតដល់ផុតរយៈពេលធានាគុណភាពទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់"។

តាមការពិនិត្យអាណត្តិបើកប្រាក់ និងសំណុំឯកសារលទ្ធកម្មរបស់នាយកដ្ឋានហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទ២០១៩ លើគម្រោងជួសជុលមជ្ឈមណ្ឌលយុវជននៅខេត្តសៀមរាប និងការពង្រីកទីធ្លាបរិវេណសាលាបឋមសិក្សាពញ្ញាហុក ដែលមានទឹកប្រាក់ចំនួន១ ០០០ ០០០ ០០០ រៀល និងការជួសជុលអគាររដ្ឋបាល គ្រឹះស្ថានសាធារណៈ (ខេត្តកំពង់ចាម និងទីលាន

បាល់ទាត់វិទ្យាល័យបឹងត្របែក) ដែលមានទឹកប្រាក់ចំនួន២ ៧៤០ ០០០ ០០០រៀល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានហិរញ្ញវត្ថុ បានចុះកិច្ចសន្យាជួសជុលជាមួយនាយកដ្ឋានសំណង់ដែលជាអង្គភាពរដ្ឋស្ថិតក្រោមអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា។ នាយកដ្ឋានហិរញ្ញវត្ថុ បានធ្វើការទូទាត់ទឹកប្រាក់ទាំងអស់ក្នុងកិច្ចសន្យាជូនដល់នាយកដ្ឋានសំណង់ ដោយពុំបានធ្វើការកាត់ទុកប្រាក់១០%នៃគម្រោងដែលគិតជាទឹកប្រាក់សរុបចំនួន៣៧៤ ០០០ ០០០រៀល ទុកជាការធានាគុណភាពសំណង់។

កត្តានេះ អាចនាំឱ្យមានហានិភ័យថវិកានៃការជួសជុលសំណង់ឡើងវិញក្នុងករណីសំណង់មានបញ្ហា។

ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំអង្គភាពថវិកាក្រោមឱវាទអនុវត្តតាមសារាចរណែនាំខាងលើឱ្យបានខ្ជាប់ខ្ជួន។

នាយកដ្ឋានហិរញ្ញវត្ថុ បានឯកភាពចំពោះការរកឃើញ និងពង្រឹងការអនុវត្តនូវចំណុចខ្វះខាតទាំងនេះ។

អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.៣៩.ការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង

អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ត្រង់ជំពូកទី៣ មាត្រា៧ បានចែងថា "មុខងារ និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុងមានដូចខាងក្រោម៖

- ពិនិត្យឡើងវិញលើមុខងារ សកម្មភាព កិច្ចប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព
- កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណវាស់វែងចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ
- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានទៅតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ បទបញ្ញាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើ

កិច្ចប្រតិបត្តិការ និងរបាយការណ៍។ ក្នុងករណីស្ថាប័ន ក្រសួង និងសហគ្រាស សាធារណៈ អនុវត្តពុំបានសមស្របដូចបានរៀបរាប់ខាងលើ ចាំបាច់សំណូមពរ ឱ្យមានការផ្លាស់ប្តូរ និងកែលម្អ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០១៩ នាយកដ្ឋាន សវនកម្មផ្ទៃក្នុងនៃប្រៃសណីយ៍កម្ពុជា បានអនុវត្តការងារសវនកម្មផ្ទៃក្នុងនៅនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស និងសាខាប្រៃសណីយ៍កម្ពុជាតាមបណ្តាខេត្តប៉ុណ្ណោះ ប៉ុន្តែនាយកដ្ឋាន សវនកម្មផ្ទៃក្នុង មិនបានចុះធ្វើសវនកម្មនៅតាមបណ្តានាយកដ្ឋានជំនាញផ្សេងៗទៀត មជ្ឈ មណ្ឌលព័ត៌មានវិទ្យា និងសាខាប្រៃសណីយ៍កម្ពុជារាជធានីភ្នំពេញឡើយ ។

ប្រៃសណីយ៍កម្ពុជា គួរណែនាំនាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តមុខងារសវនកម្ម ឱ្យបានពេញលេញ និងមានប្រសិទ្ធភាពខ្ពស់។

ឆ្លើយតបនឹងការលើកឡើង ប្រៃសណីយ៍កម្ពុជា នឹងជំរុញនាយកដ្ឋានសវនកម្មផ្ទៃ ក្នុង ដើម្បីអនុវត្តមុខងារសវនកម្មឱ្យបានពេញលេញ និងមានប្រសិទ្ធភាពខ្ពស់។

ប្រៃសណីយ៍កម្ពុជា បានឯកភាពតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្ម ជាតិ។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពបន្តទៀត។

**៣.១.៤០.ការប្រមូលបំណុលពន្ធដែលអ្នកជាប់ពន្ធសន្យាទូទាត់**

បំណុលពន្ធដារមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារអគ្គនាយកដ្ឋាន ពន្ធដារបានខិតខំប្រមូលពន្ធពីការធ្វេសប្រហែស និង/ឬការគេចវេសពន្ធរបស់អ្នកជាប់ពន្ធ។ ដើម្បីខិតខំប្រមូលបំណុលពន្ធនេះឱ្យបាន អគ្គនាយកដ្ឋានពន្ធដារបានចាត់វិធានការអនុញ្ញាត ឱ្យអ្នកជាប់ពន្ធទូទាត់បំណុលជាដំណាក់កាល។ តាមការធ្វើតេស្តនៅសាខាពន្ធដារខេត្ត និង ខណ្ឌចំនួន២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអ្នកជាប់ពន្ធចំនួន១៥៧ ទទួល បានការអនុញ្ញាតឱ្យទូទាត់បំណុលជាដំណាក់កាល ក្នុងនោះអ្នកជាប់ពន្ធចំនួន៩៤ បានទូទាត់ បំណុលពន្ធតាមការសន្យា ប៉ុន្តែអ្នកជាប់ពន្ធចំនួន៦៣ទៀត មិនបានទូទាត់បំណុលតាមការ សន្យា។

ការខកខានក្នុងការទូទាត់បំណុលតាមការសន្យា នាំឱ្យការប្រមូលបំណុលពន្ធពុំ ទាន់អស់លទ្ធភាព និងអាចឈានទៅដល់ការបាត់បង់បំណុលពន្ធជាយថាហេតុ។ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យមានវិធានការបន្ថែមទៀតចំពោះ អ្នកជាប់ពន្ធដែលមិនទូទាត់បំណុលពន្ធតាមការសន្យា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងទទួលយកអនុសាសន៍របស់អាជ្ញាធរ សវនកម្មជាតិ។ ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងណែនាំអង្គភាពពាក់ព័ន្ធត្រូវតាមដាន និងធ្វើលិខិតរំលឹកចំពោះអ្នកជាប់ពន្ធ ដែលខកខានពុំបានបង់បំណុលពន្ធតាមកិច្ចសន្យា ដោយ នឹងបន្តចាត់វិធានការផ្សេងៗទៅតាមច្បាប់ស្តីពីសារពើពន្ធចំពោះក្រុមហ៊ុន សហគ្រាស ដែល មិនទូទាត់បំណុលពន្ធទៅតាមកិច្ចសន្យា។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៤១.បំណុលត្រូវទារពីថ្លៃឈ្នួលឡូត៍នៃសាទ វិនិយោគកៅស៊ូ និងដីសម្បទានសេដ្ឋកិច្ច

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ផ្នែក៣ មាត្រា៤២ ត្រទី៣បានចែងថា "ផុតរយៈពេល៦ខែ(ប្រាំមួយខែ)គិតចាប់ពីថ្ងៃបង់ប្រាក់៖ ក្នុងករណីអ្នកជាប់កាតព្វកិច្ច នៅតែមិនទូទាត់បំណុលរបស់ខ្លួន ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបញ្ជូនសំណុំរឿង និងឯកសារភស្តុតាងទាំងអស់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផ្តល់កិច្ចសហការ ដើម្បីចាត់វិធានការតឹងទារបំណុលតាមរយៈយន្តការក្រុមការងារអន្តរក្រសួងដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" និងបទបញ្ជាលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ ចែងថា "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដាក់ចេញវិធានការជាមួយក្រសួងស្ថាប័នសាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារបំណុលដែលផ្នែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋ ដូចជា៖ បញ្ឈប់ការអនុញ្ញាតនាំចូល-នាំចេញ បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាបណ្ណ និងក្នុងករណីការអនុវត្តតឹងទារបំណុលនេះមិនមានប្រសិទ្ធភាព ក្រសួងស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្ដឹងទៅតុលាការ"។ ត្រង់ផ្នែកទី៣ មាត្រា៤៣ ត្រទី២ បានកំណត់ថា "លើសរយៈពេល៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យបង់ប្រាក់៖ ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវចាត់វិធានការលើបំណុលដែលត្រូវទារ និងពិន័យយ៉ាងតិច ២% (ពីរភាគរយ) ក្នុងមួយខែលើចំនួនទឹកប្រាក់បំណុលដើម និងទឹកប្រាក់ពិន័យកន្លងមកដែលមិនទាន់បានបំពេញកាតព្វកិច្ចបង់សងជូនភាគីរដ្ឋ ដោយគិតចាប់ពីថ្ងៃដំបូងដែលបានកត់ត្រាជាបំណុលមិនមែនសារពើពន្ធ...."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពរដ្ឋបាលជលផលនៅមានបំណុលត្រូវទារពីថ្លៃឈ្នួលឡូត៍នេសាទគិតពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៩ សរុបមានចំនួន៤ ៩៣៨ ៨២៨ ០០០រៀល ដែលក្រុមហ៊ុនមិនទាន់បានធ្វើការទូទាត់សង។ អគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅមានបំណុលត្រូវទារពីថ្លៃឈ្នួលលើការវិនិយោគស្តារដួល និងអភិវឌ្ឍន៍កៅស៊ូឡាបានសៀកខេត្តរតនគិរីក្នុងឆ្នាំ២០១៩ ពីក្រុមហ៊ុនស៊ីហ្វ៉ាប់ប៊ើលីមីតធីតមានចំនួន៦៣ ៧៨៥,៤៥ដុល្លារអាមេរិក និងប្រាក់ពិន័យ២%ពីការខកខានក្នុងការបង់ថ្លៃឈ្នួលនេះ (គិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០) ចំនួន១៥ ៥២៣,៧៤ដុល្លារអាមេរិកនៅឡើយ។ លើសពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពុំទាន់បានរៀបចំរបាយការណ៍កត់ត្រាតាមដានតួលេខបំណុលពីថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច ដែលក្រុមហ៊ុនមិនទាន់បានបង់ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវទៅតាមគោលការណ៍នៃការគ្រប់គ្រងបំណុលនៅឡើយ។

កត្តានេះ នាំឱ្យការគ្រប់គ្រងបំណុលត្រូវទារមិនទាន់មានភាពច្បាស់លាស់ និង អាចនាំឱ្យបាត់បង់បំណុលត្រូវទារជាយថាហេតុ។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរធ្វើការណែនាំដល់ អង្គភាពរដ្ឋបាលជលផល និងអគ្គនាយកដ្ឋានកៅស៊ូឱ្យធ្វើការពង្រឹងយន្តការពិនិត្យឡើងវិញ និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញការតឹងទារបំណុលថ្លៃឈ្នួលដែលក្រុមហ៊ុន នៅជំពាក់ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា ។ លើសពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួររៀបចំរបាយការណ៍កត់ត្រាតាមដានតួលេខបំណុលពីថ្លៃសម្បទានសេដ្ឋកិច្ច ដែលក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចមិនទាន់បានបង់ឱ្យបានច្បាស់លាស់។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការបញ្ជាក់ដូចតទៅៈ

- ពាក់ព័ន្ធនឹងបំណុលត្រូវទារពីថ្លៃឈ្នួលឡូត៍នេសាទគិតពីឆ្នាំ២០០៣ ដល់ឆ្នាំ ២០១៩ របស់រដ្ឋបាលជលផល តាមរយៈគណៈកម្មការបច្ចេកទេសទទួល បន្ទុកប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធប្រចាំក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ជាមួយនឹងប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រជុំ ពិនិត្យ និងពិភាក្សាជាបន្តបន្ទាប់ ដើម្បីលើកវិធានការដោះស្រាយ និងចាត់ វិធានការទប់ស្កាត់ការកើតបំណុលសម្បទាននេសាទថ្មីឈ្នួលឡូត៍នេសាទ ពីឆ្នាំ ២០០៣-២០១៦។ ជាក់ស្តែងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលលិខិតអញ្ជើញពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចូលរួមប្រជុំពិនិត្យ និងពិភាក្សាលើបញ្ហាបំណុលរ៉ាំរ៉ៃសម្បទាន នេសាទនៅសេសសល់ចន្លោះឆ្នាំ២០០៣ ដល់ឆ្នាំ២០១៦ ដែលស្ថិតក្រោម ការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- ករណីក្រុមហ៊ុនស៊ីហ្វរ៉ាប់បើលីមីតធីត ពុំទាន់បានបង់ថ្លៃឈ្នួលចម្ការកៅស៊ូរដ្ឋ ឡាបានសៀកសម្រាប់ឆ្នាំ២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានវិធានការជាបន្តបន្ទាប់ ដោយបានចេញសេចក្តីជូនដំណឹងជូនទៅលោកស្រី អគ្គនាយិកា ក្រុមហ៊ុនស៊ីហ្វរ៉ាប់ប៊ីលីមីតធីត (យោងលិខិតលេខ៤០៨១ កសិក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩) ជាមួយគ្នានេះ អគ្គនាយកដ្ឋានចំការកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជូនដំណឹងទៅលោកស្រីអគ្គ នាយិកា ក្រុមហ៊ុននេះជាថ្មីម្តងទៀត (លិខិតលេខ៥៤២ អក.រន ចុះថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០១៩) ដើម្បីឱ្យក្រុមហ៊ុននេះបំពេញកាតព្វកិច្ចបង់ប្រាក់ឈ្នួលកៅស៊ូ រដ្ឋឡាបានសៀកខេត្តរតនគិរី។
- ចំពោះក្រុមហ៊ុនដែលមិនបានបង់ថ្លៃឈ្នួល មិនអាចចាត់ទុកថាជាបំណុលនៅ ឡើយទេដោយសារៈ
  - ក្រុមហ៊ុនមិនទាន់ចុះកិច្ចសន្យា

- ក្រុមហ៊ុនមិនទាន់បានចុះបញ្ជីដី
- ក្រុមហ៊ុនមិនទាន់កែសម្រួលកិច្ចសន្យា
- ក្រុមហ៊ុនមិនទាន់ដោះស្រាយទំនាស់ដីធ្លី។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការជំរុញការតឹងទារបំណុលថ្លៃឈ្នួលទឡ្ហ៍នេសាទ និងវិនិយោគកៅស៊ូដែលក្រុមហ៊ុននៅជំពាក់ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគួរធ្វើការការកត់ត្រាតាមដានតួលេខបំណុលពីថ្លៃសម្បទានសេដ្ឋកិច្ចដែលក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងឡាយណាដែលត្រូវបង់ ប៉ុន្តែមិនទាន់បានបង់ឱ្យបានច្បាស់លាស់ ដើម្បីមានភាពងាយស្រួលក្នុងការគ្រប់គ្រង និងតាមដានតួលេខបំណុលឱ្យបានពេញលេញស្របតាមគោលការណ៍ និងបទប្បញ្ញត្តិនៃការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីជៀសវាងការបាត់បង់បំណុលទាំងនោះជាយថាហេតុ។

## ៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១.ការកត់ត្រាពន្ធឈ្នួលចលន និងអចលនទ្រព្យពុំទាន់សមស្រប

ដើម្បីផ្តល់លទ្ធភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលបានផ្តល់ប្រភពចំណូលបន្ថែមជូនសាលារាជធានី ខេត្ត ដោយផ្ទេរគណនី៧០០១ ពន្ធផ្ទាល់ "ពន្ធលើផលទុនប្រាក់ចំណូល" ពីថវិកាជាតិ មកថវិកាថ្នាក់ក្រោមជាតិតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៩ តម្រូវឱ្យកត់ត្រាចំណូលពន្ធលើផលទុនប្រាក់ចំណូល(ឈ្នួលចលន និងអចលនទ្រព្យ) ចូលក្នុងគណនីចំណូលថវិការាជធានី ខេត្ត។ តាមការពិនិត្យស្ថិតិពន្ធលើឈ្នួលចលន និងអចលនទ្រព្យប្រចាំខែ និងសំណុំឯកសារផ្សេងៗនៅសាខាពន្ធដារខេត្តមួយចំនួន និងតាមការធ្វើតេស្តអចលនទ្រព្យដែលបានជួលទៅឱ្យសាខាក្រុមហ៊ុនប្រកបអាជីវកម្មចំនួន៧១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអចលនទ្រព្យចំនួន៦៩ ដែលម្ចាស់បានជួលទៅឱ្យក្រុមហ៊ុនបើកសាខាប្រកបអាជីវកម្មនៅតាមខេត្តមួយចំនួនខាងលើ ហើយក្រុមហ៊ុនបានប្រកាសបង់ចំណូលពីឈ្នួលអចលនទ្រព្យចូលគណនី៧០០១ "ពន្ធផ្ទាល់" មិនទាន់សមស្របតាមទីតាំងជាក់ស្តែងដែលអចលនទ្រព្យស្ថិតនៅតាមបណ្តាខេត្តនោះឡើយ គឺបង់នៅតាមអង្គភាពពន្ធដែលក្រុមហ៊ុនបានចុះបញ្ជី។ ជាងនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារក៏មិនបានបង្វែរចំណូលពីឈ្នួលអចលនទ្រព្យចូលជាថវិការាជធានី ខេត្តដែលអចលនទ្រព្យស្ថិតដែរ។

ការកត់ត្រាចំណូលពីឈ្នួលអចលនទ្រព្យមិនបានត្រឹមត្រូវទៅតាមទីតាំងជាក់ស្តែងដែលអចលនទ្រព្យស្ថិតនៅ អាចធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមិនមានថវិកាគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំដល់អង្គភាពពាក់ព័ន្ធឱ្យ

ពិនិត្យការកត់ត្រាពន្ធឈ្នួលអចលនទ្រព្យសមស្របតាមទីតាំងអចលនទ្រព្យស្ថិតនៅថ្នាក់ក្រោមជាតិជាក់ស្តែង។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានពន្ធដារមានប្រព័ន្ធទទួលការបង់ប្រាក់ពន្ធច្បាស់លាស់។ ក្នុងករណីនេះ ពាក់ព័ន្ធលើការអនុវត្តការកាត់ទុកពន្ធឈ្នួលចលន និងអចលនទ្រព្យរបស់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ ជាការអនុវត្តសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស រាល់ពន្ធកាត់ទុកទាំងអស់ដែលប្រមូលបានរួមទាំងពន្ធកាត់ទុកលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ សហគ្រាសត្រូវធ្វើការប្រកាសបង់ពន្ធសរុបនៅអង្គភាពពន្ធដារដែលខ្លួនបានចុះបញ្ជី និងស្ថិតក្រោមការគ្រប់គ្រង និងត្រូវបានទទួលស្គាល់ជាចំណូលក្នុងអង្គភាពពន្ធដារនោះ ដោយពុំតម្រូវឱ្យសហគ្រាសធ្វើការប្រកាសបង់ពន្ធនៅតាមបណ្តាសាខាពន្ធដារខេត្ត ខណ្ឌ ទៅតាមប្រភពចំណូលពន្ធដែលបានកាត់ទុកនោះទេ។ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងកែលម្អចំណុចនេះក្នុងប្រព័ន្ធបច្ចេកវិទ្យារបស់ខ្លួន ដោយមានការពិភាក្សាជាមួយអ្នកជាប់ពន្ធ និងវិស័យឯកជន ដើម្បីកែលម្អលើចំណុចនេះ ឱ្យបានល្អប្រសើរនាពេលខាងមុខ ដើម្បីឱ្យចំណូលទាំងនោះត្រូវបានបែងចែកទៅថ្នាក់មូលដ្ឋានដែលអចលនទ្រព្យនោះស្ថិតនៅ ដែលជាគុណប្រយោជន៍សម្រាប់ការអភិវឌ្ឍមូលដ្ឋាននោះ។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.២.២.ភាពយឺតយ៉ាវក្នុងការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួន

ដើម្បីសម្រួលដល់សាធារណៈជនក្នុងការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យឱ្យបានឆាប់រហ័ស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ឱ្យអគ្គនាយកដ្ឋានពន្ធដារផ្តល់សេវាចំពោះការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិក្នុងរយៈពេលចំនួន ៤-៨ ថ្ងៃ (ថ្ងៃធ្វើការ)។ តាមការពិនិត្យសំណុំឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រាចំនួន១ ០០៨ ក្នុងខែកក្កដាឆ្នាំ២០១៩ នៅសាខាពន្ធដារខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្តចំនួន៤ បានផ្តល់សេវាប្រថាប់ត្រាចំពោះផ្ទេរកម្មសិទ្ធិអចលនទ្រព្យមួយចំនួនតូចមានភាពយឺតយ៉ាវជាងការកំណត់ជាក់សស្តែងចាប់ពី២១ថ្ងៃ រហូតដល់ជាង១០០ថ្ងៃធ្វើការ។

ភាពយឺតយ៉ាវក្នុងការផ្តល់សេវាប្រថាប់ត្រាចំពោះផ្ទេរកម្មសិទ្ធិអចលនទ្រព្យ អាចនាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារ និងនាំឱ្យមានការថ្នាំងថ្នាក់ពីអ្នកជាប់ពន្ធមួយចំនួនផងដែរ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំដល់អគ្គនាយកដ្ឋានពន្ធដាររិះរកវិធីសាស្ត្រផ្តល់សេវាប្រថាប់ត្រាលើអចលនទ្រព្យឱ្យកាន់តែប្រសើរថែមទៀត។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា ចំពោះការស្នើសុំបង់ពន្ធប្រថាប់ត្រាលើអចលនទ្រព្យ អគ្គនាយកដ្ឋានពន្ធដារ ក៏មានប្រព័ន្ធតាមដានឯកសារដែលអ្នកជាប់ពន្ធអាចពិនិត្យ និងតាមដានឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់គាត់ថា ដល់ណាហើយ

ឬទទួលបានការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារហើយឬនៅ។ ចំពោះករណីឃើតយ៉ាវមួយចំនួន អាចកើតឡើងដោយកត្តាមួយចំនួន ដូចជា ការកង្វះខាតឯកសារភ្ជាប់របស់អ្នកជាប់ពន្ធ ការខកខានមិនបានបង់ពន្ធលើអចលនទ្រព្យនាពេលកន្លងមក និងការជាប់ជំពាក់បំណុលពន្ធរបស់អ្នកជាប់ពន្ធ ដែលទាមទារឱ្យអ្នកជាប់ពន្ធត្រូវទូទាត់បំណុលទាំងនោះជាមុនសិន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តខិតខំកែលម្អចំណុចខ្វះចន្លោះនេះ ដោយបន្តខិតខំផ្តល់សេវាស្នើសុំបង់ពន្ធប្រថាប់ត្រាជូនម្ចាស់កម្មសិទ្ធិឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.២.៣.កង្វះខាតក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ

ប្រកាសលេខ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ត្រង់ជំពូកទី០២ ប្រការ០៥ ចំណុចទី៣ បានចែងថា "អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ" និងត្រង់ជំពូកទី១៤ ប្រការ១០៩ បានចែងថា "សាខាពន្ធដារខេត្ត ខណ្ឌ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យមស្ថិតក្នុងមណ្ឌលដែនដីរបស់ខ្លួន"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៩ សាខាពន្ធដារខេត្តប៉ៃលិនបានរៀបចំស្ថិតិជំរឿនផ្ទះសំណាក់ និងសណ្ឋាគារ មានចំនួនសរុប២៩ទីតាំង ប៉ុន្តែសាខាពន្ធដារខេត្តប្រមូលចំណូលបានតែ១២ទីតាំង ដែលមានចំនួនទឹកប្រាក់១៤ ០៥៧ ០៣៩រៀល។

ឆ្លើយតបនឹងការលើកឡើងនេះ សាខាពន្ធដារខេត្តប៉ៃលិន សូមទទួលស្គាល់ការអនុវត្តប្រមូលចំណូលអាករលើការស្នាក់នៅ ពិតជានៅមានការខ្វះខាត ដោយសារនៅក្នុងខេត្តប៉ៃលិនមានអាជីវកម្មប្រភេទផ្ទះសំណាក់ និងសណ្ឋាគារ ក្នុងបរិមាណតិច ជាហេតុធ្វើឱ្យចំណូលអាករប្រភេទនេះមានកម្រិតទាបនៅឡើយ។ ទន្ទឹមនឹងនោះដែរ នាដើមឆ្នាំ២០១៩ សាខាពន្ធដារខេត្ត ក៏បានខិតខំយកចិត្តទុកដាក់ខ្ពស់ ក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ ដោយធ្វើការចុះស្រង់ស្ថិតិផ្ទះសំណាក់ សណ្ឋាគារតាមបណ្តាមុខព្រួញទាំងពីរ (ក្រុងប៉ៃលិន និងស្រុកសាលាក្រៅ) ព្រមទាំងធ្វើលិខិតជូនដំណឹងដល់ម្ចាស់ផ្ទះសំណាក់ដែលមានផលរបរដល់កម្រិតដើម្បីចូលខ្លួនមកបំពេញកាតព្វកិច្ចចុះបញ្ជីប្រកាសបង់ប្រាក់ពន្ធឱ្យស្របតាមច្បាប់សារពើពន្ធ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានលើការកែលម្អអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

### ៣.២.៤.ការប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់

ដើម្បីប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ឱ្យអស់លទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដោយបានកំណត់តួនាទីរបស់គណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ឱ្យបង្កើតបញ្ជីរាយនាមឈ្មោះតំបន់ ឬខណ្ឌនៃរាជធានី និងក្រុង ស្រុកនៃខេត្ត ដែល

មានដីត្រូវជាប់ពន្ធ។ តាមការធ្វើសវនកម្មនៅសាខាពន្ធដារខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្តទាំងនោះពុំទាន់ទទួលបាននូវបញ្ជីដីដែលត្រូវជាប់ពន្ធពីគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់នៅឡើយទេ។ ប៉ុន្តែទោះជាយ៉ាងណា ក្នុងឆ្នាំ២០១៩ សាខាពន្ធដារខេត្តទាំងនោះបានខិតខំប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់លើសផែនការឆ្នាំ ហើយការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នេះភាគច្រើនធ្វើឡើងនៅពេលម្ចាស់ដីស្នើសុំបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិដី។

ការខកខានក្នុងការបំពេញតួនាទីរបស់គណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ធ្វើឱ្យការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ពុំទាន់បានពេញលេញ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ឱ្យរៀបចំបញ្ជីដីដែលត្រូវជាប់ពន្ធឱ្យបានទាន់ពេលវេលា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានពន្ធដារនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះខាតទិន្នន័យអចលនទ្រព្យ និងខ្វះមន្ត្រីដើម្បីចុះត្រួតពិនិត្យគ្រប់អចលនទ្រព្យ។ ម្ចាស់អចនលទ្រព្យមួយចំនួននៅតែមិនយកចិត្តទុកដាក់ ឬរឹងរូសក្នុងការបំពេញកាតព្វកិច្ចពន្ធ ប៉ុន្តែម្ចាស់អចលនទ្រព្យពុំអាចធ្វើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យបានឡើយ បើសិនអចលនទ្រព្យនោះនៅពុំបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើអចលនទ្រព្យ។ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តខិតខំកែលម្អលើចំណុចខ្វះខាតនេះ។ ចំពោះសេចក្តីសម្រេចបង្កើតអនុគណៈកម្មការដីធ្លីមិនបានប្រើប្រាស់ គឺយើងមានរួចហើយដែលបច្ចុប្បន្នបាននិងកំពុងរៀបចំការធ្វើបច្ចុប្បន្នភាព ដោយសារមានការកែសម្រួលសមាសភាពមួយចំនួន ហើយយើងក៏មានក្រុមការងារចុះអង្កេតអចលនទ្រព្យនៅតាមបណ្តាខេត្ត ខណ្ឌ និងមានតារាងលម្អិតឧបសម្ព័ន្ធផ្សព្វផ្សាយតាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារផងដែរ។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.២.៥.ការប្រមូលចំណូលពីការចេញអាជ្ញាបណ្ណទេសចរណ៍ពុំអស់លទ្ធភាព

ប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្តត្រូវបានធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រួមមានដូចខាងក្រោម៖

- សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត បឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ចំណុះត្រឹម ២០ បន្ទប់ចុះ
- ផ្ទះភ្ញៀវ ចំណុះត្រឹម ២០ បន្ទប់ចុះ
- ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ ចំណុះត្រឹម១០០នាក់/កៅអីចុះ មិនស្ថិតនៅក្នុងអាជីវកម្មដែលចេញអាជ្ញាបណ្ណដោយក្រសួងទេសចរណ៍
- បៀរហ្គាឌិន

- ខារ៉ាអូខេ ចាប់ពី ០៦ បន្ទប់ឡើង
- ម៉ាស្សាសុខភាព ចំណុះពី ០៦ ដល់ ១០គ្រែ ឬកៅអី ...។

និងប្រកាសលេខ១២៣ ប្រក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរទេសចរណ៍រាជធានី-ខេត្ត បានតម្រូវឱ្យចូលរួមជំរុញ និងអនុវត្តយន្តការ និងនីតិវិធីនៅថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យ និងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ទាំងការផ្តល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ ទេសចរណ៍ម៉ាយ (ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) សេវាកម្មម៉ាស្សា និងស្ប៉ា ភ្នាក់ងារដឹកជញ្ជូនទេសចរណ៍ សេវាកម្មកម្សាន្ត និងកីឡាទេសចរណ៍។

តាមការធ្វើសវនកម្មនៅមន្ទីរទេសចរណ៍ខេត្តចំនួន០៥ ឃើញថា នៅមានអាជីវកម្មសេវាកម្មទេសចរណ៍មួយចំនួនក្នុងខេត្តកំពុងប្រតិបត្តិអាជីវកម្ម ដោយពុំមានអាជ្ញាបណ្ណទេសចរណ៍ឡើយ រួមមានខេត្តស្វាយរៀងមានចំនួន៥៥ទីតាំង (សណ្ឋាគារ០២ ផ្ទះសំណាក់១៧ ភោជនីយដ្ឋាន និងអាហារដ្ឋាន២៦ ម៉ាស្សា០២ ខារ៉ាអូខេ០៧ និងឌីស្កូតេក០១) ខេត្តឧត្តរមានជ័យចំនួន៩៣ទីតាំង (សណ្ឋាគារ០៥ ផ្ទះសំណាក់៣២ ភោជនីយដ្ឋាន និងអាហារដ្ឋាន២៧ ម៉ាស្សា១៨ និងខារ៉ាអូខេ១១) ខេត្តក្រចេះមានចំនួន៣០ទីតាំង (សណ្ឋាគារ០១ ផ្ទះសំណាក់០៦ ភោជនីយដ្ឋាន និងអាហារដ្ឋាន១៨ និងខារ៉ាអូខេ០៥) ខេត្តស្ទឹងត្រែងមានចំនួន៥៣ទីតាំង (ផ្ទះសំណាក់១១ ភោជនីយដ្ឋាន និងអាហារដ្ឋាន២៥ ម៉ាស្សា០៤ និងសេវាដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹក១៣) និងខេត្តបាត់ដំបងមានចំនួន៣៧ទីតាំង (ផ្ទះភ្ញៀវ០៤ ភោជនីយដ្ឋាន និងអាហារដ្ឋាន២០ ខារ៉ាអូខេ០៩ ម៉ាស្សា០២ និងរង្គសាល ក្លឹប០២)។

កង្វះខាតក្នុងការបំពេញកាតព្វកិច្ចប្រមូលចំណូលពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ពុំអស់លទ្ធភាព នាំឱ្យបាត់ចំណូលថវិកាជាតិ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំដល់មន្ទីរជំនាញនេះឱ្យខិតខំអនុវត្តតាមគោលការណ៍ណែនាំខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តមួយចំនួនបានបំភ្លឺថា នឹងជំរុញមន្ទីរទេសចរណ៍អនុវត្តការងារនេះ និងខេត្តមួយចំនួនទៀតថាបានធ្វើការផ្សព្វផ្សាយណែនាំដល់សេវាករ និងប្រតិបត្តិករទេសចរណ៍នូវច្បាប់ គោលការណ៍ណែនាំរួចហើយ និងថាសេវាករខ្លះប្រតិបត្តិក្នុងទីតាំងកាស៊ីណូ ពុំព្រមដាក់សំណើសុំអាជ្ញាបណ្ណទេសចរណ៍ទេ ខ្លះទៀតកំពុងមានវិបត្តិហិរញ្ញវត្ថុ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានការអនុវត្តតាមអនុសាសន៍សវនកម្មបន្តទៀត។

### ៣.២.៦.ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីតាមដានការងារសាងសង់ និងជួសជុល

ប្រកាសលេខ៣៨១ ប្រក.សហវ/២០១០ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើសៀវភៅលទ្ធកម្មស្តីពីការអនុវត្តន៍វិធាន និងបទប្បញ្ញត្តិ ស្តីពីលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ចំណុច៣.១៤.៨ បានបញ្ជាក់ថា ជាទូទៅការត្រួតពិនិត្យកិច្ចសន្យាសំណង់មានការស្មុគស្មាញ ដោយសារកត្តាទាំងឡាយដែលមិនអាចដឹងបានមុនពេលចាប់ផ្តើមការងារ។ ដូច្នេះ តម្រូវឱ្យមានការចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីធ្វើការគ្រប់គ្រងទីតាំងគម្រោង និងត្រួតពិនិត្យសកម្មភាពប្រចាំថ្ងៃរបស់"អ្នកទទួលការ"។ អ្នកគ្រប់គ្រងគម្រោងអាចជាបុគ្គលនៅក្នុងអង្គភាពលទ្ធកម្ម ឬជាទីប្រឹក្សាជំនាញ ឬជាបុគ្គលដែលមានជំនាញមកពីស្ថាប័នអនុវត្តលទ្ធកម្ម។ អ្នកគ្រប់គ្រងគម្រោងត្រូវធ្វើរបាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាដែលកើតមានឡើងក្នុងពេលអនុវត្តការងារ។

តាមការធ្វើតេស្តសវនកម្មលើសំណុំឯកសារលទ្ធកម្មឆ្នាំ២០១៩នៅខេត្តចំនួន០៧ គឺខេត្តតាកែវ កណ្តាល កំពង់ស្ពឺ កោះកុង ស្ទឹងត្រែង កំពត និងខេត្តព្រះសីហនុឃើញថា ការសាងសង់ និងជួសជុលសំណង់អគារ និងផ្លូវរដ្ឋមួយចំនួន គឺពុំបានចាត់តាំងមន្ត្រីជំនាញ អ្នកគ្រប់គ្រងគម្រោង ដើម្បីតាមដានការងារសាងសង់របស់អ្នកទទួលការ និងធ្វើរបាយការណ៍វឌ្ឍនភាពឡើយ។

ដោយសារការពុំបានចាត់តាំងឱ្យមានអ្នកគ្រប់គ្រងគម្រោង អាចនាំឱ្យគណៈកម្មការប្រគល់ ទទួលសំណង់ ពុំមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីធ្វើការសន្និដ្ឋាន មុនពេល ឬក្នុងអំឡុងពេលប្រគល់ ទទួលសំណង់ឡើយ ហើយគុណភាពសំណង់ក៏អាចអនុវត្តមិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំអង្គភាពអនុវត្តលទ្ធកម្មឱ្យចាត់តាំងបុគ្គល ឬអ្នកមានជំនាញវិជ្ជាជីវៈសំណង់ ដើម្បីធ្វើការតាមដានជាប្រចាំនូវរាល់សកម្មភាពការងាររបស់អ្នកទទួលការ និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពជូនទៅថ្នាក់ដឹកនាំពិនិត្យ និងកែលម្អឱ្យបានទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តបានទទួលយកនូវអនុសាសន៍សវនកម្ម ដោយសន្យាថានឹងណែនាំដល់អង្គភាពអនុវត្តលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងថាការងារនេះនឹងត្រូវបានអនុវត្តបានល្អប្រសើរនាពេលខាងមុខ ហើយអាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៧.ការសម្រេចជ្រើសអ្នកទទួលការផ្គត់ផ្គង់តាមកិច្ចលទ្ធកម្មសាធារណៈប្រើប៉ាតង់ពុំចំមុខសញ្ញា

សារាចរណែនាំលេខ០០៤ សហវ. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការអនុវត្តពន្ធប៉ាតង់ បានតម្រូវឱ្យអ្នកជាប់ពន្ធ ដែលចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ អាចប្រើប្រាស់នូវបណ្ណប៉ាតង់ដែលខ្លួនបានបង់ពន្ធរួច ដើម្បីបំពេញបែបបទចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ តែបណ្ណប៉ាតង់នោះ ត្រូវតែមានមុខរបរឱ្យស្របគ្នានឹងមុខរបរដែលត្រូវចូលរួម

ដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងតម្លៃ...″ ក្រោយពេលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងតម្លៃបាន អ្នកជាប់ពន្ធត្រូវបង់ពន្ធប៉ាតង់ជាថ្មី ផ្អែកតាមផលរបរដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងតម្លៃបាននោះ នៅតាមសាខាពន្ធដារខេត្ត ក្រុង ដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងតម្លៃបាន ដើម្បីអនុវត្តគម្រោងរបស់ខ្លួន″។

តាមរយៈការធ្វើសវនកម្មនៅខេត្តចំនួន០៥ និងនៅមន្ទីរជំនាញមួយចំនួន ដែលបានជ្រើសរើសយកអ្នកទទួលការផ្គត់ផ្គង់តាមកិច្ចលទ្ធកម្មសាធារណៈ ដោយអ្នកទទួលការផ្គត់ផ្គង់ទាំងនោះ សុទ្ធតែមានបណ្ណប៉ាតង់អាជីវកម្មពុំសមស្របតាមមុខសញ្ញានៃគម្រោង មានជាអាទិ៍ ខេត្តស្វាយរៀងមានចំនួន០៥គម្រោង បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានអាជីវកម្មទិញ-លក់សម្ភារការិយាល័យ និងគ្រឿងសង្ហារឹម ប៉ុន្តែបានផ្គត់ផ្គង់ឯកសណ្ឋានជូនមន្ទីរឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍។

បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានអាជីវកម្មផ្គត់ផ្គង់សម្ភារការិយាល័យ បរិក្ខារ និងសង្ហារឹម ប៉ុន្តែបានផ្គត់ផ្គង់មធ្យោបាយដឹកជញ្ជូនជូនមន្ទីរឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍០១គម្រោង មន្ទីរបរិស្ថាន០១គម្រោង មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ០១គម្រោង។ បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានអាជីវកម្មទិញ-លក់សម្ភារការិយាល័យ គ្រឿងបរិក្ខារអេឡិចត្រូនិច និងគ្រឿងសង្ហារឹម ប៉ុន្តែបានផ្គត់ផ្គង់សម្ភារឧបត្ថម្ភអ្នកជម្ងឺ ជូនមន្ទីរសុខាភិបាល។

ខេត្តកំពង់ស្ពឺមានចំនួន០១គម្រោង ដែលបណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានអាជីវកម្មចម្បងទិញលក់សម្ភារការិយាល័យ ប៉ុន្តែបានផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

ខេត្តរតនគិរីមានចំនួន០៦គម្រោង បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានអាជីវកម្មលក់សម្ភារការិយាល័យ ប៉ុន្តែបានផ្គត់ផ្គង់សង្ហារឹម០១គម្រោង សម្ភារ និងបរិក្ខារបច្ចេកទេស០១គម្រោង ម៉ូតូ០១គម្រោង និងឧបត្ថម្ភសហគមន៍ ដូចជា អង្ករ និងសម្ភារចែកជូនស្រ្តីមេម៉ាយ ទីទ័លក្រគ្មានទីពឹង០១គម្រោង ជូនមន្ទីរកិច្ចការនារី។ បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានអាជីវកម្មទិញលក់គ្រឿងអេឡិចត្រូនិក និងគ្រឿងសង្ហារឹម ប៉ុន្តែបានផ្គត់ផ្គង់សម្ភារការិយាល័យជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ០១គម្រោង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី០១គម្រោង។

ខេត្តកោះកុង បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានរបរលក់គ្រឿងទេស ប៉ុន្តែបានដាក់ចូលរួមដេញថ្លៃប្រេងឥន្ធនៈនៅរដ្ឋបាលខេត្ត។ បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានមុខរបរផ្គត់ផ្គង់សម្ភារគ្រប់ប្រភេទបានចូលរួមដេញថ្លៃ និងពិគ្រោះថ្លៃប្រេងឥន្ធនៈនៅមន្ទីរជំនាញចំនួន១៤ក្នុងខេត្ត។ បណ្ណប៉ាតង់របស់អ្នកផ្គត់ផ្គង់មានមុខរបរសាងសង់សំណង់បានចូលរួមដេញថ្លៃ និងពិគ្រោះថ្លៃប្រេងឥន្ធនៈនៅមន្ទីរជំនាញចំនួន១៤ក្នុងខេត្ត។

ដោយសារការសម្រេចជ្រើសរើសយកអ្នកទទួលការផ្គត់ផ្គង់តាមកិច្ចលទ្ធកម្ម ដែលបណ្ណប៉ាតង់អាជីវកម្មមានមុខរបរពុំសមស្របនឹងគម្រោង នាំឱ្យប៉ះពាល់ដល់គោលការណ៍លទ្ធកម្មសាធារណៈ និងបាត់ចំណូលពន្ធប៉ាតង់។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តខាងលើគួរណែនាំអង្គភាពអនុវត្តលទ្ធកម្ម ក្រុមលទ្ធកម្ម និងគណៈកម្មាធិការលទ្ធកម្ម អនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលការណ៍លទ្ធកម្មសាធារណៈនាពេលកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខាងលើបានទទួលយកនូវអនុសាសន៍សវនកម្ម ដោយសន្យាថានឹងណែនាំដល់អង្គភាពអនុវត្តលទ្ធកម្ម អនុវត្តឱ្យបានត្រឹមត្រូវ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

**៣.២.៨.កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម**

ក្នុងការវាយតម្លៃការងារលទ្ធកម្ម អង្គភាពលទ្ធកម្មត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មដើម្បីរាយការណ៍ពីការងាររបស់ខ្លួន។ ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ៣៧ នៃជំពូកទី១០ របាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម បានតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាជ្ញាធរអគ្គិសនីកម្ពុជាបានរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ២០១៩ មិនទាន់បានត្រឹមត្រូវនៅឡើយទេ ដោយអាជ្ញាធរអគ្គិសនីកម្ពុជាបានរាយការណ៍ថា មានចំនួន០៧គម្រោង ត្រូវបានអនុវត្តតាមវិធីសាស្ត្រលទ្ធកម្មដេញថ្លៃប្រកួតប្រជែងក្នុងស្រុក និង០២គម្រោងទៀត តាមវិធីសាស្ត្រលទ្ធកម្មដោយឡែក។ ប៉ុន្តែតាមការពិនិត្យឯកសារលទ្ធកម្ម មាន០៥គម្រោងបានអនុវត្តតាមវិធីសាស្ត្រលទ្ធកម្មដេញថ្លៃប្រកួតប្រជែងក្នុងស្រុក និង០៤គម្រោងទៀត បានអនុវត្តតាមវិធីសាស្ត្រលទ្ធកម្មដោយឡែក។ អាជ្ញាធរអគ្គិសនីកម្ពុជា គួររៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ក្នុងការរៀបចំរបាយការណ៍លទ្ធកម្មឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម នឹងកំពុងបានអនុវត្តក្នុងឆ្នាំ២០២០។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានការអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.២.៩.ការខ្ចីប្រេងឥន្ធនៈប្រើប្រាស់មុនធ្វើកិច្ចលទ្ធកម្ម**

សារាចរណែនាំលេខ០០២ សហវ អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២០ បានចែងថា "រាល់ការខ្ចីនូវឧបករណ៍សម្ភារសម្រាប់ប្រើប្រាស់មុន ឬការប្រគល់ទទួលទំនិញ សំណង់ សេវានៃគម្រោងលទ្ធកម្មណាមួយដោយគ្មានកិច្ចសន្យាត្រូវហាមឃាត់ដាច់ខាត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនអនុញ្ញាតឱ្យធ្វើការទូទាត់ជូនឡើយ ហើយស្ថាប័នអនុវត្តលទ្ធកម្មត្រូវទទួលខុសត្រូវចំពោះបាតុភាពអសកម្មទាំងឡាយដែលកើតចេញពីទង្វើរបស់ខ្លួននេះ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្ត និងមន្ទីរមួយចំនួននៃខេត្តត្បូងឃ្មុំ និងខេត្តកែប បានខ្ចីប្រេងឥន្ធនៈប្រើប្រាស់ពីដេប៉ូមុនអនុវត្តកិច្ចលទ្ធកម្ម។ រដ្ឋបាលខេត្ត និងមន្ទីរនានានៃខេត្តត្បូងឃ្មុំ និងខេត្តកែបគួរខិតខំអនុវត្តតាមសារាចរណែនាំខាងលើឱ្យបានត្រឹមត្រូវ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ រដ្ឋបាលខេត្ត និងមន្ទីរនានានៃខេត្តត្បូងឃ្មុំ និងខេត្តកែបនឹងខិតខំពង្រឹង និងកែលម្អនូវចំណុចខ្វះខាតទាំងឡាយពាក់ព័ន្ធ ដែលមិនទាន់ស្របតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិ ដែលអាជ្ញាធរសវនកម្មជាតិបានធ្វើការកត់សម្គាល់ឃើញ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវការអនុវត្តតាមអនុសាសន៍ជាបន្តទៀត។

**៣.២.១០.ការពុំទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង**

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ត្រង់មាត្រា៤១ បានតម្រូវឱ្យ "សវនកម្មផ្ទៃក្នុងត្រូវបង្កើតនៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ"។ សវនកម្មផ្ទៃក្នុងត្រូវធ្វើរបាយការណ៍ទៅប្រធាន ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈរបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាន នៃការធ្វើសវនកម្មនេះទៅអាជ្ញាធរសវនកម្មជាតិ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតដល់ចុងឆ្នាំ២០១៩ គ្រឹះស្ថានអង្គរនៅតែពុំទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង។ គ្រឹះស្ថានអង្គរ គួរតែបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់គ្រឹះស្ថានឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ គ្រឹះស្ថាននឹងពិនិត្យលទ្ធភាពបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង នៅពេលប្រកាសរួមស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគ្រឹះស្ថានអង្គររៀបចំរួចរាល់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពបន្តទៀត។

**៣.២.១១.ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈនៅមានកម្រិត**

ប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ត្រង់ប្រការ៣ បានចែងថា "គ្មានបុគ្គលណាដែលអាចបង្កើតស្ថានីយប្រេងឥន្ធនៈដោយគ្មានៈ
ក.លិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយប្រេងឥន្ធនៈពីក្រសួងរ៉ែ និងថាមពល
ខ.វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈពីក្រសួងរ៉ែ និងថាមពល"។

តាមរយៈការធ្វើសវនកម្មនៅមន្ទីររ៉ែ និងថាមពល ខេត្តប៉ៃលិន សម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅទូទាំងខេត្តប៉ៃលិន មានស្ថានីយប្រេងឥន្ធនៈសរុបចំនួន២៩ ក្នុងនោះ មន្ទីររ៉ែ និងថាមពលខេត្ត បានចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយប្រេងឥន្ធនៈចំនួន០៥ និងលិខិតអនុញ្ញាតដំណើរ

ការស្ថានីយប្រេងឥន្ធនៈចំនួន០១ ប៉ុន្តែមន្ទីរនៅពុំទាន់បានចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការចំនួន២៤ទៀតនៅឡើយ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងជំរុញមន្ទីររ៉ែ និងថាមពល ខេត្តប៉ៃលិន ឱ្យអនុវត្តការងារនេះឱ្យបានល្អប្រសើរ។

ផ្អែកតាមការឆ្លើយបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៩ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

### ៤.១.ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម

ប្រកាសលេខ០២៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រង់ប្រការ៤ បានចែងថា "ការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបែងចែកជាបីប្រភេទ៖ អ្នកជាប់ពន្ធតូចគឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ៧០០លានរៀល ឬមានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត... អ្នកជាប់ពន្ធមធ្យម គឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០ លានរៀល ដល់ ៤ ០០០លានរៀល.....”។

តាមការធ្វើតេស្តលើលិខិតប្រកាសពន្ធរបស់អ្នកជាប់ពន្ធតូចចំនួន១៣៥ នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអ្នកជាប់ពន្ធតូចចំនួន ២៦ មានផលរបរត្រូវជាប់ពន្ធមធ្យម (លើសពី៧០០លានរៀល) ប៉ុន្តែសាខាពន្ធដារខេត្ត ខណ្ឌទាំងនោះមិនទាន់បានចាត់វិធានការផ្ទេរសហគ្រាសទាំងនោះទៅអ្នកជាប់ពន្ធមធ្យមនៅឡើយ។ ការយឺតយ៉ាវនេះក៏ដោយសារអ្នកជាប់ពន្ធតូចមួយចំនួនមិនបានបង្កលក្ខណៈងាយស្រួលដល់អង្គភាពពន្ធដារដើម្បីធ្វើការចុះបញ្ជីពន្ធដារនោះទេ ដោយហេតុថា អ្នកជាប់ពន្ធមួយចំនួនមានបំណងចង់គេចវេសពីការធ្វើសវនកម្ម និងការកាន់កាប់បញ្ជីគណនេយ្យ។ ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តខិតខំកែលម្អលើចំណុចខ្វះខាតនេះ ហើយនឹងណែនាំដល់គ្រប់សាខាពន្ធដារខេត្ត ខណ្ឌពាក់ព័ន្ធត្រូវបន្តពង្រឹងការផ្ទេរសហគ្រាសអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម ដើម្បីឱ្យស្របតាមប្រកាសណែនាំស្ដីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

### ៤.២.ការប្រមូលពន្ធប៉ាតង់ពុំទាន់បានពេញលេញ

ប្រកាសលេខ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៥ ចំណុច៤ បានតម្រូវឱ្យអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី ខេត្តផ្សេងគ្នាត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ និងត្រង់ប្រការ៧ បានចែងថា ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

តាមការធ្វើតេស្តលើការប្រកាសបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៩ របស់ក្រុមហ៊ុនចំនួន៦ ០៩៩ (សាខាក្រុមហ៊ុនចំនួន៨៨៩ ក្រុមហ៊ុនរបបស្វ័យប្រកាសអ្នកជាប់ពន្ធមធ្យមចំនួន២ ៧៦០ របប

ស្វ័យប្រកាសអ្នកជាប់ពន្ធតូចចំនួន២ ៤៥០) ដែលចុះបញ្ជីនៅតាមបណ្ដាសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនចំនួន១ ៣០៥ (សាខាក្រុមហ៊ុនចំនួន២៩០ ក្រុមហ៊ុនរបបស្វ័យប្រកាសអ្នកជាប់ពន្ធមធ្យមចំនួន៣៨៩ និងក្រុមហ៊ុនរបបស្វ័យប្រកាសអ្នកជាប់ពន្ធតូចចំនួន៦២៦) មិនទាន់បានបង់ពន្ធប៉ាតង់ឆ្នាំ២០១៩នៅឡើយ។ ចំពោះអ្នកជាប់ពន្ធដែលមិនបានបង់ពន្ធប៉ាតង់ គឺមានមួយចំនួនធំជាសហគ្រាសបាត់ខ្លួន និងមិនបានមកដាក់លិខិតប្រកាសពន្ធ។ អគ្គនាយកដ្ឋានពន្ធដារនឹងជំរុញសាខាពន្ធដារខេត្តខណ្ឌពាក់ព័ន្ធណែនាំដល់អ្នកជាប់ពន្ធ ដែលនៅពុំទាន់បានបង់ពន្ធប៉ាតង់ ឱ្យមកបង់ពន្ធប៉ាតង់ឱ្យបានគ្រប់ចំនួន ព្រមទាំងពង្រឹងការផាកពិន័យទៅតាមច្បាប់ជាធរមានផងដែរ។

**៤.៣.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន**

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ប៉ុន្តែ អគ្គនាយកដ្ឋានពន្ធដារ មិនទាន់បានប្រមូលព័ត៌មានសហគ្រាសនៅតាមបណ្ដាក្រសួងស្ថាប័នមួយចំនួនផ្សេងទៀតឱ្យបានពេញលេញ និងទាន់ពេលវេលានៅឡើយ។ អាជ្ញាធរសវនកម្មជាតិបានឃើញនូវការបង្កើតក្រុមការងារមួយចំនួនរួចហើយ ហើយលើកទឹកចិត្តចំពោះការប្រមូលព័ត៌មានអំពីសហគ្រាសដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ននានាបន្ថែមទៀត។

**៤.៤.ការគ្រប់គ្រងអ្នកជាប់ពន្ធ**

ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់សារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រង់មាត្រា១០៤ថ្មី ចំណុច១ បានចែងថា "អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់"។

ច្បាប់សារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់មាត្រា១២៨ អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ ចំណុច១ "ករណីដែលបុគ្គលមិនបានដាក់លិខិតប្រកាសសារពើពន្ធ ដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់កំណត់" និងមាត្រា១២៩ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារបានចែងថា "ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេសពន្ធ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា១២៨នៃច្បាប់ខាងលើ ត្រូវបានចាត់ទុកថា បានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ"។

តាមការពិនិត្យរបាយការណ៍ស្តីពីការគ្រប់គ្រង និងប្រមូលចំណូលពន្ធសម្រាប់ខែធ្នូ ឆ្នាំ២០១៩ នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសចំនួន៦២ ៤៣៣ ត្រូវដាក់លិខិតប្រកាសពន្ធប្រចាំធ្នូ ឆ្នាំ២០១៩ ក្នុងនោះក្រុមហ៊ុនសហគ្រាសចំនួន២៥ ៨១៤ បានដាក់លិខិតប្រកាសពន្ធ ប៉ុន្តែក្រុមហ៊ុនសហគ្រាសមួយចំនួនផ្សេងទៀត (រួមទាំងក្រុមហ៊ុនសហគ្រាសបាត់ខ្លួន) មិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែធ្នូ ឆ្នាំ២០១៩។ ករណីនេះ សាខាពន្ធដារខ្លះបាននិងកំពុងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនសហគ្រាសមួយចំនួន ដើម្បីមានវិធានការបន្ត លើសពីនេះអគ្គនាយកដ្ឋានពន្ធដារបានខិតខំជំរុញណែនាំដល់នាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត ខណ្ឌ បន្តការធ្វើសវនកម្មឱ្យបានម៉ឺងម៉ាត់ និងដាក់ទណ្ឌកម្មពិន័យតាមច្បាប់ចំពោះក្រុមហ៊ុន សហគ្រាស ដែលខកខានមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធ។ ចំពោះការមិនបានដាក់ទោសទណ្ឌតាមមាត្រា១២៩ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារនៅតែព្យាយាមប្រើប្រាស់វិធានការទន់ភ្លន់ និងបន្តអប់រំដល់អ្នកជាប់ពន្ធឱ្យអនុវត្តបំពេញកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់ស្តីពីសារពើពន្ធសិន។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានប្រើប្រាស់វិធានការរដ្ឋបាលជាច្រើន មានដូចជា ការឃាត់ទុកការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ មិនឱ្យបើកក្រុមហ៊ុនថ្មី និងមិនឱ្យលក់ភាគហ៊ុនជាដើម។ល។

**៤.៥. ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ**

ច្បាប់ស្តីពីសារពើពន្ធបានកំណត់ឱ្យអ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីលិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ នោះអ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ...”។ តាមការពិនិត្យសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន៨៧ ក្រុមហ៊ុនសហគ្រាស អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន៦០ (ក្រុមហ៊ុនសហគ្រាសស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន១៦ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្ត ខណ្ឌចំនួន៤៤) ពុំទាន់បានកាន់កាប់ កត់ត្រា និងថែរក្សាទុកកិច្ចបញ្ជិកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីសារពើពន្ធនៅឡើយ ដែលជាហេតុនាំឱ្យរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ។ ករណីនេះ កន្លងមក អគ្គនាយកដ្ឋានពន្ធដារតែងតែធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំដល់អ្នកជាប់ពន្ធទាំងអស់ តាមរយៈការធ្វើសិក្ខាសាលា ដើម្បីជំរុញការអប់រំអ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ពន្ធដារ និងការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ប៉ុន្តែនៅមានក្រុមហ៊ុនមួយចំនួនតូច នៅតែព្យាយាមគេចវេះមិនព្រមកាន់កាប់ កត់ត្រា កិច្ចបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវនៅឡើយ។

## ៤.៦.របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ

សហគ្រាសវិនិយោគទាំងឡាយដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំរបស់សហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ។ តាមការពិនិត្យសំណុំឯកសារសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសមួយចំនួន បានបំពេញកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនឱ្យសវនករឯករាជ្យធ្វើសវនកម្ម ប៉ុន្តែក្រុមហ៊ុនសហគ្រាសមួយចំនួនទៀត មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រកាសខាងលើទេ។ កន្លងមក អគ្គនាយដ្ឋានពន្ធដារ តែងតែអនុវត្តគ្រប់ដំណាក់កាលលើនីតិវិធីនៃការធ្វើសវនកម្មពេញលេញដោយប្រើប្រាស់នូវគ្រប់មូលដ្ឋានព័ត៌មាន ដូចជា លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ របាយការណ៍សវនកម្មពីសវនករឯករាជ្យ (បើមាន) ឯកសារ ទិន្នន័យពាក់ព័ន្ធផ្សេងៗរបស់អ្នកជាប់ពន្ធដូចមានរាយក្នុងបញ្ជីស្នើសុំឯកសារ ត្រូវបានប្រមូល និងប្រើប្រាស់ជាធាតុចូលក្នុងការកំណត់ហានិភ័យក៏ដូចជាការកំណត់ពន្ធ ទោះបីជាការសហការឆ្លើយតប ឬផ្តល់ឯកសារពីអ្នកជាប់ពន្ធមកវិញនៅមានកម្រិតនៅឡើយ។

## ៤.៧.ការប្រើប្រាស់វិក្កយបត្រ

តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឱ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម គឺត្រូវមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេស ដូចជា ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ តាមការធ្វើតេស្តលើលិខិតប្រកាសពន្ធ និងឯកសារភ្ជាប់ផ្សេងៗរបស់ក្រុមហ៊ុនសហគ្រាសមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៩ ក្រុមហ៊ុនសហគ្រាសមួយចំនួនបានប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់បានត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជា វិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងចាត់វិធានការជាបន្តបន្ទាប់ ដោយបានធ្វើការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ រៀបចំសិក្ខាសាលាណែនាំដល់

អ្នកជាប់ពន្ធ ផ្ញើលិខិតជូនដំណឹងពាក់ព័ន្ធនឹងការប្រើប្រាស់វិក្កយបត្រជូនដល់សហគ្រាស និង ណែនាំដល់មន្ត្រីពន្ធដារពាក់ព័ន្ធគ្រប់ផ្នែកពិនិត្យមើលឱ្យបានម៉ឺងម៉ាត់ និងចាត់វិធានការមួយចំនួន ដូចជាៈ ធ្វើកំណត់ហេតុជាមួយតំណាងសហគ្រាសឱ្យធ្វើការកែសម្រួលឡើងវិញនូវការចេញវិក្កយបត្រឱ្យបានត្រឹមត្រូវតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ និងមិនអនុញ្ញាតឱ្យឥណទានអាករលើធាតុចូល ឬព្យួរការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ក្នុងករណីមិនអនុវត្តតាមវិធានវិក្កយបត្រ។

## ៤.៨.ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ

ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ នៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើតេស្តលើការត្រួតពិនិត្យលិខិតប្រកាសពន្ធប្រចាំខែ និងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ក្រុមហ៊ុនចំនួន៦៦១ (លិខិតប្រកាសពន្ធធំចំនួន១០២ ពន្ធមធ្យមចំនួន៣៣៩ និងពន្ធតូច២២០) នៅអង្គភាពពន្ធចំនួន២៥ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនមួយចំនួន មានបញ្ហាគួរឱ្យកត់សម្គាល់ ដូចជាគណនាពន្ធលើប្រាក់បៀវត្សមិនត្រឹមត្រូវ បន្ទាបបៀវត្សបុគ្គលិកជំនាញ មិនប្រកាសពន្ធកាត់ទុកលើសេវាកម្ម ប្រកាសចំណូលថេរ ប្រកាសចំណូលទាប គណនាប្រាក់អាករពិសេសមិនត្រឹមត្រូវ និងមិនបង្ហាញមូលដ្ឋានគិតអាករពិសេស និងអាករបំភ្លឺសាធារណៈ។

កន្លងមក អគ្គនាយកដ្ឋានពន្ធដារតែងតែធ្វើការណែនាំជាប់ជាប្រចាំ និងតាមរយៈសិក្ខាសាលាផងដែរ ដើម្បីធ្វើការផ្សព្វផ្សាយដល់អ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ស្តីពីសារពើពន្ធ និងការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ។ ម្យ៉ាងវិញទៀត អ្នកជាប់ពន្ធតែងតែសម្រុកមកដាក់លិខិតប្រកាសពន្ធប្រចាំខែ នៅថ្ងៃផុតកំណត់ការទទួលលិខិតប្រកាស ដែលធ្វើឱ្យមានភាពកកស្ទះ នាំឱ្យមន្ត្រីទទួលលិខិតប្រកាសមិនអាចពិនិត្យទិន្នន័យលើលិខិតប្រកាសពន្ធរបស់អ្នកជាប់ពន្ធបានគ្រប់ជ្រុងជ្រោយនោះឡើយ។ ប៉ុន្តែបន្ទាប់ពីទទួលលិខិតប្រកាសរួចហើយ មន្ត្រីទទួលបន្ទុកលិខិតប្រកាសបានធ្វើការត្រួតពិនិត្យតាមក្រោយករណីលិខិតប្រកាសពន្ធណាមួយដែលមានភាពមិនប្រក្រតី មន្ត្រីទទួលបន្ទុកបានអញ្ជើញតំណាងមកធ្វើការណែនាំឱ្យធ្វើការកែតម្រូវលិខិតប្រកាសឡើងវិញ និងដាក់កម្មវិធីធ្វើសវនកម្មមានកម្រិត។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តអប់រំ ផ្សព្វផ្សាយ និងណែនាំដល់អ្នកជាប់ពន្ធពីកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និងបន្តជំរុញបន្ថែមទៀតដល់មន្ត្រីទទួលបន្ទុកពិនិត្យការដាក់លិខិតប្រកាសរបស់អ្នកជាប់ពន្ធឱ្យបានត្រឹមត្រូវ។

## ៤.៩.ការប្រមូលពន្ធអចលនទ្រព្យ

គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបានតម្រូវឱ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ ការអនុវត្តប្រមូលពន្ធអចលន

ទ្រព្យនៅមានកម្រិតនៅឡើយ តាមការធ្វើតេស្តនៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និង សាខាពន្ធដារខេត្តចំនួន១៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អចលនទ្រព្យមួយចំនួននៅមិនទាន់បានបង់ពន្ធអចលនទ្រព្យសម្រាប់ឆ្នាំ២០១៩។ អគ្គនាយកដ្ឋានពន្ធដារ នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះខាតទិន្នន័យអចលនទ្រព្យ ខ្វះមន្ត្រី និងខ្វះការសហការពីម្ចាស់អចលនទ្រព្យ។

អគ្គនាយកដ្ឋានពន្ធដារបានបន្តជំរុញសាខាពន្ធដារខេត្ត-ខណ្ឌពាក់ព័ន្ធ ត្រូវបន្តយកចិត្តទុកដាក់ប្រមូលពន្ធលើអចលនទ្រព្យឱ្យបានអស់លទ្ធភាព។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតក្រុមការងារចុះផ្តល់សេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពតាមរយៈការធ្វើអង្កេតអចលនទ្រព្យនៅរាជធានី និងតាមបណ្តាខេត្ត។ កត្តានេះនឹងអាចជួយរដ្ឋបាលសារពើពន្ធងាយស្រួលក្នុងការត្រួតពិនិត្យ និងជំរុញការបំពេញកាតព្វកិច្ចពន្ធរបស់ម្ចាស់អចលនទ្រព្យបានគ្រប់គ្នា។ ដោយឡែកចំពោះម្ចាស់អចលនទ្រព្យដែលមិនបានបំពេញកាតព្វកិច្ចសារពើពន្ធ ម្ចាស់អចលនទ្រព្យនោះត្រូវទទួលរងពិន័យ និងទោសទណ្ឌតាមច្បាប់ជាធរមាន។

## ៤.១០.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ

ប្រកាសលេខ១៤៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រង់ជំពូកទី៥ នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ ប្រការ២១ បានបញ្ជាក់ថា នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈមានតួនាទី និងភារកិច្ចដូចជា៖ ពិនិត្យកំណត់ហេតុល្មើសគយ លើកសំណើសម្រុះសម្រួល និងសម្រេចវិនិច្ឆ័យលើបទល្មើសគយ និងវិវាទផ្សេងទៀតជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពិនិត្យ និងសម្រេច។

ប្រកាសលេខ៦១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការសម្រុះសម្រួលបទល្មើសគយ ត្រង់ប្រការ៤ បានបញ្ជាក់ថា ប្រសិនបើក្នុងរយៈពេលកៅសិប(៩០)ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្តីសម្រេចជាផ្លូវការស្តីពីការសម្រុះសម្រួលនូវបទល្មើសគយមិនអាចទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ មានកំណត់ហេតុល្មើសច្បាប់គយចំនួន៨២៦ ក្នុងនោះកំណត់ហេតុចំនួន៣៧១ ត្រូវបានធ្វើសេចក្តីសម្រេចវិនិច្ឆ័យរួច (បូកកំណត់ហេតុសល់ឆ្នាំ២០១៨) ប៉ុន្តែនៅសល់កំណត់ហេតុល្មើសចំនួន៥៦៥ទៀត នៅពុំទាន់បានធ្វើការដោះស្រាយ និងមានវិធានការសមស្របនៅឡើយ។ កន្លងមក មន្ត្រីនៃនាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានខិតខំរិះរកមធ្យោបាយសម្រុះសម្រួលបទល្មើសគយដោយអនុលោមតាមក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិគយ មុនពេលមានសាលក្រមរបស់តុលាការ តែការសម្រុះសម្រួលនេះ បានជួបនូវបញ្ហាប្រឈមមួយចំនួន។ យោងតាមច្បាប់ និងបទប្បញ្ញត្តិ

គយជាធរមាន បទល្មើសគយណាដែលមិនអាចសម្រុះសម្រួលបាន គឺអង្គភាពគយនីមួយៗ ដែលជាម្ចាស់នៃដើមបណ្តឹង ត្រូវរៀបចំសំណុំរឿងទៅតុលាការតាមដែនសមត្ថកិច្ចរបស់ខ្លួន។ អង្គភាពគយ និងរដ្ឋាករកម្ពុជាបានបញ្ជូនសំណុំរឿងទៅតុលាការជាបន្តបន្ទាប់ និងកំពុងរង់ចាំការសម្រេច។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបាននិងកំពុងបន្តខិតខំរិះរកវិធានការ និងមធ្យោបាយដោះស្រាយកំណត់ហេតុល្មើសច្បាប់គយដែលនៅសេសសល់តាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិបន្ថែមទៀត។

### ៤.១១.ការយឺតយ៉ាវក្នុងការផ្ញើសលាកប័ត្របង្វែរថវិកាចូលរតនាគារ

ប្រកាសលេខ០១៤ ប្រក.សហវ.រជ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកម្រិតកំណត់ចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋដែលភ្នាក់ងារ ឬអង្គភាពនីមួយៗអាចរក្សាទុកនៅក្នុងបេឡារបស់ខ្លួន ត្រង់ប្រការ២ បានកំណត់ថា "ចំពោះគណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុនៅរាជធានីភ្នំពេញមិនឲ្យលើសពី៥ ០០០ ០០០រៀល និងនៅតាមបណ្តាខេត្តក្រុងមិនឱ្យលើសពី២ ០០០ ០០០រៀល។ ចំពោះរជ្ជទេយ្យករចំណូលមិនឲ្យលើសពី២ ០០០ ០០០រៀលឡើយ"។ លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានចេញសារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ ស្តីពីការកែលម្អនីតិវិធីអនុវត្តថវិកាដែលតម្រូវឱ្យលុបបំបាត់ទាំងអស់ និងជាបន្ទាន់នូវទង្វើរក្សាប្រាក់ចំណូលសម្រាប់ចំណាយ និងសាច់ប្រាក់ឱ្យតម្កល់ទុកបានក្នុងបេឡាមិនត្រូវឱ្យលើសពីចំនួនបានកំណត់ ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០១៤ ប្រក.សហវ.រជ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ នោះទេ។

តាមការពិនិត្យលើស្ថានភាពចំណូលចំណាយ (បញ្ជីលេខ១) ឆ្នាំ២០១៩ នៅតាមនាយកដ្ឋាន សាខាគយ និងរដ្ឋាករ និងការិយាល័យគយ និងរដ្ឋាករនៃរាជធានី ខេត្តមួយចំនួន និងការបង់ចំណូលចូលរតនាគាររាជធានី ខេត្ត អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋាន សាខាគយនិងរដ្ឋាករ និងការិយាល័យគយនិងរដ្ឋាករទាំងនោះបានរក្សាទុកសមតុល្យសាច់ប្រាក់ចំណូលក្នុងបេឡាមានរយៈពេលយូរថ្ងៃ ទើបផ្ញើសលាកប័ត្របង្វែរបង់ចូលរតនាគាររាជធានីខេត្ត ដែលប្រការនេះមិនស្របតាមខ្លឹមសារនៃប្រកាស និងសារាចរណែនាំខាងលើ។ ជាគោលការណ៍ ការិយាល័យគយ និងរដ្ឋាករអាចរក្សាសាច់ប្រាក់មិនលើសពី៥លានរៀលក្នុងបេឡារបស់ខ្លួន។ ដោយឡែកក្នុងការអនុវត្តពិតជាមានការលំបាកខ្លះដោយហេតុផលដូចខាងក្រោម៖

- ការប្រតិបត្តិការងារប្រចាំថ្ងៃ រួមទាំងថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃឈប់សម្រាកផ្លូវការផ្សេងទៀត និងត្រូវបំពេញការងារដល់យប់ផងដែរ ដែលនាំឱ្យប្រាក់ពន្ធ និងអាករប្រមូលបានត្រូវរក្សាក្នុងបេឡាជាបណ្តោះអាសន្នសិន ព្រោះមិនអាចយកទៅបង់ចូលធនាគារ ឬរតនាគារបានទាន់ពេលកំណត់។
- ការិយាល័យគយ និងរដ្ឋាករមួយចំនួនស្ថិតនៅឆ្ងាយពីទីប្រជុំជនដែលពុំមានធនាគារ ហើយអាជីវករតូចតាចតែមានសកម្មភាពមមាញឹកតាមតំបន់ព្រំដែន ធុរជន និងអ្នកដំណើរម្តងម្កាលឆ្លងកាត់ព្រំដែន ពុំមានលទ្ធភាពបង់ប្រាក់តាមប្រព័ន្ធធនាគារមូលដ្ឋាននៅឡើយ។
- ករណីភាគច្រើនពុំពាក់ព័ន្ធពីការរក្សាសាច់ប្រាក់នៅក្នុងបេឡាគយលើសកំណត់នោះទេ ហើយគ្រាន់តែជាការយឺតយ៉ាវក្នុងការផ្ញើសលាកប័ត្របង្វែរចូលថវិកាជាតិតែប៉ុណ្ណោះ ហើយសាច់

ប្រាក់ស្ទើរទាំងស្រុង(ជាង៩០%) ត្រូវបានបង់ចូលរតនាគារជាតិតាមរយៈធនាគារពាណិជ្ជរួចហើយ ដែលរតនាគារជាតិអាចប្រើប្រាស់សាច់ប្រាក់ទាំងនោះបាន។

- ករណីនេះ អង្គភាពភាគច្រើនបានកែសម្រួលរួចហើយ ដោយធ្វើសលាកប័ត្រច្រើនដង ទៅតាមចំនួនទឹកប្រាក់ដែលប្រមូលបាន។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានឹងជំរុញបន្ថែមទៀតដល់អង្គភាពក្រោមឱវាទ ឱ្យរួតរះធ្វើសលាកប័ត្របង់ចំណូលចូលថវិកាជាតិជាប្រចាំទៅតាមករណីជាក់ស្តែង។

## ៤.១២.ការយឺតយ៉ាវក្នុងការធ្វើប្រកាសបង្វែរឥណទានតួលេខចំណូលចូលថវិកា

សារាចរណែនាំលេខ០០៧ សហវ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្ត ចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៩ ត្រង់ចំណុច I អំពីការបិទបញ្ជីចំណូល ចំណាយថវិកា ថ្នាក់ជាតិឆ្នាំ២០១៩ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទីIII និងមាត្រា១០៦នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ **ដូចនេះ ប្រាក់ចំណូលទាំងអស់ ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ជាកំហិត។**

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានការយឺតយ៉ាវក្នុងការធ្វើប្រកាសផ្ទេរឥណទានតួលេខចំណូលពន្ធអាករ ជាបន្ទុករដ្ឋរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលនៅសល់សមតុល្យចុងឆ្នាំ២០១៩ ដោយមិនទាន់បានបង្វែរចូលថវិកា មានចំនួន **១៣៦ ០៩០លានរៀល** រួមមាន៖

– អាករលើតម្លៃបន្ថែមរបបនាំចូលជាបន្ទុករបស់រដ្ឋ គណនីលេខ៧០០២៧ មានចំនួន**៩៩ ២៦៤ លានរៀល**

– ពន្ធនាំចូលវត្ថុជាបន្ទុករដ្ឋ គណនីលេខ៧១០០៧ មានចំនួន**៦ ៣៧៤លានរៀល**។

ចំពោះការដែលនៅសល់នេះ គឺបណ្តាលមកពីការគ្រោងឥណទានពុំបានគ្រប់គ្រាន់ ហើយចំណូលពីអនុគណនីនេះមានកំណើនលើសការគ្រោងទុក ដែលតាមនីតិវិធីហិរញ្ញវត្ថុ តួលេខនេះត្រូវបូកយោងដាក់ជាឥណទានគ្រោងនៅឆ្នាំបន្ទាប់ ហើយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក៏បានបង្វែរចូលថវិការួចហើយដែរ តាមរយៈសលាកបត្រលេខ០០០១/២០២០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។ ចាប់ពីឆ្នាំ២០២០តទៅ ករណីនេះមិនមានទៀតទេ ព្រោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសម្រេចឱ្យបង្វែរតួលេខចំណូលនេះជាបន្ទុករដ្ឋវិញ។

## ៤.១៣.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ

សារាចរណែនាំលេខ០០៧ សហវ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្ត ចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៩ ត្រង់ចំណុច I អំពីការបិទបញ្ជីចំណូល ចំណាយថវិកា ថ្នាក់ជាតិឆ្នាំ២០១៩ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏

ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទីIII និងមាត្រា១០៦នៃអនុក្រឹត្យលេខ៨២ អនក្រ.បកចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ **ដូចនេះ ប្រាក់ចំណូលទាំងអស់ ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ជាកំហិត។**

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) មានសមតុល្យនៅសល់តួលេខចំណូលមិនមែនសារពើពន្ធ (រដ្ឋបាលកណ្តាល) ចុងឆ្នាំ២០១៩ ចំនួន ៣ ៣០៦ លានរៀល ដោយមិនទាន់បានបង្វែរចូលថវិការដ្ឋនៅឡើយ។ ថវិកាដែលជាចំណូលសេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១៩ ពិតជាបានបង់ចូលថវិការដ្ឋយឺតយ៉ាវមែន ប៉ុន្តែអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធបានធ្វើការណែនាំឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបង់ចំណូលចូលថវិការដ្ឋនេះរួចរាល់ក្នុងឆ្នាំ២០២០។

**៤.១៤.ការទូទាត់ និងការកត់ត្រាចំណាយ**

ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ឆ្នាំ២០១៩ ត្រឹមវេលាម៉ោង១៧ និង៣០នាទី នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០"។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់មួយចំនួន (សម្រាប់រដ្ឋបាលកណ្តាល) ត្រូវបានបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់នៅក្រោយថ្ងៃកំណត់បិទបញ្ជី (អំឡុងពេលខែកុម្ភៈ ដល់ខែមីនា ឆ្នាំ២០២០) ហើយបានកត់ត្រាជាចំណាយថវិកាប្រចាំឆ្នាំ២០១៩ មានចំនួន៤ ៣២៧អាណត្តិបើកប្រាក់ ស្មើនឹងទឹកប្រាក់ចំនួន ២ ៨៩០ ៦៥៥ ៧០១ ៨១៣ រៀល (អាណត្តិបើកប្រាក់ជាប្រាក់រៀលមានចំនួន៤ ១៩៧អាណត្តិបើកប្រាក់ ស្មើនឹង២ ៣២៧ ៦៨៩ ៧០១ ០៩០រៀល និងអាណត្តិបើកប្រាក់ជាដុល្លារមានចំនួន១៣០អាណត្តិបើកប្រាក់ស្មើនឹងទឹកប្រាក់ចំនួន៥៦២ ៩៦៦ ០០០ ៧២៣រៀល)។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា នៅរៀងរាល់ដំណាច់ឆ្នាំនីមួយៗ គឺមានការបញ្ជូនអាណត្តិបើកប្រាក់ក្នុងចំនួនច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានភាពយឺតយ៉ាវ មិនទាន់ពេលវេលាកំណត់ តាមសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកាប្រចាំឆ្នាំ ជាពិសេសគឺនៅក្នុងខែធ្នូ ឆ្នាំ២០១៩។ ដោយឡែក បើពិនិត្យប្រភេទអាណត្តិបើកប្រាក់ទាំងនោះ គឺមានអាណត្តិនិយ័តកម្មមួយចំនួន (អាណត្តិទូទាត់ប្រាក់បុរេប្រទាន និងអាណត្តិទូទាត់ប្រាក់រដ្ឋទេយ្យបុរេប្រទាន) ដែលចាំបាច់ត្រូវទូទាត់ជម្រះបញ្ជីក្នុងឆ្នាំថវិកា២០១៩ ដើម្បីបិទបញ្ជីដោយកត់ត្រាចំណាយថវិកាឱ្យបានពេញលេញ និងបង្ការកុំឱ្យមានការលំបាកច្រើនដល់កិច្ចទូទាត់ជម្រះបញ្ជីនៅឆ្នាំបន្តបន្ទាប់។ ម្យ៉ាងទៀត រយៈពេលនេះគឺស្ថិតនៅក្នុងរយៈពេលបំពេញបន្ថែមសម្រាប់ប្រតិបត្តិការនិយ័តកម្មនៃរតនាគារ។ បន្ថែមពីលើនេះការទូទាត់ចំណាយខាងលើ គឺបានសម្រួលដល់ការទូទាត់ចំណាយចាំបាច់ និងការទូទាត់ជម្រះបញ្ជីប្រតិបត្តិការចំណាយក្នុងឆ្នាំថវិកា២០១៩ និងបញ្ចៀសការបង្ករបន្ទុកចំណាយទៅឆ្នាំថវិកា២០២០ និងឆ្នាំបន្តបន្ទាប់។

ទន្ទឹមនឹងនេះ ក៏មានមូលហេតុទាក់ទងនឹងគោលការណ៍អនុញ្ញាតបន្តឱ្យទទួលអាណត្តិទូទាត់នៅអគ្គនាយកដ្ឋានរតនាគារជាតិនាចុងឆ្នាំ ដើម្បីធានាឱ្យប្រតិបត្តិការចំណាយសម្រេចបានតាមគោលដៅ និងមិនខាតឥណទានក្នុងឆ្នាំ ព្រមទាំងដើម្បីអាចឱ្យលទ្ធផលសមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីសម្រេចបានខ្ពស់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តជំរុញក្រសួង ស្ថាប័នឱ្យរួសរាន់រៀបចំលិខិតយុត្តិការចំណាយ និងបោះផ្សាយអាណត្តិបើកប្រាក់ រួចបញ្ជូនទៅអភិបាលហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីអាចធ្វើការទូទាត់បានទាន់ពេលវេលា ជាពិសេសការទូទាត់ជម្រះបញ្ជីបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានឱ្យទាន់ក្នុងឆ្នាំថវិកា ជៀសវាងការបង្ករបំណុលទៅឆ្នាំថវិកាបន្ទាប់ទៀត។ ទន្ទឹមនឹងនេះ ក្រសួងក៏បន្តជំរុញ និងពង្រឹងការអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលនឹងចូលរួមធានាឱ្យការអនុវត្តចំណាយថវិកាស្របតាមគោលការណ៍នៃកាលបរិច្ឆេទកំណត់ ព្រមទាំងព្យាយាមបញ្ចប់នូវប្រតិបត្តិការទូទាត់ឱ្យបានឆាប់ដោយមិនត្រូវពន្យារពេលដល់ចុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។ រាល់ឯកសារដែលមិនមានភាពចាំបាច់ខ្លាំង និងមិនមានឯកសារគាំទ្រគ្រប់គ្រាន់ ហើយដែលហួសពេលកំណត់សម្រាប់ធ្វើការទូទាត់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែងមិនអនុញ្ញាតឱ្យទូទាត់ ឬតែងបញ្ជូនត្រឡប់ទៅកាន់អង្គភាពសាមី ដើម្បីប្រើប្រាស់ឥណទានឆ្នាំថ្មី។

**៤.១៥.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់**

ដើម្បីធានាបាននូវការទទួលខុសត្រូវក្នុងការអនុវត្តចំណាយថវិការដ្ឋ អគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករសាធារណៈ មានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ។ ការអនុវត្តតួនាទីនេះបានគត់មត់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តិការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ចំណាយ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ដូចជា៖ កិច្ចសន្យាលទ្ធកម្មដែលមានពន្ធប្រថាប់ត្រា និងបណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ជាដើម។ល។ តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់ចំនួន១៧៣ របស់ក្រសួងមួយចំនួន ដែលទទួលបានការយល់ព្រមទូទាត់ដោយអគ្គនាយកដ្ឋានរតនាគារជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ចំនួន១៤ មិនបានភ្ជាប់នូវឯកសារគាំទ្រត្រឹមត្រូវដូចជា៖ ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនសមស្របតាមកម្មវត្ថុនៃការចំណាយ ប្រភេទអាជីវកម្មមិនត្រូវតាមការផ្គត់ផ្គង់ និងប្រថាប់ត្រាក្រោយកាលបរិច្ឆេទទូទាត់ ដោយចុងឆ្នាំមានឯកសារស្នើសុំធ្វើការទូទាត់មានចំនួនច្រើន និងមានគោលការណ៍អនុញ្ញាតបោះផ្សាយអាណត្តិតម្កល់នៅរតនាគារជាតិពិសេសអាណត្តិទូទាត់កិច្ចលទ្ធកម្មសាធារណៈ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា អាស្រ័យដោយនៅកៀកដំណាច់ឆ្នាំថវិកា ២០១៩ មានការបញ្ជូនអាណត្តិបើកប្រាក់គំហុកច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយ

ក្នុងនោះអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្មមួយចំនួនមានបញ្ហាខ្វះចន្លោះ មិនត្រឹមត្រូវតាមនីតិវិធីនៃការទូទាត់។ ផ្អែកតាមសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិបានយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្ម ដើម្បីមានមូលដ្ឋានក្នុងការទូទាត់ចំណាយថវិកា ដោយផ្អែកលើកំណត់ហេតុប្រគល់-ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងាររបស់គណៈកម្មការលទ្ធកម្មដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងច្បាស់លាស់លើទំនិញ ឬសេវាដែលបានបំពេញរួច។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានណែនាំដល់ក្រសួង ស្ថាប័ន ក៏ដូចជាអ្នកផ្គត់ផ្គង់ឱ្យបំពេញបន្ថែមនូវសក្ខីប័ត្រចំណាយឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ មានជាអាទិ៍ ការបង់ពន្ធប៉ាតង់បន្ថែមឱ្យស្របតាមប្រភេទអាជីវកម្ម និងការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាជាដើម។ កត្តានេះ ក៏បានរួមចំណែកក្នុងការប្រមូលពន្ធបង់ចូលថវិការដ្ឋផងដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ ដោយសារកត្តាពេលវេលា និងការមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ពីដើមទី ក៏មាននៅសល់បញ្ហាខ្វះចន្លោះមួយចំនួនដែលតម្រូវឱ្យមានកិច្ចសហការចូលរួមពង្រឹងបន្ថែមពីសាមីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចាប់ពីដើមទី នៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។ ទន្ទឹមនឹងនេះ ក៏មានគោលការណ៍អនុញ្ញាតបោះផ្សាយអាណត្តិតម្កល់នៅអគ្គនាយកដ្ឋានរតនាគារជាតិ ពិសេសអាណត្តិទូទាត់កិច្ចលទ្ធកម្មសាធារណៈ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តពង្រឹងការត្រួតពិនិត្យលិខិតយុត្តិការចំណាយ និងទូទាត់ចំណាយថវិកាឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ជាពិសេសជំរុញកិច្ចសហការរវាងអគ្គនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួង ស្ថាប័ន ដែលជាអង្គភាពពាក់ព័ន្ធពីដើមទី ឱ្យចូលរួមក្នុងការពង្រឹង និងដោះស្រាយបញ្ហាប្រឈមទាំងនេះ នៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់ ព្រមទាំងព្យាយាមលុបបំបាត់នូវនីតិវិធីក្នុងការបោះផ្សាយអាណត្តិតម្កល់នៅអគ្គនាយកដ្ឋានរតនាគារជាតិ និងណែនាំដល់ក្រសួង ស្ថាប័ន ឱ្យស្នើសុំធ្វើការទូទាត់ចំណាយបានទាន់ពេលវេលា និងតាមផែនការកំណត់ច្បាស់លាស់។

## ៤.១៦.ក្រសួងស្ថាប័នមួយចំនួនមិនបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៩

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជាស្ដីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា២៣ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២៤ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១ ខែមេសា ខែកក្កដា ខែតុលា និងខែមករា។ ការខកខានដោយមិនបានផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មតាមកាលកំណត់នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិចារណាផ្អាកការផ្តល់ធានាចំណាយសម្រាប់គម្រោងលទ្ធកម្មបន្តបន្ទាប់។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនបានផ្ញើ និងមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០១៩ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការក្រើនរំលឹក និងបានរៀបចំផ្ញើលិខិតជូនស្ថាប័នអនុវត្តលទ្ធកម្មដែលមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៩ តាមរយៈលិខិតលេខ១២៩ សហវ.អលសា ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។

**៤.១៧.ការមិនបានបែងចែក និងវិភាជន៍ឥណទានថវិកាទៅឱ្យអង្គភាពថវិកា**

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុចIII.២ កថាខណ្ឌទី២ បានចែងថា "ដើម្បីឱ្យអង្គភាពថវិកាទទួលខុសត្រូវលើការអនុវត្តថវិកា និងការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ពិសេសដើម្បីបង្កើនគណនេយ្យភាពចំណាយឱ្យកាន់តែប្រសើរ រដ្ឋមន្ត្រីប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវវិភាជន៍ថវិកាឱ្យអង្គភាពថវិកាក្រោមឱវាទឱ្យបានទាន់ពេលវេលាសមស្របតាមការិយបរិច្ឆេទនៃឆ្នាំសារពើពន្ធនៃការអនុវត្តថវិកា"។

ប្រកាសអន្តរក្រសួងលេខ៥៨៨ ប្រក.សក.ហវ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិការវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រង់ប្រការ១ បានទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន៣៣ ដូចជា៖ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានសាធារណការ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ... និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តចំនួន២៥ និងប្រការ៣ បានចែងថា "ប្រកាសនេះមានប្រសិទ្ធភាពសម្រាប់ការអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ"។

តាមការពិនិត្យរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំឆ្នាំ២០១៩ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ក្នុងឆ្នាំ២០១៩ ក្រសួងសាធារណការ និងដឹកជញ្ជូនពុំទាន់បានបែងចែក ឬវិភាជន៍ថវិកាឱ្យបានពេញលេញទៅឱ្យអង្គភាពថវិកា ដើម្បីទទួលខុសត្រូវលើការអនុវត្តថវិកាកម្មវិធី ហើយរាល់ប្រតិបត្តិការនៃការចំណាយថវិកាកម្មវិធីភាគច្រើន នៅបន្តអនុវត្តក្នុងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ (អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ) ប៉ុណ្ណោះ។ កត្តានេះអាចនាំឱ្យការអនុវត្តថវិកាកម្មវិធីពុំទាន់អនុវត្តបានរលូនស្របតាមប្រកាសខាងលើ។

ដូចនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរធ្វើការបែងចែក និងវិភាជន៍ឥណទានថវិកាទៅឱ្យអង្គភាពថវិការបស់ខ្លួនឱ្យបានពេញលេញ។

ក្រសួងសាធារណការ និងដឹកជញ្ជូនបានបញ្ជាក់ថា ឆ្នាំ២០១៩ ក្រសួងបានវិភាជន៍ថវិកាទៅឱ្យអង្គភាពថវិកានូវខ្ទង់ចំណាយ ប្រេងឥន្ធនៈ ការបោះពុម្ព និងបេសកកម្មក្នុងប្រទេស។ ចំពោះការវិភាជន៍លើមុខចំណាយផ្សេងៗទៀត គឺត្រូវមានការសម្រេចពីថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន។

អាជ្ញាធរសវនកម្មជាតិ នឹងធ្វើការតាមដានការអនុវត្តអនុសាសន៍នេះជាបន្តទៀត។

### ៤.១៨.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥(ប្រាំ)ឆ្នាំនៃឆ្នាំគោល។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួន នៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋដែលមានដូចជា៖

| ល.រ | ក្រសួង ស្ថាប័ន រាជធានីខេត្ត និងមន្ទីរអង្គភាពរាជធានីខេត្ត | បញ្ជីសារពើភណ្ឌឆ្នាំគោល២០១៩ | | |
|---|---|---|---|---|
| | | បានធ្វើ | មិនបានធ្វើ | សរុប |
| ១ | ក្រសួង-ស្ថាប័ន (ថ្នាក់កណ្តាល) | ១៣០ | ១៥០ | ២៨០ |
| ២ | មន្ទីរជំនាញ(ថ្នាក់មូលដ្ឋាន) | ៥៤ | ៧១៥ | ៧៦៩ |
| ៣ | រដ្ឋបាលរាជធានី-ខេត្ត | ០១ | ២៤ | ២៥ |
| ៤ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | ០ | ២០៣ | ២០៣ |
| ៥ | រដ្ឋបាលឃុំ សង្កាត់ | ៨៦ | ១ ៥៦០ | ១ ៦៤៦ |

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា ក្រសួងបានចេញលិខិតជំរុញជារៀងរាល់ឆ្នាំអំពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ជាក់ស្តែងក្នុងឆ្នាំ២០១៩ ក្រសួងបានចេញលិខិតចំនួន០៨ រួមមាន៖ លិខិតលេខ៥៤៧ សហវ.អទច, ៥៤៦ សហវ.អទច, ៥៤៥ សហវ.អទច, ៥៤៤ សហវ.អទច, ៥៦០ សហវ.អទច, ៥៦១ សហវ.អទច, ៥៦២សហវ.អទច, ៥៦៣សហវ.អទច ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ជម្រាបជូនគ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ស្តីពីការរៀបចំ និងបញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល២០១៩ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាត់មន្ត្រីជំនាញចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃលើការរៀបចំរហូតដល់បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលបានសរុបចំនួន២ ១៨២ច្បាប់ នៃចំនួនសរុប២ ៩៩៨ច្បាប់ ក្នុងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ) ទទួលបាន៥៣៨ច្បាប់ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ទទួលបាន១ ៦៤៤ច្បាប់ និងនៅសល់ចំនួន៨១៦ច្បាប់ ដែលអាជ្ញាធរកាន់កាប់មិនទាន់ផ្ញើមក។

ចំពោះការយឺតយ៉ាវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសង្កេតឃើញ មានកត្តាពីរធំៗ ដូចខាងក្រោម៖

១. ចំនួនអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋមានចំនួនកើនឡើងពី៦១ រហូតដល់១ ៩១០ និងអង្គភាពប្រើប្រាស់នៃអាជ្ញាធរទាំងនោះ មានចំនួនកើនឡើងពី១ ១៥៤ ដល់២ ៩៩៨ ដោយសារផ្អែកតាមខ្លឹមសារនៃអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា

ឆ្នាំ២០១៧ ឃុំសង្កាត់ចំនួន ១ ៦៤៦ បានក្លាយជាអាជ្ញាធរកាន់កាប់ដោយស្វ័យប្រវត្តិ និងមានកាតព្វកិច្ចក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយខ្លួនឯង។

២. ការផ្ទុះឡើងនូវជំងឺកូវីដ-១៩។

ទោះជាយ៉ាងនេះក្តី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្តនៅតែបន្តជំរុញបន្ថែមជាប់ជានិច្ចតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ដូចជាជំរុញតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម (តេឡេក្រាម) និងកម្មវិធីសិក្ខាសាលានានាជាដើម។

## ៤.១៩.ការធ្វើបណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ តាមការធ្វើសវនកម្មលើក្រសួងស្ថាប័នចំនួន៥ ដែលមានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន១២៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានទីតាំងចំនួន៥៨កន្លែង មានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ប៉ុន្តែមានទីតាំងចំនួន៧០កន្លែងទៀត នៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺបន្ថែមថា ក្រសួងបានជំរុញជារៀងរាល់ឆ្នាំជាមួយនឹងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងបានចេញប្រកាសអន្តរក្រសួងលេខ៣៥៦ សហវ.ប្រក ស្តីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយខ្លឹមសារប្រការ៣ នៃប្រកាសនេះ បានចែងអំពីការលើកលែងការយកកម្រៃសេវាសាធារណៈចំពោះការចុះបញ្ជីដីលើកដំបូងលើដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគរុភណ្ឌជាដីរបស់វត្ត ប៉ុន្តែដីដែលជាទ្រព្យសម្បត្តិរបស់សហគ្រាសសាធារណៈ ត្រូវបង់កម្រៃសេវាសាធារណៈជាធម្មតា។ ក្នុងន័យនេះ គឺដើម្បីលើកទឹកចិត្ត និងពន្លឿនលើការធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋ។ ហើយថ្មីៗនេះ គឺកាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានជួបប្រជុំពិភាក្សាគ្នា និងទទួលបានឯកភាពរៀបចំយន្តការអន្តរក្រសួងចំនួនពីរកម្រិតសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីដឹកនាំធ្វើកិច្ចការនេះ ដែលយន្តការទាំងពីរនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងបង្កើតគណៈកម្មការអន្តរក្រសួងរួចរាល់ និងកំពុងដាក់ឆ្លងជូនថ្នាក់ដឹកនាំនៃក្រសួងទាំងពីរពិនិត្យតាមនីតិវិធី។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងពុះពាររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន និងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ សមិទ្ធផលទាំងនេះ មានប្រសិទ្ធភាពបំផុតសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ និងបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សានូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីភាពពហុបក្ស ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងការធានាបាននូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវ័ន្តនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងការកាត់បន្ថយភាពក្រីក្រ និងបានផ្តល់នូវមធ្យោបាយ និងធនធានសមស្របដល់ក្រសួង ស្ថាប័ន ជាពិសេសការបង្កើនល្បឿននៃការអភិវឌ្ឍ ការលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងការចូលរួមដោះស្រាយបញ្ហាជាច្រើនទៀតរបស់ជាតិ និងប្រជាជន រួមមានការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការទូទៅ ការបន្តគាំទ្រការវិនិយោគចាំបាច់នានា ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចដោយឈរលើគោលការណ៍ប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានល្អប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូលចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។